ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jan-2013, 14:51
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ១២នាទី**

**សវនាការលើកទី១៤៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន *(Mr.Dav ANSAN)*

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger PHILIPS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្ស៊ី

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ ខ្លួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ទ្បោ ជុនធី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ តាមកាលវិភាគដែលមានការបត់បែនកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ដែលអង្គជំនុំជម្រះបានជូនទៅភាគី គឺអង្គជំនុំជម្រះនឹងធ្វើសវនាការលើឯកសារដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១។ ដោយហេតុថានៅក្នុងសប្តាហ៍មុននេះ ជនជាប់ចោទមានបញ្ហាសុខភាពត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់ ធ្វើឲ្យកាលវិភាគនៃការកំណត់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីត្រូវបានអាក់ខាន។ ហើយនាពេលនេះ គឺអង្គជំនុំជម្រះបានជម្រាបជូនទៅភាគីក្នុងការបត់បែនកែសម្រួលនូវកាលវិភាគសម្រាប់កិច្ចដំណើរការសវនាការនៅចំពោះមុខនាពេលនេះ គឺធ្វើសវនាការលើឯកសារ។ ហើយដូចជាកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយ ដើម្បីជម្រាបជូនទៅភាគីពាក់ព័ន្ធទៅនឹងរឿងក្តីនេះ ដោយកំណត់ការធ្វើសវនាការលើឯកសារ ដែលនៅថ្ងៃចន្ទ និងថ្ងៃអង្គារ គឺទី២១, ២២ ខែមករា ឆ្នាំ២០១៣ តាមឯកសារ E223/3។

[០៩:១៤:៥៥]

ហើយដូចមានបញ្ជាក់នៅក្នុងអនុស្សរណៈសម្រាប់សវនាការនេះ គឺមានគោលបំណងពីរ។ ទី១ គឺអង្គជំនុំជម្រះនឹងស្តាប់ការពិភាក្សារបស់ភាគីទៅលើឯកសារទាំងឡាយដែលនៅសល់ និងដែលមិនទាន់បានដេញដោល។ ហើយទី២ គឺការបង្ហាញឯកសារនានា ដែលភាគី ឬក៏អង្គជំនុំជម្រះយល់ថា ពាក់ព័ន្ធបំផុតទៅនឹងសំណុំរឿង០០២/០១ ដែលឯកសារទាំងនោះ ធ្លាប់បានដេញដោលរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ។

បាទ មុននឹងបន្តកិច្ចដំណើរការនីតិវិធី សូមលោក ឌុច ផារី ក្រឡាបញ្ជីសវនាការឡើងរាយ-ការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះដែលកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។

លើកលែងតែជនជាប់ចោទ អៀង សារី វត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ ជនជាប់ចោទ នួន ជា និង ជនជាប់ចោទ ខៀវ សំផន អវត្តមាន ដោយមូលហេតុសុខភាព។ តែជនជាប់ចោទទាំងពីរ ដាក់បាននូវលិខិតលះបង់សិទ្ធិមានវត្តមានសម្រាប់សវនាការក្នុងការដេញដោលលើកឯកសារនេះ តាមរយៈឯកសារ E258/2 និងឯកសារ E223/4។ សូមអរគុណ។

[០៩:១៦:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។

បាទ មុននឹងចាប់ផ្តើមសវនាការ អង្គជំនុំជម្រះសូមរំឭកជម្រាបជូនថា តាមរយៈអនុស្សរណៈដែលអង្គជំនុំជម្រះបានចេញកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៣ សវនាការលើកឯកសារនេះ តាមពិតត្រូវបានៗគ្រោងធ្វើឡើង -- ធ្វើសម្រាប់នៅថ្ងៃទី១៨ រហូតដល់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ ឯកសារ E -- ២០១៣ ឯកសារ E236/4 ក៏ប៉ុន្តែដោយសារ ដូចខ្ញុំបានជម្រាបជូនអម្បាញ់មិញអ៊ីចឹង គឺស្ថានភាពសុខភាពជនជាប់ចោទមិនអាចអនុញ្ញាតឲ្យបន្តសវនាការស្តាប់សក្ខីកម្មសាក្សីបាននោះ អង្គជំនុំជម្រះបានសម្រេចផ្អាកក្នុងការស្តាប់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីកាលពីសប្តាហ៍មុននេះ ហើយបានសម្រេចលើកយកបញ្ហាឯកសារនេះ មកធ្វើសវនាការនៅក្នុងសប្តាហ៍នេះវិញ។ ហើយដោយសារនៅក្នុងដំណើរការសវនាការនេះ ជនជាប់ចោទចំនួនពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ទោះបីគាត់បាននិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ប៉ុន្តែរូបកាយរបស់គាត់ រូបកាយស្មារតីសមស្រប ហើយគាត់បានបង្ហាញនូវជំហរច្បាស់ក្នុងការលះបង់សិទ្ធិដែលចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ ដោយជាលាយលក្ខណ៍អក្សរផ្ញើជូនមកអង្គជំនុំជម្រះកាលពីថ្ងៃពីសុក្រសប្តាហ៍មុន។

[០៩:១៨:១៤]

ហេតុដូច្នេះ សវនាការដែលបានគ្រោងធ្វើនេះ ដើម្បីស្តាប់សក្ខីកម្ម -- អ៎! ដើម្បីធ្វើឲ្យខានតែបានទៅតាមស្ថានភាពជាក់ស្តែងនេះ គឺអង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តីទាំងពីរក្រុម គឺការពារក្តីលោក នួន ជា និងលោក ខៀវ សំផន ថាតើរហូតដល់ពេលនេះ តើមានបញ្ហាប្រែប្រួលអ្វីដែរឬទេ លើកូនក្តីរបស់លោក ចំពោះការលះបង់សិទ្ធិនៅក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ?

លោកមេធាវីការពារក្តីលោក នួន ជា?

**លោក វ៉ិចទ័រ កូប៉េះ**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មិនមានការប្រែប្រួលអ្វីកើតឡើងនោះទេ។ កូនក្តីខ្ញុំបានផ្តល់នូវការលះបង់សិទ្ធិ អនុញ្ញាតឲ្យមានការសវនាការលើឯកសារ។ ចំណែកស្ថានភាពសុខភាព គឺហាក់ដូចជាមានការថមថយ ប៉ុន្តែមិនមានអ្វីជាការប្រែប្រួលធ្ងន់ធ្ងរ ឬក៏ខ្លាំងក្លានោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[០៩:១៩:៥៣]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ពាក់ព័ន្ធនឹងស្ថានភាពលោក ខៀវ សំផន នោះ គឺមិនមានអ្វីប្រែប្រួលនោះទេ ពួកយើងបានជួបសួរសុខទុក្ខគាត់ ហើយគាត់បានបញ្ជាក់ថាគាត់បានលះបង់សិទ្ធិសម្រាប់តែបញ្ហាសវនាការឯកសារតែប៉ុណ្ណោះ។ ហើយខ្ញុំដឹងថាគាត់ទន់ខ្សោយហើយ ហើយគាត់អស់កម្លាំងខ្លាំងណាស់។ ដូច្នេះ យើងចាំព័ត៌មានបន្ថែមពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់គាត់។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយគាត់សុំលះបង់សិទ្ធិតែសម្រាប់សវនាការលើឯកសារនេះតែប៉ុណ្ណោះ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្តល់ព័ត៌មានចុងក្រោយពាក់ព័ន្ធទៅនឹងបញ្ហាសុខភាព និងការលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការលើឯកសារ។ ហើយអង្គជំនុំជម្រះសម្រេចធ្វើនៅពេលនេះ។ តែទោះបីជាយ៉ាងនេះក្តី ក៏អង្គជំនុំជម្រះសូមជម្រាបជូនដល់មេធាវីការពារក្តីទាំងពីរក្រុម គឺការពារក្តីលោក នួន ជា និងលោក ខៀវ សំផន ថា អង្គជំនុំជម្រះនឹងផ្តល់ជូនជនជាប់ចោទទាំងពីររូបក្នុងការធ្វើការកត់សម្គាល់លើឯកសារដែលនឹងដាក់ពិភាក្សានៅក្នុងសវនាការនេះ នៅក្នុងពេលណាមួយក្នុងពេលសមស្របប្រសិនបើកូនក្តីរបស់លោកមានបំណងធ្វើដូច្នេះ។

[០៩:២១:២០]

បាទ ជាបន្តអង្គជំនុំជម្រះ ដូចបានជម្រាបជូនបញ្ជាក់ នៅក្នុងអនុស្សរណៈរបស់ខ្លួនលេខ E258

អង្គជំនុំជម្រះនឹងស្តាប់ទឡ្ហីករណ៍ជំទាស់តវ៉ាដែលនៅសេសសល់ទាំងឡាយ ដែលមិនទាន់បានពិភាក្សាដេញដោល និងប្រភេទឯកសារដែលភាគីបានស្នើសុំដែលដាក់នៅក្នុងសំណុំរឿង០០២/០១។

ឯកសារដែលពាក់ព័ន្ធទាំងនោះគឺដែលមានយោងនៅក្នុងដីកាដំណោះស្រាយត្រង់កថាខណ្ឌដែលពាក់ព័ន្ធទៅនឹងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងការផ្លាស់ប្តូរទីលំនៅប្រជាជន នៅកថាខណ្ឌ ២០៥ ដល់ ២០៩, ១៣៨៧ ដល់ ១៣៨៩, ១៤១៥ -- សូមទោសសុំកែសម្រួលឡើងវិញ-- កថាខណ្ឌ ២០៥ ដល់២០៩, កថាខណ្ឌ៦៩៨ ដល់ ៧១១, កថាខណ្ឌ ៩៧៥ ដល់៩៧៧, កថាខណ្ឌ ១១០៥ ដល់ ១១១៣, កថាខណ្ឌ ១១៩១ ដល់១១៩៣, កថាខណ្ឌ ១៣៧៣, ១៣៧៥, ១៣៧៧, ១៣៧៩ ដល់ ១៣៨១។ កថាខណ្ឌ ១៣៨៧ ដល់១៣៨៩, កថាខណ្ឌ ១៤១៥ ដល់១៤១៨, កថាខណ្ឌ១៤២៣ ដល់កថាខណ្ឌ១៤២៥។

ក្រៅពីនេះអង្គជំនុំជម្រះហ្នឹងស្តាប់ការលើកឡើងទឡ្ហីករណ៍ជំទាស់តទៅទៅនឹងឯកសារចំនួន៤៨ ដែលតំណាងសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលឯកសារមិនពាក់ព័ន្ធទៅនឹងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងការផ្លាស់ប្តូរទីលំនៅប្រជាជន និងឯកសារចំនួន៩៥ទៀតរបស់តំណាងសហព្រះរាជអាជ្ញាដែលពាក់ព័ន្ធទៅនឹងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងផ្លាស់ទីលំនៅប្រជាជន។ អង្គជំនុំជម្រះសូមបញ្ជាក់ថាភាគីផ្សេងៗឯទៀត មិនបានស្នើសុំដាក់ឯកសារដើម្បីសុំប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះទេ។

[០៩:២៣:៤០]

ហើយគោលបំណងនៃការសវនាការ និងការបង្ហាញឯកសារនេះមិនមែនដើម្បីបើកការជជែកវែកញែកជាថ្មី ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារណាមួយដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។ ដូចដែលអង្គជំនុំជម្រះបានធ្លាប់បញ្ជាក់កាលពីពេលមុនៗរួចមកហើយថា នៅពេលកន្លងមកឯកសារជាច្រើនដែលត្រូវបានលើកឡើង នឹងចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឯកសារ E3 គឺមានសារៈសំខាន់ ប៉ុន្តែនៅក្នុងកិច្ចពិភាក្សាដេញដោលជាក់លាក់នៅក្នុងសវនាការនោះ ឯកសារទាំងនោះមិនបានអាចឲ្យសាធារណជនទទួលព័ត៌មានគ្រប់គ្រាន់ទាំងអស់នោះបានទេ។ ហើយបន្ថែមពីលើនេះទៀតដោយសារឯកសារដែលបានទទួលស្គាល់រួចហើយ ដែលមានចំនួនច្រើន ដែលបានដាក់ដោយភាគីនានានៅពេលសវនាការកន្លងមកនោះ ហេតុដូច្នេះ វាជាការប្រសើរណាស់សម្រាប់អង្គជំនុំជម្រះក្នុងការទទួលបាននូវការបញ្ជាក់ពីភាគីនៅចំនួនឯកសារក្នុងកម្រិតមួយជាក់

លាក់។ ឯកសារដាក់បន្ទុក ឯកសារដោះបន្ទុកដែលពាក់ព័ន្ធ ហើយដែលរហូតមកដល់ពេលនេះភាគីមិនទាន់បានលើកយកមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:២៤:៥១]

ការបង្ហាញភស្តុតាងនេះ ផ្តោតជាសំខាន់ទៅលើឯកសារទាំងឡាយដែលភាគីយល់ថា មានភាពពាក់ព័ន្ធបំផុតទៅនឹងការបញ្ជាក់ការពិតក្នុងសំណុំរឿង០០២/០១ ដែលពាក់ព័ន្ធទៅនឹងផ្នែកនៃអង្គហេតុទាំងអស់ដែលមិនទាន់បានដេញដោលក្នុងសំណុំរឿង០០២/០១ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។ កន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ រចនាសម្ព័ន្ធយោធា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

បាទ ជាបន្តទៅទៀត អង្គជំនុំជម្រះសូមសួរទៅតំណាងសហព្រះរាជអាជ្ញាថា តើក្នុងការដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះនេះ តើតំណាងសហព្រះរាជអាជ្ញាមានបំណងធ្វើដូចម្តេចដែរ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ និងជម្រាបសួរសាធារណជន។ តាមពិតនោះអ្វីដែលយើងស្នើឡើងនោះ គឺថាយើងចង់ជជែកពិភាក្សាតែទៅលើការទទួលយកឯកសារតែប៉ុណ្ណោះនៅពេលព្រឹកនេះ គឺឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ១, ២, ក, ខ, គ ។ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ នោះ យើងបានបញ្ជូនឯកសារ គឺឯកសារ--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យសហព្រះរាជអាជ្ញាអានលេខម្តងទៀត។

[០៩:២៦:៣៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

--ឯកសារនោះ គឺលេខ E223/2.1.1 ហើយឧបសម្ព័ន្ធ២(ក) នោះ គឺ E223/2/1.2 ហើយនិងឯកសារឧបសម្ព័ន្ធ២(គ) -- និង២(ខ) និង២(គ) នោះ ដូចគ្នាដែរ។ ប៉ុន្តែបញ្ចប់ទៅដល់1.2 ទៅដល់ 4 គឺមានន័យថា E223/2/1.2 ទៅដល់ចុច 4។

កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ នោះ គឺថាមានតែពួកយើងទេ ដែលបានឆ្លើយតបចំពោះអង្គជំនុំជម្រះដែលថា ឯកសារបន្ថែមណាខ្លះដែលយើងចង់ដាក់ចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ ហើយនិងទួលពោធិ៍ជ្រៃ។

[០៩:២៧:៤០]

តារាងនោះ គឺមាននៅក្នុងឧបសម្ព័ន្ធ២(ក), (ខ), (គ) គឺមានន័យថា ៩៤ឯកសារ ដែលត្រូវបាន បែងចែកជាតារាងបី។ តារាងដំបូងនោះ ពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ ហើយទី២នោះ ការជម្លៀសដោយបង្ខំ ដំណាក់កាលទី២។ ហើយទី៣ ទួលពោធិ៍ជ្រៃ។ នៅក្នុងការឆ្លើយទៅតបទៅនឹង អង្គជំនុំជម្រះនោះ យើងបានផ្តួចផ្តើមគំនិតក្នុងការបញ្ចូលឧបសម្ព័ន្ធមួយដែលពាក់ព័ន្ធទៅនឹងឯកសារ ៤៨ ដែលបើតាមយើងនោះ គឺថាឯកសារទាំងអស់ហ្នឹង គឺថាមិនទាន់បានជជែកដេញដោលនៅចំពោះ មុខពាក់ព័ន្ធទៅនឹងភាពទទួលយកបានន័យឯកសារទាំងអស់នោះនៅឡើយទេ។

លើកលែងតែអង្គជំនុំជម្រះស្នើសុំនោះ ខ្ញុំគិតថា យើងមិនចាំបាច់បញ្ជាក់អំពីឯកសារនោះទេ។ ក៏ប៉ុន្តែឯកសារផ្សេងទៀតនោះ គឺថាបានធ្វើសវនាការជាសាធារណៈហើយកាលពីខែមករា កុម្ភៈ មីនា ឆ្នាំ២០១២ ហើយឯកសារទាំងអស់នោះ គឺមាននៅក្នុងឧបសម្ព័ន្ធ១ ទៅដល់១១ ហើយនិង១៤ ទៅដល់ ២០ នៃឯកសារដែលខ្ញុំនឹងរកមើលលេខ។ គឺថាលេខ E109/4 គឺកាលពីឆ្នាំ២០១១ ដែលស្ថិតនៅក្នុង តារាងរបស់សហព្រះរាជអាជ្ញា។ កាលពីសប្តាហ៍មុនមានការឆ្លងឆ្លើយគ្នាតាមអ៊ីម៉ែលរវាងខាងភាគី ហើយនិងមន្ត្រីច្បាប់ពាក់ព័ន្ធទៅនឹងឯកសារទាំង៤៨ នោះ។ ហើយឯកសារ៤៤៤ នោះ គឺថាវាមាននៅ ក្នុងឧបសម្ព័ន្ធ១ ដល់១២ ហើយនិង១៤ ទៅដល់២០ គឺថាមានឯកសារខ្លះអាចពិភាក្សាដេញដោលរួច មកហើយ ក៏ប៉ុន្តែបើសិនបើមានការស្នើសុំនោះ យើងនឹងអាចពន្យល់បាន។

[០៩:២៩:៤៤]

ពាក់ព័ន្ធទៅនឹងឯកសារ៤៨ នោះ គឺថាមានឯកសារពីរ ដែលបានដាក់នៅក្នុងជើងទំព័រនៃដីកា ដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ ហើយនិងទួលពោធិ៍ជ្រៃ។ ហេតុអ្វីបានជា មានតែពីរឯកសារ? ព្រោះថាយើងបានប្រៀបធៀបឯកសារមួយម្តងៗទៅនឹងឯកសារដែលមាននៅក្នុង កំណត់សម្គាល់ជើងទំព័រនៃកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយនោះ។ ហើយយើងពិនិត្យឃើញថា ឯកសារស្ទើរតែទាំងអស់ទៅហើយ មាន -- លើកលែងតែពីរនោះទេ ដែលមានលេខ E3 នោះ។ បន្ទាប់ពីមានការពិភាក្សាគ្នាទៅលើឧបសម្ព័ន្ធ១ ដល់១១ ហើយនិង១៤ ទៅដល់២០ កាលពីឆ្នាំមុននោះ។

ដូច្នេះ ឯកសារទាំងអស់នោះគឺថា ត្រូវបានចាត់ទុកថាជាឯកសារនៅសម័យនោះ ហើយត្រូវបាន ពិភាក្សាដេញដោលគ្នារួចទៅហើយ ហើយក៏ប៉ុន្តែមិនទាន់មានការផ្តល់ -- មិនទាន់មានសេចក្តីសម្រេច ពាក់ព័ន្ធទៅនឹងឯកសារនោះទេ។ ប្រសិនបើចាំបាច់នោះ ខ្ញុំអាចផ្តល់ការពន្យល់បន្ថែម។ ហើយខ្ញុំអាច

សង្ខេបដោយខ្លីអំពីអ្វីដែលយើងធ្វើ។

[០៩:៣១:០០]

ក្រៅពីឯកសារពីរដែលមាននៅក្នុងជើងទំព័រនោះ គឺថាមានឯកសារដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ ឯកសារបី ស្នើដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយចំពោះឯកសារទាំងអស់នោះ គឺថាអាចខាងមេធាវីការពារក្តីគាត់ចាប់ផ្តើម ហើយនិងបន្ទាប់មកនឹងមានការជំទាស់ ហើយនិងមានឯកសារ៩៤ផ្សេងទៀតដែលយើងស្នើដាក់បញ្ចូល ពាក់ព័ន្ធទៅនឹងការជម្លៀស និងទួលពោធិ៍ជ្រៃ។ ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ១នោះ គឺយើងបានធ្វើជាតារាង ហើយមានឯកសារមួយចំនួនត្រូវបានស្នើឡើងខាងមេធាវីការពារក្តី ហើយមិនទាន់មានការជជែកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយនោះទេ។ ហើយនៅក្នុងចំណោមនោះមានឯកសារបួន ដែលត្រូវបានស្នើឡើងដោយមេធាវីការពារក្តី អៀង សារី។ ប្រសិនបើខ្ញុំមិនច្រឡំនោះទេ មាន២១ស្នើឡើងដោយខាងមេធាវីការពារក្តី ខៀវ សំផន។ ហើយខ្ញុំសូមបញ្ជាក់ថា សហព្រះរាជអាជ្ញាធ្វើការជំទាស់ទៅលើឯកសារបួនក្នុងចំណោមឯកសារទាំង២១នេះ។ ហើយឯកសារផ្សេងទៀតនោះត្រូវបានស្នើឡើងដោយក្រុមមេធាវីការពារក្តី នួន ជា គឺមាន ១១ឯកសារ។ សហព្រះរាជអាជ្ញានឹងជំទាស់ទៅលើឯកសារបួនក្នុងចំណោមឯកសារទាំង១១ របស់ខាង នួន ជា។

[០៩:៣២:៣៨]

ដោយសារតែសហព្រះរាជអាជ្ញាជាអ្នកស្នើឯកសារជាច្រើននៅក្នុងឧបសម្ព័ន្ធនោះ យើងសូមឲ្យខាងមេធាវីការពារក្តីងើបឡើង ហើយនិងប្រាប់អង្គជំនុំជម្រះថា តើពួកគាត់ជំទាស់ទៅនឹងឯកសារណាខ្លះដែលយើងបានស្នើដាក់នោះ ហើយបន្ទាប់មកទៀត យើងខ្ញុំនឹងឆ្លើយតបទៅនឹងការជំទាស់របស់តំណាងសហមេធាវីការពារក្តី។ ហើយបន្ទាប់មកទៀត យើងនឹងឡើងអំពីការជំទាស់របស់យើងពាក់ព័ន្ធទៅនឹងឯកសាររបស់មេធាវីការពារក្តីម្តង។ ដូច្នេះដើម្បីឲ្យមានលក្ខណៈងាយស្រួល ជាលក្ខណៈល្អប្រសើរនោះ យើងសុំឲ្យមានការជំទាស់ទៅលើឯកសារទាំង ៤៨សិន ហើយបន្ទាប់មកទៀតនឹងមានការជំទាស់ទៅលើឯកសារជាង៩០ផ្សេងទៀត ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។

នេះជាគោលជំហររបស់យើងលោកប្រធាន គឺថាសូមឲ្យខាងមេធាវីការពារក្តី គាត់លើកឡើងនូវការជំទាស់របស់គាត់សិន។ បន្ទាប់មកយើងនឹងលើកនូវការជំទាស់របស់យើងនៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[០៩:៣៣:៥៤]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបំភ្លឺអំពីគោលជំហរនៃក្រុមរបស់យើងពាក់ព័ន្ធទៅនឹងសវនាការនេះ។ ដូចយើងបានបញ្ជាក់ហើយនៅក្នុងការឆ្លើយឆ្លងគ្នាតាមអ៊ីម៉ែលនោះ គឺថាសវនាការនេះធ្វើឡើងលឿនពេក គឺថាវាលឿនជាងអ្វីដែលយើងបានគិតទុកជាមុន។ ដូច្នេះយើងខ្ញុំមានការលំបាកណាស់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ទៅលើបញ្ជីឯកសារដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ យើងគិតថា គ្មានអ្នកណាដែលថាមិនអាចខុសនោះទេ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យើងស្វាគមន៍ចំពោះការបញ្ជាក់របស់មន្ត្រីច្បាប់ជាន់ខ្ពស់ដែលបានលើកឡើងថា គឺថាជាការពិភាក្សាទៅលើឯកសារ ហើយនិងមានការ-- ហើយៗការពិភាក្សានេះមិនមែនជាគេការពិភាក្សាចុងក្រោយបំផុតនោះដែរ។ ហើយយើងពិភាក្សានោះ គឺថាទៅលើឯកសារ៤៨នោះ គឺថាយើងនឹងពិភាក្សាទៅលើការអាចទទួលយកបាននៃឯកសារ។ ដូច្នេះ នេះដើម្បីបញ្ជាក់ថាកុំឲ្យពេលក្រោយថាៗយើងមិនបានលើកឡើងអំពីជំទាស់ទៅលើភាពមិនអាចទទួលយកបាននោះ។

ពាក់ព័ន្ធទៅនឹងការចំណុច -- បង្ហាញចំណុចឯកសារនេះ ខ្ញុំសូមបញ្ជាក់ថាអ្វីដែល -- គឺថាសហព្រះរាជអាជ្ញាបានបញ្ជាក់រួចអម្បាញ់មិញហើយ គឺថាមាន -- គឺថាមានឯកសារ៥០០ ហើយបន្ទាប់មកមានការបន្ថយមកនៅត្រឹមតែ៤៨ ដោយគាត់គិតថាមានការពិភាក្សាគ្នារួចមកហើយ នៅក្នុងឧបសម្ព័ន្ធ១ទៅដល់១៤ ដើម្បីបង្ហាញពីគោលជំហររបស់យើងនោះគឺថា នៅក្នុងសេចក្តី E72/5 អង្គជំនុំជម្រះបានបញ្ជាក់ថាឯកសារថ្មីនឹងត្រូវពិភាក្សាគ្នានៅពេលក្រោយ។ ហើយឯកសារពាក់ព័ន្ធទៅនឹងកំណត់ហេតុនោះគឺថាមានលេខ E1/47.1 នោះ យើងបាន -- អង្គជំនុំជម្រះមានការលើកពេលសម្រាប់ការពិភាក្សាគ្នានៅចំពោះឧបសម្ព័ន្ធ៦ ទៅដល់ ២០។

[០៩:៣៦:៤៧]

ខ្ញុំសូមបញ្ជាក់ថា គឺថា E1/47.1។ លោកមេធាវី គង់ សំអុន បានបញ្ជាក់ហើយថាឧបសម្ព័ន្ធ៦ទៅដល់ ២០នោះ គឺថាមានលើកឡើងអំពីឯកសារថ្មី ហើយនិងមានការពិភាក្សាគ្នានៅពេលក្រោយ។ ដូច្នេះ ក្នុងលក្ខខណ្ឌបែបនេះយើងខ្ញុំមិនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់សវនាការថ្ងៃនេះក្នុងការពិនិត្យ

មើលឯកសារមួយម្តងៗ ជាពិសេស យើងមិនអាចធ្វើការជំទាស់បានសមស្របពីខាងមេធាវីការពារក្តី លោក ខៀវ សំផន។

ហើយចំណុចទី២ យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ E185/1 កាលពីថ្ងៃ០៣ ធ្នូ ខែ -- ២០១២ ដែលអង្គជំនុំជម្រះបញ្ជាក់ថាយើងអាចពិភាក្សាអំពីភាពទទួលយកបាននៃឯកសារមួយចំនួន យ៉ាងម៉េច យ៉ាងដូចម្តេច? ហើយអង្គជំនុំជម្រះបានបញ្ជាក់ថា គឺថាមានវិធីសាស្ត្រផ្សេងពីតុលាការអន្តរជាតិផ្សេងទៀតពាក់ព័ន្ធទៅនឹងការទទួលយកឯកសារ។ ហើយការពិភាក្សានោះគឺថាមានបញ្ហាទៅលើតម្លៃជាភស្តុតាងនៃឯកសារ។ ក៏ប៉ុន្តែនៅក្នុងដំណាក់កាលនោះ ដំណាក់កាលនេះ យើងខ្ញុំសូមបញ្ជាក់ថា -- នេះមានន័យថា បន្ទាប់ពីការបង្ហាញឯកសារភស្តុតាងអស់ហើយនោះ គឺថាយើងនឹងមានការពិភាក្សាទៅលើតម្លៃជាភស្តុតាងមួយទៀត ដើម្បីឲ្យអង្គជំនុំជម្រះនៅពេលដែលធ្វើការពិភាក្សាសម្រេចនោះ យល់ច្បាស់អំពីគោលជំហរបស់ភាគីទាំងអស់អំពីតម្លៃជាភស្តុតាងនៃឯកសារ។

ដូច្នេះ យើងមិនអាចថាមិនធ្វើបែបនេះបានទេ។ ហើយខាងមេធាវីការពារក្តី ខៀវ សំផន យើងខ្ញុំសូមលើកឡើងនូវចំណុចនេះនៅថ្ងៃនេះ។ សូមអរគុណលោកប្រធាន។

[០៩:៣៩:០២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤០:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តនេះអង្គជំនុំជម្រះសុំផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបង្ហាញនូវឯកសារទាំង៤៨ ដែលសហព្រះរាជអាជ្ញាបានស្នើសុំពាក់ព័ន្ធជាមួយនឹងឯកសារនេះជាមុនសិនបាទ។

[០៩:៤១:១៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:៥១]

**ប្រធានអង្គជំនុំ៖**

បាទ ដោយមានការពិភាក្សាជាថ្មី ដើម្បីភាពច្បាស់លាស់នូវបញ្ហានេះ អង្គជំនុំជម្រះសុំប្រគល់ភារៈជូនទៅលោកស្រីក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីជម្រាបជូនទៅភាគីជ្រាបអំពីកិច្ចពិភាក្សាដេញ

ដោលដែលនឹងធ្វើនាពេលនេះ។ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានឯកភាពថា វិធីល្អបំផុតត្រូវដំណើរនេះគឺយើងត្រូវផ្តោតលើឯកសារចំនួន៤៨ ជាមុនសិន ដែលសហព្រះរាជអាជ្ញាបានបញ្ជាក់និងស្នើឡើង។ ហើយរបៀបដែលសវនាការដំណើរនៅក្នុងថ្ងៃនេះ នោះគឺតាមរបៀបដូច្នេះ ដំបូងសហព្រះរាជអាជ្ញានឹងលើកឡើងអំពីឯកសារទាំងអស់នោះ ដើម្បីធ្វើជាប្រតិចារឹក ក៏ប៉ុន្តែមិនត្រូវធ្វើយោបល់បន្ថែមណាមួយផ្សេងនោះទេ។ បន្ទាប់មកយើងផ្តល់វេទិកាទៅដល់មេធាវីការពារក្តី ដែលក្រុមនីមួយៗនឹងមានឱកាសធ្វើការជំទាស់ចំពោះឯកសារណាមួយក្នុងចំណោមឯកសារទាំង៤៨នោះ។ ហើយប្រសិនបើមិនមានការជំទាស់ទេ យើងទុកមួយ-- ឯកសារនោះមួយឡែក។ បន្ទាប់មកតំណាងសហមេធាវីនាំមុខ នឹងមានឱកាសឆ្លើយតបទៅនឹងការជំទាស់ណាមួយដែលលើកឡើងដោយក្រុមមេធាវីការពារក្តីនីមួយៗ។ ដូច្នេះ សវនាការឯកសារនៅក្នុងថ្ងៃនេះយើងផ្តោតសំខាន់លើឯកសារចំនួន៤៨ ដែលសហព្រះរាជអាជ្ញាជាអ្នកលើកឡើង។ ដូច្នេះ លោកប្រធានខ្ញុំគិតថាអ្វីដែលខ្ញុំលើកឡើងនេះ គឺបានក្តោបរួមទៅលើយោបល់ដែលលោកប្រធានបានលើកឡើង។ សូមអរគុណលោកប្រធាន។

[០៩:៤៥:៥១]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ដើម្បីបន្ថែមទៅលើអ្វីដែលលោកស្រី ខាតវ៉ាយថ៍ បានមានប្រសាសន៍អំបាញ់មិញនេះ ខ្ញុំចង់រំឭកថាមានការជំទាស់ប្រាំបីដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាទៅលើឯកសារ។ ឯកសារនោះគឺថាមិនមែនសហព្រះរាជអាជ្ញាជាអ្នកស្នើឡើងទេ គឺថាយើងមានការជំទាស់បួន ទៅលើឯកសារដែលបង្ហាញឡើងដោយមេធាវីការពារក្តី ខៀវ សំផន ហើយនិងបួនដែលលើកឡើងដោយមេធាវីការពារក្តី នួន ជា។ ដូច្នេះ ខ្ញុំចង់ឲ្យខាងមេធាវីការពារក្តីគាត់ឆ្លើយតបទៅនឹងការជំទាស់នៅពេលក្រោយ។ ឯកសារទាំង៤៨នោះ គឺថាមកពីកំណត់សម្គាល់ជើងទំព័រនៃដីកាដំណោះស្រាយគឺឯកសារ ES5.380 ដែលជាចម្លើយសារភាពរបស់ឈ្មោះ មូល សំបាត់ ហៅ រស់ ញឹម ចុះថ្ងៃទី១៤ មិថុនា ឆ្នាំ ១៩៧៨។ ខ្ញុំសូមអានឯកសារនេះ ហើយបន្ទាប់មកនឹងមានការជំទាស់។ ឯកសារទីពីរ

នោះ គឺជាឯកសាររបាយការណ៍ភូមិសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ គឺឯកសារលេខ D125/217 ហើយនៅក្នុងឯកសារនោះ គឺមាននៅក្នុងជីកាដំណោះស្រាយ គឺនៅក្នុងកំណត់ជើងទំព័រ3025។ បន្ទាប់មកទៀត មានប្រាំមួយឯកសាររបស់សហព្រះរាជអាជ្ញា។ ឯកសារទី១ នោះ គឺឯកសារ E216/3.1 ឯកសារនេះគឺជាការដកស្រង់នូវសៀវភៅសរសេរដៃផ្សេងៗទាក់ទងទៅនឹងប្រវត្តិរូបរបស់ សួង ស៊ីគឿន ហើយសំណើហ្នឹងគឺជាសំណើរបស់សហព្រះរាជអាជ្ញាដែលមានលេខ E216។ ឯកសារមួយទៀតគឺសៀវភៅរបស់ ថេត សម្បត្តិ ដែលមានលេខ E152.2 ដែលមានចំណងជើងថា "នៅក្រោយវាលពិឃាដ"។ បន្ទាប់មកទៀតមានភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់ ឡុង ណារិន ហៅ រិទ្ធ ដែលមានលេខកូដ E3/218 សុំទោស គឺ E3/128។

[០៩:៤៩:៤៥]

ឯកសារមួយទៀតគឺនៅក្នុងឧបសម្ព័ន្ធមួយគឺថាជាខ្សែវីដេអូសម្ភាសលោក ខៀវ សំផន គឺឃ្លីបវីដេអូ៥៤ ដែលមានលេខដូចតទៅនេះ E152.1.1R រហូតទៅដល់ E152/1.1.54R គឺថាឯកសារនេះមានជាការសម្ភាសបន្តបន្ទាប់គ្នា ហើយបន្ទាប់មកមានប្រតិចារឹកនៃឃ្លីបវីដេអូនេះ ប្រតិចារឹកនេះត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដែលមានលេខ E125.2.1.1 រហូតទៅដល់ E152.1.54។ ឯកសារបន្តទៅទៀតនេះក៏ជាឃ្លីបវីដេអូដែរ។ វីដេអូទី១នោះ គឺធ្វើឡើងនៅក្នុងសន្និសីទកាសែតរបស់លោក ខៀវ សំផន និង នួន ជា នៅឆ្នាំ១៩៩៨ ដែលមានលេខពីរ គឺលេខ A190/1/15R សម្រាប់អ្នកបកប្រែនោះ គឺថា ខ្ញុំនិយាយទៅតាមឯកសារដែលមាន E223/2.1.1។ ប្រសិនបើអ្នកបកប្រែមានឯកសារនេះនៅមុខនោះ គឺថាមានភាពងាយស្រួល។

ហើយបន្ទាប់មកទៀតគឺមានសម្រង់ខ្សែវីដេអូ ដែលធ្វើឡើងដោយ ថេត សម្បត្តិ ដែលបានសម្ភាសលោក នួន ជា ដែលមានលេខ E93/7.3R។ ឯកសារនេះក៏មានជាប្រតិចារឹកដែរ ប្រតិចារឹកនៃការសម្ភាស គឺមានលេខ E93/7.2R។ ពាក់ព័ន្ធនឹងឯកសារបីដែលលើកឡើងដោយតំណាងដើមបណ្តឹងរដ្ឋប្បវេណី យើងសូមលើកឡើងនូវសៀវភៅរបស់លោក វ៉ាអ៊ីល ម៉ាកចេនណា ដែលមានចំណងជើងថា "ខៀវ សំផន និងខ្មែរក្រហម" ដែលមានលេខកូដ E109/2.3.1។

[០៩:៥២:៥៧]

បន្ទាប់មកទៀតមានខ្សែភាពយន្តឯកសារ ដែលធ្វើឡើងដោយ រ៉ូសាន ដែលមានចំណងជើងថា "ការត្រដររស់នៅក្នុងរបបខ្មែរក្រហម"។ ហើយខ្ញុំគិតថាមានការភ័ន្តច្រឡំ -- មានការច្របូកច្របល់

បន្ថិចពាក់ព័ន្ធនឹងឯកសារនេះ គឺមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលថានៅក្នុងតារាងនោះគឺថាមានកំហុស។ តាមពិតទៅគឺឯកសារហ្នឹងលេខ E109/2.3R នោះទេ។

ខ្ញុំគិតថា ឯកសារហ្នឹងគឺថាមានការភ័ន្តច្រឡំ តាមពិតទៅប្រហែលជាមានលេខ E101/2.3R ហើយខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចបញ្ជាក់អំពីចំណុចនេះបាន។ ឯកសារដែលស្នើឡើងដោយសហព្រះរាជអាជ្ញា និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺជាខ្សែភាពយន្តឯកសារ ដែលមានចំណងជើងថា“សត្រូវប្រជាជន” ដែលធ្វើឡើងដោយ ថេត សម្បត្តិ ដែលមានខ្សែភាពយន្តនេះផ្ទាល់តែម្តង។ ឯកសារនេះគឺមានលេខ E186/1R។ បន្ទាប់មកទៀតមានបួនឯកសារដែលលើកឡើងដោយខាងមេធាវីការពារក្តី អៀង សារី គឺទី១ សៀវភៅរបស់ ដេវីដ ឆេនដ័ល័រ, សៀវភៅនោះគឺមានលេខ D172.6។

[០៩:៥៥:០០]

បន្ទាប់មកទៀត គឺសៀវភៅរបស់លោក ម៉ៃខល វីកឃើរី ដែលមានចំណងជើងថា “*ឌីម៉ូក្រាទិក កម្ពុជា៖ ហ្វឹម អេន វ៉ារីអេសិន*” ដែលមានលេខ E190.1.407។ បន្ទាប់មកទៀត គឺសៀវភៅរបស់ មីលតុន អូស្បន (Milton Osborne) ដែលមានចំណងជើងថា “*សីហនុ៖ ព្រីន អូហ្វ ឡៃហ្វ, ព្រីន អូហ្វ ដាកណេស*” ដែលមានលេខ E190/2.2។ ឯកសារចុងក្រោយដែលស្នើឡើងដោយលោក អៀង សារី គឺជាអត្ថបទកាសែត ដែលនិពន្ធដោយ ដូក្លាស ហ្គីលសុន ហើយនិង ហ៊ ដែលមានចំណងជើងថា “*វ៉នហេនដ្រិត- សេវេនធីសេវេន វីលីស ហ្វ្រម អេស-ថ្វេនធីវ៉ន, ដុក ឌី.ស៊ី.ខេម*” ឯកសារ គឺ D22/205.2.1។ បន្ទាប់មកទៀត មានឯកសាររបស់លោក ខៀវ សំផន ឯកសារដំបូងនោះ គឺជាអត្ថបទជាភាសាអង់គ្លេស ដែលនិយាយថា -- ដែលមាន “*ប៉ុមស៍ អូវ៉រ ខេមបូឌា*” ឯកសារនេះមានលេខពីរ។

[០៩:៥៦:៥៣]

ឯកសារលេខទី១នោះ គឺថាមាន E190/2.6, D153.12 ដែលជាសំណើត្រូវបានកែប្រែ ហើយនិងដាក់បញ្ចូលបន្ថែមនៅឆ្នាំ២០០៩។ ឯកសារទី២ របស់មេធាវីការពារក្តីលោក ខៀវ សំផន នោះគឺជាសៀវភៅរបស់លោក ប៊ែន ឃៀរនិន ដែលមានលេខកូដ E190/2.10 ឯកសារនេះគឺថាមាននៅក្នុងតារាងដែលផ្តល់ជូនដោយអង្គជំនុំជម្រះ។ សៀវភៅនេះមានចំណងជើងថា “*យូ.អេស ប៉ុមបាតដ៍មិន អូហ្វ ខេមបូឌា៖* ឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧៣, ជំនាន់វៀតណាម”។ ឯកសារនេះ គឺថា នឹងចុះឆ្នាំ១៩៨៧។

ឯកសារមួយទៀតដែលមានចំណងជើងថា “*ឌីខេត អូហ្វ ឌី ដេណូសាយ*” ដែលមានលេខ

E190/2.11។ បន្ទាប់មកទៀត គឺមានការទំនាក់ទំនងអន្តរជាតិដែលចេញមកពីក្រសួងការបរទេសអាមេរិក។ ឯកសារដំបូងនោះ គឺ E190/2.13 ដែលជាប្រតិចារឹកនៃការសន្ទនាគ្នារវាង និចសុន និង ឃីស៊ីងហ្គ័រ(Kissinger) នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧០។ នៅថ្ងៃដដែលនោះដែរ គឺមានឯកសារចេញពីមកក្រសួងការបរទេសអាមេរិក គឺ E190/2.14។

[០៩:៥៩:១៤]

ឯកសារនេះ គឺជាប្រតិចារឹកនៃកិច្ចសន្ទនារវាង ឃីស៊ីងហ្គ័រ និងឧត្តសេនីយ៍ ហេក។ បន្ទាប់មកទៀត គឺឯកសារ E190/2.16 ចុះឆ្នាំ១៩៧៥ ដែលជាអនុស្សរណៈនៃកិច្ចសន្ទនារវាងប្រធានាធិបតីឥណ្ឌូនេស៊ី ស៊ូហាតូ និងលោក ហ្វត និង ឃីស៊ីងហ្គ័រ។ ឯកសារបន្ទាប់មកទៀតរបស់ក្រសួងការបរទេស គឺ E190/2.15 ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលជាអនុស្សរណៈនៃកិច្ចសន្ទនារវាងលោក ឃីស៊ីងហ្គ័រ ហើយនិងលោករដ្ឋមន្ត្រីក្រសួងការបរទេសថៃ ឆាត ឆៃ។ បន្ទាប់មកទៀត យើងមានឯកសារ E190.1.408។ ឯកសារនេះគឺជាកំណត់សម្គាល់របស់អ្នកការទូតបារាំងមួយរូបដែលមានចំណងជើងថា “កិច្ចសន្ទនាជាមួយលោក ពេជ លឹមគួន នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦” ដែលចេញមកពីក្រសួងការបរទេសបារាំង។

បន្ទាប់មកទៀត គឺឯកសារដែលជា-- នៃមហាសន្និបាតអង្គការសហប្រជាជាតិដែលមាន E190/2.9 ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៩ ដែលជាសេចក្តីសម្រេចរបស់មហា សន្និបាតអង្គការសហប្រជាជាតិនៅកិច្ចប្រជុំលើកទី៣៤ ពាក់ព័ន្ធទៅនៅស្ថានភាពនៃប្រទេសកម្ពុជា។ បន្ទាប់មកទៀត យើងមានអត្ថបទសារព័ត៌មានអន្តរជាតិមួយចំនួន។ ទី១នោះគឺមានលេខ E190/2.17 ដែលចេញមកពី ណមឆមស្តី នៃញូវយ៉ក រីវីយូ អូហ្វ ប៊ុកស៍, ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧០ ដែលនិយាយអំពីប្រទេសកម្ពុជានៅក្នុងលេខពិសេស។

[១០:០១:៤៧]

បន្ទាប់មកទៀត យើងមានអត្ថបទរបស់ទីភ្នាក់ងារសារព័ត៌មានបារាំង ដែលមានចំណងជើងថា “ការមកដល់នៃគណៈប្រតិភូឡាវ ដែលមកទស្សនកិច្ចនៅកម្ពុជា” ឯកសារនៃចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៥ ដែលមានលេខ E190.1.412។ ក្រោយមកទៀត អត្ថបទរបស់សារព័ត៌មានថាមស៍ ចុះថ្ងៃទី០៤ ឧសភា ឆ្នាំ១៩៧៦ ដែលមានលេខកូដ E190/-- សូមទោស E190.1.411។ អត្ថបទនេះមានចំណងជើងថា “*ឌីហ្វិកធីង ខ្មែរ-រូស ហេលីកូផ័រ ពីឡុត ថែល អូហ្វ ឡៃហ្វ អ៊ីន ភ្នំពេញ*”។ បន្ទាប់មកទៀត មានអត្ថបទ

សារព័ត៌មានរបស់ ហេរ៉លដ៍ ទ្រីប៊ូន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៦ ដែលមានលេខកូដ E190.1.409 អត្ថបទនេះមានចំណងជើងថា "*អេសស្កេប ប៊ិខស អូហ្វ ខ្មែរ ប្រ៊ូថលលីធី*"។ អត្ថបទមួយទៀតដែលចុះផ្សាយដោយសារព័ត៌មានញូវរីក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ ដែលមានលេខកូដ E190.1.410 ដែលមានចំណងជើងថា "*ខេមបូឌា៖ ធូ វីយូ ប្រម អ៊ិនសាយ*"។ ចុងក្រោយគឺឯកសារនៃសារព័ត៌មានអន្តជាតិដែលមានលេខកូដ E190/2.8 ដែលជាអត្ថបទរបស់ វីល្លៀម សក្រូស (William Shawcross) នៅក្នុងទស្សនាវដ្ដី "ហ្វាអ៊ីស វីវ៉ីយូ អេកូណូមិក" អត្ថបទនេះមានចំណងជើងថា "*ខេមបូឌា៖ ឌី វើឌិក អ៊ិស្ដ ហ្គាលធី អូហ្វ និចសុន អេន ឃីស៊ីងហ្គ័រ*"។ បន្ទាប់មកទៀតមានលិខិត ឬក៏សក្ខីកម្មប្អូន ដែលសហព្រះ រាជអាជ្ញាសូមជំទាស់។ ដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញរួចមកហើយ។

[១០:០៤:០៧]

ឯកសារទី១ នៃសក្ខីកម្មនោះមានលេខ E190/2.5 អ្នកនិពន្ធនោះគឺ ហ្វីលីព ហ្សូលីយ៉ង់-ហ្គូសហ្រ៊ើះ។ ឯកសារនេះចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ដែលជាអត្ថបទដែលនិយាយអំពីលោក ខៀវ សំផន។ ហើយលិខិតមួយទៀតគឺរបស់ សំ សុខ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ដែលនិយាយអំពីលោក ខៀវ សំផន ផងដែរ គឺមានលេខ E190/2.7។ សំបុត្រទី៣ ចេញមកពី រ៉ូឡង់ ឌុយម៉ាស ចុះថ្ងៃ១៤ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានលេខកូដ E190/2.18។ សំបុត្រទី៤នោះ គឺចេញមកពី ក្លូត កាតហ្ស៍ ដែលបានសរសេរនៅថ្ងៃ១៨ ខែមេសា ឆ្នាំ២០១១ ដែលសរសេរពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ហើយមានលេខ E190/2.19។

បន្ទាប់មកទៀត គឺឯកសារបីដែលស្នើឡើងដោយលោក ខៀវ សំផន គឺអត្ថបទដែលចុះផ្សាយនៅក្នុងសារព័ត៌មានជាតិ-អន្តរជាតិ។ ឯកសារទី១ គឺ E190/2.4 អត្ថបទនេះសរសេរឡើងដោយ ហ្សង់-ប៉ូល ដេសហ្គូត ដែលមានចំណងជើងថា "ការសំណេះសំណាលជាមួយ ឡូរ៉ង់ ពិច នៅខែមិថុនា ឆ្នាំ១៩៨៤" បន្ទាប់មកទៀត គឺអត្ថបទកាសែតដែលចុះផ្សាយនៅក្នុងសារព័ត៌មានភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា "ណាម ឆមស្គី ដែលត្រូវបានសម្ភាសដោយ ចច ម៉ាកឡូត ដែលធ្វើឡើងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩" ដែលមានលេខកូដ E190/2.20។

[១០:០៦:៣៨]

អត្ថបទចុងក្រោយពាក់ព័ន្ធនឹងចំណុចនេះ គឺជាអត្ថបទរបស់ ប៉ែន ឃៀរនិន, ថៃល័រ អូវ៉ិន ដែលមានចំណងជើងថា "*រូតស៍ អូហ្វ ឌី យូ.អេស ត្រូប៊ុល អ៊ិន អាហ្គានីស្ថាន៖ ស៊ីវីលានប៊ុមប៊ីង*

*កាសសលលីធី អេន ឌឺ ខាំបូឌាន ប្រេស៊ីឌិន*" ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ ដែលមានលេខ E190/2.12។ យើងនឹងបញ្ចប់ទៅលើឯកសារ១១ ដែលស្នើឡើងដោយលោក នួន ជា។

បាទ ឯកសារទី១គឺជាឯកសារដែលសរសេរដោយ ស្ទីវ ហេដឌ័រ នៅឆ្នាំ១៩៩៧ មានចំណងជើង គឺថា " *វេស៊ីម, ម៉ាក្សស៊ីស, និង ដេណូសាយ របស់ ប៉ុល ពត -- របប ប៉ុល ពត*"។ សរសេរនៅឆ្នាំ១៩៩៧ មានលេខកូដ E131/1/13.3។ បាទ ឯកសារទី២ គឺជាសៀវភៅរបស់ ចូអែល ប្រ៊ីង្គលី គឺជាសម្រង់របស់សៀវភៅគាត់ដែលសរសេរនៅឆ្នាំ២០១១ ដែលមានចំណងជើងថា "*ខេមបូឌា ឃើស៖* និង *ឌឺ ម៉ូឌឺន ហិស្តូរី*" លេខកូដ E131/1/13.12។ បាទ ខ្ញុំសូមបញ្ជាក់ថា នេះគឺជាឯកសារដែលសហព្រះរាជអាជ្ញាសូមជំទាស់។

[១០:០៨:៣៧]

បន្ទាប់មកទៀត គឺថាមានរបាយការណ៍ដែលមានលេខកូដ E131/1/13.8 បាទ នេះគឺជារបាយ-ការណ៍របស់ យូ.អេស.ជី.អេ.អូ ចុះថ្ងៃទី៣០ មេសា ឆ្នាំ១៩៧៩ ដែលមានចំណងជើងថា --១៩៧៤ ដែលមានចំណងជើងថា "*រីផត ធូ សាប-ខំមីតធី អន ឌឺ រីហ្វូស អេន អេសខេប*"។ ហើយបន្ទាប់មកទៀតមានឯកសារមួយទៀតដែលមានចំណងជើងថា -- បាទ ដែលចុះនៅថ្ងៃទី១៩ ឆ្នាំ១៩៧៨ មានចំណងជើងថា "សាយហ្គន" បាទលេខកូដ គឺថា E133/1/13.6 (ស៊ុក)។ ហើយបន្ទាប់មកទៀតមានឯកសារសារព័ត៌មានអន្តរជាតិមួយទៀត ដែលសរសេរដោយលោក ស៊ីដនី សាន់ប៊ឺជ ជាកាសែតញូវយ៉កថែមស៍ ដែលសរសេរនៅថ្ងៃទី១៩ មីនា ១៩៧៥ មានចំណងជើងថា "*ខេមបូឌាន អេនទីរីសារី ម៉ាច អូនលី បាយ មីសីរី*" លេខកូដគឺ E131/1/13.4។ ហើយបន្ទាប់មកទៀត គឺឯកសាររបស់ -- នៅក្នុងកាសែត *ញូវវីក* ដោយមានចំណងថា "ភ្នំពេញ ញូវរូល័រ" ដែលចុះថ្ងៃទី២២ មករា ឆ្នាំ១៩៧៩ មានលេខកូដ E131/1/13.7។ ហើយឯកសារមួយទៀតរបស់ ស៊ីដនី សាន់ប៊ឺជ នៅក្នុងកាសែតញូវយ៉កថាមស៍ ដែលចុះនៅថ្ងៃទី២៦ កុម្ភៈ ឆ្នាំ១៩៧៥ មានចំណងជើងថា "*ធៀលជ្រិនស្តារវីង អ៊ីនវ័នស៍-ឡាស ឡោនដ៍*" លេខកូដគឺ E131/1/13.5។ មួយទៀតគឺថា កាសែតជាអត្ថបទរបស់លោក អាល្ហម៉ាន ដែលចុះនៅថ្ងៃទី នៅខែមេសា ឆ្នាំ១៩៩០ ដែលមានចំណងជើងថា "*សីហនុ សាយស្បូ*" លេខកូដគឺថា 131/1/13.2។ ហើយឯកសារនេះក៏យើងសុំជំទាស់ផងដែរ។

[១០:១១:៥៣]

នៅសល់ឯកសារបីចុងក្រោយ គឺឯកសារទី១ គឺថាជារបាយការណ៍របស់ព្រឹទ្ធសភាអាមេរិក

ដែលមានចំណងជើងថា "*យូ.អេស អ៊ែរ អុបភើរេសិន អ៊ីន ខេមបូឌា អេបព្រីល ណាទធីន-សីវិនធីស្រី*" ដែលចុះនៅថ្ងៃទី២៧ មេសា ឆ្នាំ១៩៧៣ ដែលមានលេខកូដ E131/1/13.9។

ហើយមួយទៀត គឺឯកសារដែលជារបាយការណ៍របស់គណៈរដ្ឋមន្ត្រីនៃគណៈអចិន្ត្រៃយ៍របស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាឯកសារនេះចុះថ្ងៃទី២៣ សីហា ឆ្នាំ១៩៨៦ ឯកសារ E131/1/13.11។ ហើយសហព្រះរាជអាជ្ញាសូមជំទាស់នឹងឯកសារនេះផងដែរ។

ហើយនេះជាឯកសារចុងក្រោយដែលជារបាយការណ៍ចុះនៅថ្ងៃទី០៦, ០៧ ឧសភា ឆ្នាំ១៩៩៨ ទាក់ទងទៅនឹងទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅប្រទេសថៃ ហើយរបាយការណ៍នេះមានលេខកូដ E131/1/13.10។ នេះគឺជាឯកសារទី៤ ដែលក្រុម នួន ជា ស្នើហើយខាងព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងឯកសារនេះ ហើយបន្តិចទៀតយើងនឹងផ្តល់មូលហេតុ។ សូមអភ័យទោសដែលការបង្ហាញឯកសារទាំង៤៨នេះ ហើយមានការលំបាកផងដែរ ដោយសារឯកសារច្រើនពេក។

[១០:១៤:០២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៥:២៨]

**ប្រធានអង្គជំនុំ៖**

បាទ បន្ទាប់ពីបានស្តាប់នូវការបង្ហាញនូវអត្តសញ្ញាណឯកសារទាំង៤៨ របស់តំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានស្តាប់ឮតំណាងសហព្រះរាជអាជ្ញាបានលើកឡើងពីការជំទាស់របស់ខ្លួនចំពោះឯកសារមួយចំនួននៅក្នុងបញ្ជីឯកសារទាំង៤៨នេះ។ ឥឡូវនេះ អង្គជំនុំជម្រះសូមស្តាប់នូវសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ចំពោះឯកសារដែលខ្លួនបានបង្ហាញនូវជំហរជំទាស់ និងមូលហេតុនៃការជំទាស់នេះជាមុនសិន មុននឹងផ្តល់វេទិកាជូនទៅភាគីដទៃទៀតនៃរឿងក្តី ជាពិសេសមេធាវីការពារក្តី។

សូមអញ្ជើញបាទ!

[១០:១៦:២៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ នៅក្នុងឧបសម្ព័ន្ធទី១នោះ មិនមានឯកសារដែលខាងសហព្រះរាជអាជ្ញាចង់យកមកពិភាក្សានោះមាននោះទេ ក៏ប៉ុន្តែការប្មូកសរុបឯកសារទាំងនេះ គឺជាកម្មវត្ថុ

នៃការពិភាក្សានៅក្នុងសវនាការយើងនេះ ក៏ប៉ុន្តែនេះជាការពន្យល់ឃើញថាមានឯកសារមួយចំនួនដែលសហព្រះរាជអាជ្ញាជំទាស់។

ខ្ញុំសូមចាប់ផ្ដើមនិយាយអំពីឯកសារទាំងបួន ដែលថាជាឯកសាររបស់ក្រុម ខៀវ សំផន។ យើងមិនជំទាស់ឯកសារទាំង១៨នោះទេ ក៏ប៉ុន្តែមានសក្ខីកម្មបួនដែលសរសេរ ដែលនិយាយល្អអំពីលោក ខៀវ សំផន គឺថាមានមនុស្សមួយចំនួនដែលនិយាយល្អពីគាត់នោះ។ ដើម្បីឲ្យច្បាស់លាស់តែម្ដងនោះ ខ្ញុំសូមឲ្យលេខយោងគឺថាលេខE190/2.5 ដែលគឺជាកាសែតរបស់ អំ!ជាសំបុត្ររបស់ ហ្វូលីយ៉ង់-ហ្វូសហ្វ្រិះ សរសេរនៅថ្ងៃទី១៥ តុលា ឆ្នាំ២០១០។ ឯកសារមួយទៀតគឺ E190/2.7 សរសេរនៅថ្ងៃទី២១ មករា ឆ្នាំមួយពាន់ប្រាំ -- ពីររយដប់មួយ ហើយមួយទៀតគឺថារបស់កាសែតរបស់ ឌុយម៉ា រ៉ូឡង់ ដែលជាមានលេខកូដ E190/2.18 សរសេរ ចុះនៅថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០១១។ មួយទៀតគឺឯកសាររបស់ កាតហ្ស៍ក្លូត ដែលមានលេខកូដ 190/2.19 បាទឯកសារទាំងបួននេះមានបញ្ហាជាក់លាក់មួយចំនួន។

ទី១ គឺថាមានបញ្ហាដែលត្រូវយើងត្រូវតែបំភ្លឺ គឺការដែលថាសក្ខីកម្មរបស់គាត់ទាំងអស់នេះ ត្រូវបានប្រមូល ឬក៏ធ្វើឡើងដោយមានការផ្ដួចផ្ដើមពីក្រុម ខៀវ សំផន បន្ទាប់ពីមានការបញ្ចប់ការស៊ើបអង្កេតទៅហើយ ហើយមិនបានធ្វើដោយសហចៅក្រមស៊ើបអង្កេតដោយឯករាជ្យនោះទេ។ ដូច្នេះគឺជាការធ្វើដោយខ្លួនឯង ហើយមិនត្រូវបានទទួលការអនុញ្ញាតពីអង្គជំនុំជម្រះនោះទេ។

[១០:១៨:៤៩]

ដូច្នេះមិនដែលមានការកំណត់ថាភាគីមួយ ឧទាហរណ៍ដូចជាភាគី ខៀវ សំផន នោះមានសិទ្ធិទាក់ទងទៅនឹងសាក្សីណាមួយដើម្បីឲ្យនិយាយល្អ គាំទ្រកូនក្ដីរបស់ខ្លួននៅពេលដែលមានការបញ្ចប់កិច្ចស៊ើបអង្កេតរួចហើយ។ ហើយមួយទៀតមានការធ្វើសក្ខីកម្មលើកិរិយាមាយាទ ហើយនិងលើអង្គហេតុដែលទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ ហើយនិងមុខងារដែលលោក ខៀវ សំផន កាន់កាប់ ហើយនិងសកម្មភាពរបស់គាត់ អំពើររបស់គាត់។ លោក ហ្វីលីព ហ្វូសហ្វ្រិះ សរសេរនៅក្នុងសំបុត្ររបស់គាត់ដ៏វែងគឺថាឯកសារ E190/2.5 គាត់លើកធ្វើសន្និដ្ឋានមួយចំនួនទាក់ទងទៅនឹងមូលហេតុនៃការដែល ខៀវ សំផន ជំនួស សីហនុ ធ្វើជាប្រមុខរដ្ឋ ហើយនិងគាត់ក៏ធ្វើការសន្និដ្ឋានផងដែរថា អំពីមូលហេតុដែល ខៀវ សំផន មិនត្រូវបានគេសម្លាប់នៅសម័យខ្មែរក្រហមនោះ។

[១០:២០:០២]

ហើយខ្ញុំ នៅក្នុងទំព័រទី៨ ដែលជាភាសាបារាំង ហើយ ERN ភាសាបារាំងគឺថា 00809329 បើ

យើងគិតថាខាងការពារត្រូវតែសុំឲ្យខាងចៅក្រមស៊ើបអង្កេតសួរចម្លើយអ្នកទាំងអស់នេះ នៅពេលក្នុងដំណាក់កាលស៊ើបអង្កេត ឬបើមិនអ៊ីចឹងទេ បើយើងប្រើឯកសារនុំងបានជាលាយលក្ខណ៍អក្សរនោះ ហើយដែលនឹងចង់ឲ្យអង្គជំនុំជម្រះទទួលយកបាននោះ ត្រូវតែឲ្យអ្នកទាំងអស់នេះមកធ្វើផ្តល់សក្ខីកម្ម។ ហើយខ្ញុំគិតថាខាង ខៀវ សំផន បានដាក់មនុស្សទាំងបី ក្នុងចំណោមបួននេះនៅក្នុងឯកសាររបស់គាត់គឺឯកសារ E3, ឯកសារ E9/11.2 គឺមាន ស៊ុយលីយ្យាង ហ្គោក្លូដ និងមនុស្សពីរនាក់ទៀត។

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិភាក្សាលើចំណុចនេះ ហើយនិងបង្ហាញពីគោលជំហររបស់ខ្លួន ក៏ប៉ុន្តែគោលជំហររបស់យើងនោះគឺៗថា ដោយសារក្រុម ខៀវ សំផន ធ្វើដោយខ្លួនឯង ហើយក៏ដាក់នៅក្នុងសំណុំរឿងខ្លួនឯងទៀត ដូច្នេះយើងមិនអាចប្រើជាឯកសារភស្តុតាងបាននោះទេ។ នេះបញ្ជាក់ពីចរិតរបស់ជនជាប់ចោទ។ ទាល់តែឲ្យលទ្ធភាពយើងសួរចម្លើយពួកគាត់ ឲ្យគាត់មកផ្តល់សក្ខីកម្មនៅទីនេះ នេះវាជារឿងយុត្តិធម៌ ហើយពីព្រោះថាការពិភាក្សាដេញដោលគ្នាវាស្របច្បាប់ បើសិនគ្រាន់ -- វាគ្រាន់តែជាសំបុត្រគាំទ្រលើចរិត មាយាទរបស់ជនជាប់ចោទនោះទេ យើងអាចថាមិនជាការធ្ងន់ធ្ងរទេ ក៏ប៉ុន្តែបើទាក់ទងនឹងអង្គហេតុនោះ គាត់ត្រូវតែមកផ្តល់សក្ខីកម្មនៅទីនេះ បើមិនអ៊ីចឹងទេ យើងមិនគិតអំពីឯកសារនេះទេ។ ដូច្នេះ ដូចដែលខ្ញុំបានលើកឡើងពីដើមមកហើយ គឺថាយើងមិនគួរដាក់សំបុត្រទាំងបួននេះមកចូលក្នុងតារាងនោះទេ ដូច្នេះត្រូវតែពិភាក្សានៅក្នុងសវនាការទាក់ទងនឹងចម្លើយគាត់ទាំងបួននាក់នេះ។ ហើយបើពីមុនមកនោះគួរតែឲ្យខាងចៅក្រមស៊ើបអង្កេតសួរអ្នកទាំងបួននាក់នេះ។

[១០:២២:២៧]

ការជំទាស់ទាំងបួននេះ ការជំទាស់ទាំងបួនទៅលើឯកសាររបស់លោក នួន ជា។ ឥឡូវខ្ញុំសូមនិយាយអំពីនេះ។ យើងសូមជំទាស់លើភាពពាក់ព័ន្ធឯកសារទាំងបួននេះ។ ឯកសារទី១ គឺសៀវភៅរបស់ ចូអែល ប្រ៊ីង្គលី ដែលមានចំណងជើង *"ម៉ាឡេខិចស្បុង ឌុយ កាំបូឌស៍ អ៊ិស្តរ័រម៉ូឌែន ឌីស៊ារេ"* លេខកូដគឺ E131/1/13.12។

បាទ នេះខ្ញុំលើកយកជំពូកមួយដែលក្រុម នួន ជា បានជ្រើសរើសយក ដែលវាមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលតុលាការយើងនេះទទួលបណ្តឹងទេ ក៏ប៉ុន្តែវាជាការវិភាគផ្នែកនយោបាយលើស្ថានភាពនយោបាយនៅថ្ងៃនេះ ហើយនិងផ្នែកតុលាការនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ ហើយនិងមានការនិយាយលម្អិតអំពីការបង្កើតតុលាការនេះផងដែរនៅក្នុងអត្ថបទនេះ ហើយនិងនិយាយអំពីការដំណើរការតុលាការនេះផងដែរ។ ដូច្នេះ យើងមិនឃើញមានការពាក់ព័ន្ធផ្ទាល់រវាងសំណេររបស់ ចូអែល ប្រ៊ីង្គលី នេះ

ហើយនិងអង្គហេតុខ្លឹមសារដែលទាក់ទងទៅនឹងឆ្នាំ -- រយៈពេលចន្លោះ៧៥ និង ៧៩ នោះទេ។ ដូច្នេះ មិនពាក់ព័ន្ធនឹងការជម្រះសេចក្តីយើងនេះទេ។

អត្ថបទទី២ គឺអត្ថបទរបស់ ដាមាណ នៅក្នុង វ៉ាននីទីហ្វែរ ដែលមានលេខកូដ E131/1/13.2 ដែលសរសេរនៅឆ្នាំ១៩៩០ ដែលចំពោះយើងនោះពុំមានផលប្រយោជន៍អីទាំងអស់ចំពោះការកាត់ក្តីយើងនេះ វាទាក់ទងទៅនឹង -- និយាយអំពីបុគ្គលិកលក្ខណៈរបស់ សីហនុ និង ហ៊ុន សែន ដែលវាមានលក្ខណៈថាជារឿងកំប៉ិកកំប៉ុក ដែលពុំមានទាក់ទងទៅនឹងអង្គហេតុដែលយើងកំពុងតែធ្វើការជម្រះសេចក្តីនេះទេ។ ដូច្នេះវាមិនធ្វើឲ្យ -- មិនជួយក្នុងសំណុំរឿងយើងនេះ ហើយមិនជួយរកការពិតនោះទេ។ ដូច្នេះ យើងឃើញថាមិនពាក់ព័ន្ធទាល់តែសោះ។

[១០:២៥:០៣]

ចុងក្រោយ ឯកសារចុងក្រោយគឺឯកសារ ដែលមានបញ្ហាផងដែរ យើងជំទាស់គឺឯកសារ E131/1/13.11 ដែលជារបាយការណ៍គណៈរដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចុះថ្ងៃទី២៣ សីហា ឆ្នាំ១៩៨៦ ទាក់ទងទៅនឹង ក-៥។ បាទ អង្គជំនុំជម្រះបានបញ្ជាក់ផងដែរថា អង្គហេតុទាក់ទងនឹង ក-៥ នេះមិនមានភាពពាក់ព័ន្ធទៅនឹងការជម្រះសេចក្តីយើងនោះទេ ហើយមេធាវីរបស់លោក នួន ជា តែងតែចោទសំណួរទាក់ទងទៅនឹង ក-៥ នេះ រហូត ហើយចំពោះយើងនេះគឺថា វាមិនមានទាក់ទងគ្នាទេ ដែលឆ្នាំ១៩៨៦ នេះហើយនិងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្រោមរបបខ្មែរក្រហមនេះទេ។ ដូច្នេះវាមិនមានភាពពាក់ព័ន្ធនោះទេ។ យើងប្រហែលជាអាចប្រើឯកសារនេះទាក់ទងទៅនឹងខាងមនុស្សសាស្ត្របានដូចដែលលោកមេធាវី លោក នួន ជា បាននិយាយ។ ក៏ប៉ុន្តែមិនដែលមានបង្ហាញពន្យល់បញ្ជាក់អំពីមូលហេតុ ថាតើហេតុអ្វីឯកសារនេះអាចជួយដល់ការរកការពិតនៅតុលាការយើងនេះទេ។

[១០:២៦:៤៥]

នៅចុងបញ្ចប់គឺថាមានរបាយការណ៍មួយទៀត គឺលេខកូដ E131/1/13.10។ នេះគឺជារបាយការណ៍ដែលចុះថ្ងៃទី០៦, ០៧ ឧសភា ឆ្នាំ១៩៩៨ ទាក់ទងទៅនឹងការធ្វើទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅប្រទេសថៃ ហើយនិងការពិភាក្សាដែលបានធ្វើការរាយការណ៍។ ហើយនេះគឺជាឯកសារនយោបាយនៅក្នុងឆ្នាំ១៩៩៨ ហើយដែលហាក់ដូចជាមិនមានតម្លៃផ្លូវច្បាប់នៅក្នុងការជម្រះសេចក្តីនោះទេ។

[១០:២៧:៣១]

ហើយទាក់ទងទៅនឹងឯកសារនេះផងដែរ ខ្ញុំគិតថាអង្គជំនុំជម្រះច្បាស់ហើយគឺថា ដែលថាទាក់ទងទៅនឹងចម្លើយដែលមាននៅក្នុងឯកសារបែបនេះ ដែលធ្វើដោយឥស្សរជននយោបាយនោះ។ អង្គជំនុំជម្រះបានជម្រាបហើយថានេះមិនទាក់ទងទៅនឹងរឿងក្ដីតុលាការនោះទេ ព្រោះថាមិនទាក់ទងទៅនឹងអង្គហេតុដែលតុលាការបានទទួលបណ្ដឹងគឺថាទាក់ទងនឹងរបបខ្មែរក្រហមចន្លោះ ៧៥-៧៩ តែប៉ុណ្ណោះ។ ដូច្នេះ ឯកសារទាំងអស់នេះ បើនិយាយពីលក្ខខណ្ឌនៃភាពទាក់ទងយើងសូមជំទាស់លើឯកសាររបស់ នួន ជា ដែលអនុលោមទៅតាមវិធាន៨៧(៣)(ក) ដោយសារលក្ខខណ្ឌនោះមិនត្រូវបានបំពេញ។ ដូច្នេះ សុំឲ្យអង្គជំនុំជម្រះសម្រេចថាមិនអាចទទួលយកឯកសារទាំងបួននេះបានទេ។

[១០:២៨:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២៨:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំ ជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៩ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តើមានអ្វីលើកឡើងជំទាស់ដែរឬទេ លើបណ្ដាឯកសារទាំងឡាយ ដែលបានដាក់បង្ហាញអត្ថសញ្ញាណទាំង៤៨ ដែលលើកឡើងដោយ

តំណាងសហព្រះរាជអាជ្ញាមុននេះបន្តិច?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះយើងមិនមានការជំទាស់បន្ថែមអ្វីនោះទេ។ យើងសូមគាំទ្រទៅលើការជំទាស់របស់សហព្រះរាជអាជ្ញាទៅលើឯកសារបួន របស់មេធាវីការពារក្តីខៀវ សំផន និងឯកសារបួនរបស់មេធាវីការពារក្តី នួន ជា។ យើងគិតថា ឯកសារទាំង៨នេះ មិនមានភាពពាក់ព័ន្ធនោះទេ ហើយយើងក៏មិនមានអ្វីបន្ថែមទៅលើការជំទាស់របស់សហព្រះរាជអាជ្ញានោះដែរ។ សូមអរគុណលោកប្រធាន។

[១០:៥៥:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសឆ្លើយតបទៅនឹងការជំទាស់ ដែលធ្វើឡើងដោយតំណាងសហព្រះរាជអាជ្ញាចំពោះឯកសារមួយចំនួន ក្នុងចំណោមឯកសារទាំង៤៨ ដែលតំណាងសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះ។ ហើយជាដំបូងសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។ ហើយទន្ទឹមនឹងនេះផងដែរ ប្រសិនបើអាចធ្វើទៅបាន គឺប្រសិនបើអស់លោកមានការជំទាស់តវ៉ាទៅនឹងឯកសារណាមួយ ក្នុងចំណោមឯកសារ -- ឬច្រើនក្នុងចំណោមឯកសារទាំង៤៨ ក៏អាចលើកឡើងផងដែរ។

សូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នៅក្នុងពេលនេះ យើងខ្ញុំមិនមានការជំទាស់ណាមួយត្រូវលើកឡើងនោះទេ។ ហើយយើងក៏មិនមានយោបល់បន្ថែមឆ្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញាផងដែរ។ សូមអរគុណលោកប្រធាន។

[១០:៥៦:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ប្រសិនបើមានបញ្ហាសូមអញ្ជើញបាទ!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម ភាគីទាំងអស់ អស់លោក លោកស្រីនៅជុំវិញបន្ទប់សវនាការ។ កាលពីសប្តាហ៍មុនយើងទទួលបាននូវអ៊ីម៉ែលជាច្រើន ហើយនៅក្នុងថ្ងៃនេះវាទំនងជាបង្ហាញថា អង្គជំនុំជម្រះបានអនុវត្តតាមវិធីសាស្ត្រដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ យើងខ្ញុំយល់ឃើញថា ទី១ ប្រសិនបើយើងដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរលើឯកសារទាំងអស់នេះ យើងខ្ញុំចង់ធ្វើដូច្នេះ ហើយយើងខ្ញុំនឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ហើយឯកសារនីមួយៗ យើងខ្ញុំនឹងបង្ហាញការជំទាស់ជាលាយលក្ខណ៍អក្សរទៅតាមលំដាប់លំដោយ ដែលសហព្រះរាជអាជ្ញាបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ១។ ចំពោះទឡ្ហីករណ៍ផ្ទាល់មាត់នៅក្នុងថ្ងៃនេះ ខ្ញុំនិយាយក្នុងន័យទូទៅ ដោយផ្អែកទៅតាមការបកស្រាយរបស់ខ្ញុំទៅលើអ៊ីម៉ែលដែលបានឆ្លើយឆ្លង ដែលយើងទទួលបាន។ ហើយខ្ញុំនឹងកម្រិតយោបល់របស់ខ្ញុំត្រឹមតែប្រភេទនៃឯកសារទាំងឡាយ ដែលមានបញ្ចូលនៅក្នុងឧបសម្ព័ន្ធនេះ។

[១០:៥៧:៥៦]

យើងខ្ញុំសូមកត់សម្គាល់ថា ឯកសារ៩ប្រភេទ វាមានលក្ខណៈខុសៗគ្នាទាំង៩ប្រភេទ ហើយខ្ញុំនឹងលើកឡើងប្រភេទនីមួយៗ និងឯកសារនីមួយៗ ហើយវាមិនចាំបាច់ទៅតាមលំដាប់លំដោយដែលរៀបរាប់នៅក្នុងឧបសម្ព័ន្ធនេះនោះទេ។ ឯកសារសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងរបាយការណ៍បំពេញការស៊ើបសួរ ខ្សែវីដេអូ លិខិត...។ល។ គឺវាពាក់ព័ន្ធទៅនឹងក្រុម ខៀវ សំផន ចម្លើយសារភាពប្រវត្តិរូប ឯកសាររបស់រដ្ឋាភិបាលបរទេស របាយការណ៍ លិខិតទំនាក់ទំនងអន្តរជាតិ សារព័ត៌មានសៀវភៅ និងឯកសារស្រាវជ្រាវផ្សេងៗ...។ល។ ដែលខ្ញុំនឹងបង្ហាញ។

យោបល់ទូទៅរបស់យើងខ្ញុំនោះគឺថា ខ្ញុំនឹងលើកឡើងមួយៗម្តងពាក់ព័ន្ធទៅនឹងរបាយការណ៍បំពេញកិច្ចស៊ើបសួរនោះគឺថា ហេតុអ្វីចាំបាច់ត្រូវតែលើកឡើង។ យើងឃើញថាមានសេចក្តីសង្ខេបនៃរបាយការណ៍ ក៏ប៉ុន្តែតម្លៃនៃសេចក្តីសង្ខេបនោះគឺយ៉ាងម៉េច? គឺគ្មានតម្លៃទាល់តែសោះ គឺសូន្យ។ ហើយតើវាយ៉ាងម៉េច? នៅពេលដែលយើងធ្វើសេចក្តីសង្ខេបទៅលើសេចក្តីសង្ខេបរបាយការណ៍នោះ គឺវាជាភស្តុតាងបន្ថែម ហើយគ្មានប្រយោជន៍ទេសម្រាប់យើងទាំងអស់គ្នា វាគ្មានតម្លៃភស្តុតាង ហើយវាមិនមានតម្លៃភស្តុតាងនោះទេ។ ដូច្នេះយើងគួរតែច្រានចោលរបាយការណ៍បំពេញដីកាឲ្យស៊ើបសួរជំនួសនេះ។

[១០:៥៩:៣៥]

ចំពោះខ្សែវីដេអូ មិនថាអ្នកណាជាអ្នកផលិតនោះទេ នៅក្នុងករណីនេះ គឺថាយើងឃើញមានខ្សែវីដេអូមួយ ដែលបានចែកចាយទូទាំងពិភពលោក ហើយធ្វើជាឯកសារ -- ខ្សែឯកសារផងដែរ។ ហើយដែលវាកើតឡើង១០ឆ្នាំមកហើយ។ យើងសូមលើកឡើងថា វាជាខ្សែវីដេអូសិល្បៈតែប៉ុណ្ណោះ។ ខ្ញុំនិយាយដូច្នេះ ដោយសារតែវាផ្អែកទៅលើខ្សែអាត់ថតជាង១០០ម៉ោង ហើយគេយកមកសរុប ដើម្បីធ្វើជាប្រវត្តិ ឬក៏ផ្តល់ជាមតិយោបល់ និងធ្វើការរៀបរាប់ទៅតាមការយល់ឃើញរបស់អ្នកផលិត។

ដូច្នេះ តាមគោលការណ៍ យើងខ្ញុំជំទាស់ខ្សែវីដេអូទាំងឡាយណាដែលមានលក្ខណៈប្រភេទនេះ លើកលែងតែឯកសារវីដេអូនោះដែលកែសម្រួលនោះ គឺថាភាគីបានទទួលផងដែរ។ ជាពិសេសចំពោះបុគ្គលមួយនេះ គឺលោក សម្បត្តិ គឺគាត់អាចផលិតខ្សែវីដេអូឯកសាររបស់គាត់ថតចម្លងបាននោះ គឺថាយើងគួរតែមើល ហើយថាតើគាត់បានដកចំណុចណាចេញខ្លះដោយសារតែ ចំណុចដែលដកចេញមួយចំនួននោះ វាអាចជាភស្តុតាងដោះបន្ទុក ហើយវាអាចបង្ហាញឲ្យយើងឃើញនូវទិដ្ឋភាពមួយផ្សេងពីនេះ។

[១១:០១:០៤]

របាយការណ៍ដែលគាំទ្រទៅលើលោក ខៀវ សំផន យើងមិនមានជំហរអ្វីនោះទេ។ ជាក់ស្តែងជនជាប់ចោទនីមួយៗមានសិទ្ធិបង្ហាញភស្តុតាងដោយខ្លួនឯង ដោយគាំទ្រទៅលើអត្តចរិតរបស់គាត់។ យើងទុកបញ្ហានេះឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើការពន្យល់បន្ថែម ហើយអ្វីបានជាលិខិតទាំងអស់នេះ វាមានសារៈសំខាន់ហើយត្រូវដាក់បញ្ចូល។ ជាការពិត យើងខ្ញុំមិនជំទាស់ការដាក់បញ្ចូលលិខិតទាំងអស់នោះទេ។ ហើយយើងខ្ញុំសូមគាំទ្រចំពោះការទទួលយកលិខិតទាំងអស់នេះ នៅក្នុងដំណាក់កាលនេះ។

ចម្លើយសារភាពវិញម្តង តើខ្ញុំអាចនិយាយអ្វីខ្លះ? ខ្ញុំសូមនិយាយម្តងហើយម្តងទៀត ទៅលើចំណុចនេះ។ ដូច្នេះអ្វីទាំងឡាយដែលវាជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម គឺយើងត្រូវដកចេញ។ ចំណុច គឺបានន័យចង់ ខ្ញុំចង់តែនិយាយតែប៉ុណ្ណោះនោះទេ។ បានន័យថា ផ្លែឈើទាំងឡាយណាដែលទទួលបានមកពីដើមឈើដែលមានជាតិពុល គឺថាយើងត្រូវតែដកចេញ។ ចំពោះប្រវត្តិរូបរបស់ ឡុង នរិន្ទ វិញ យើងឃើញមាននៅក្នុងនេះផងដែរ។ ប្រវត្តិរូបរបស់ ឡុង នរិន្ទ។ ឡុង នរិន្ទ បានផ្តល់សក្ខីកម្មភាគីមានឱកាសសួរដេញដោល គាត់បានបញ្ជាក់ថា“គាត់បានសរសេរប្រវត្តិរូបផ្ទាល់របស់គាត់” ហើយសក្ខីកម្មផ្ទាល់មាត់របស់គាត់នោះ គឺគ្រប់គ្រាន់ហើយតាមការយល់ឃើញរបស់យើងខ្ញុំ។ ហើយប្រសិនបុគ្គលណាមួយចង់ប្រើប្រាស់ប្រវត្តិរូបរបស់គាត់សួរដេញដោលនៅពេលនោះ នោះ គឺថាអាចធ្វើទៅបាន។

ហេតុដូច្នេះហើយប្រវត្តិរូបរបស់ ឡុង នរិន្ទ យកមកដាក់ពេលនេះគឺគ្មានប្រយោជន៍នោះទេ។ ដោយសារតែសក្ខីកម្មភស្តុតាងយើងបានទទួលបានរួចមកហើយនៅពេលដែលគាត់មកផ្តល់សក្ខីកម្ម។

[១១:០២:៥២]

របាយការណ៍របស់សហ -- អង្គការសហប្រជាជាតិ រដ្ឋាភិបាលបរទេស និងអង្គការមិនមែនរដ្ឋាភិបាល។ យើងខ្ញុំជំទាស់យ៉ាងខ្លាំងទៅនឹងរបាយការណ៍ទាំងអស់ មិនថាភាគីណាមួយជាអ្នកស្នើសុំបញ្ចូលនោះទេ។ យើងមិនថា ពីក្រុមមេធាវីការពារក្តី ឬក៏ពីខាងសហព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ យើងខ្ញុំសូមជំទាស់ទាំងស្រុងតែម្តង។

ឯកសាររបាយការណ៍ទាំងអស់នេះ ជាពិសេសរបាយការណ៍មកពីបារាំង និងសហរដ្ឋអាមេរិកគឺមានលក្ខណៈគួរឲ្យសង្ស័យ។ ជាពិសេសនោះ របាការណ៍របស់សហរដ្ឋអាមេរិក ដោយសារតែសហរដ្ឋអាមេរិកនេះបានធ្វើសង្គ្រាមមួយដែលមិនសូវមានល្អនោះទេ នៅក្នុងស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ ហើយគឺ ដូច្នេះហើយរបាយការណ៍របស់សហរដ្ឋអាមេរិក គឺថាវាមានលក្ខណៈគួរឲ្យយើងសង្ស័យមិនត្រូវទទួលយកនោះទេ។

[១១:០៣:៤៨]

ជាគោលការណ៍ យើងខ្ញុំសូមជំទាស់របាយការណ៍ប្រភេទនេះ លើកលែងតែអ្នកដែលជាអ្នកសរសេររបាយការណ៍ទាំងអស់នោះមកផ្តល់សក្ខីកម្មបាន។ យើងខ្ញុំទទួលយកបានប្រសិនបើដូច្នេះមែន។ របាយការណ៍ទាំងឡាយរបស់អង្គការសុខភាពពិភពលោក ឬសហរដ្ឋអាមេរិកនោះ គឺថាយើងមិនមានឱកាសក្នុងការពិនិត្យ និងដេញដោលទៅលើអ្នកនិពន្ធនោះទេ ហើយយើងក៏មិនដឹងថា តើអ្នកនិពន្ធទាំងអស់នោះបានដឹងអ្វីខ្លះនៅពេលដែលពួកគាត់រៀបចំរបាយការណ៍។ ដូច្នេះយើងខ្ញុំសូមជំទាស់។

លិខិតឆ្លើយឆ្លងអន្តរជាតិ យើងឃើញថា ឯកសារមួយចំនួនផ្តល់ជូនដោយរដ្ឋ -- ក្រសួងការបរទេសសហរដ្ឋអាមេរិក។ ហើយយើងខ្ញុំសូមបញ្ជាក់ថា វាមានលក្ខណៈសង្ស័យ យើងឃើញថាមានព័ត៌មានជាច្រើននៅក្នុងហ្នឹង។ យើងឃើញមានឯកសារមួយចំនួនដែលផលិតដោយស្ថានទូតអាមេរិកនៅទីក្រុងបាងកក។ ដូច្នេះយើងខ្ញុំសូមលើកឡើងថា ដោយពិចារណាទៅលើស្ថានភាពកើតឡើងនៅពេលនោះ គឺយើងមានលក្ខណៈសង្ស័យណាស់។ ហើយយើងមិនដឹងថា តើរបៀបប្រមូលបាននៅពេលនោះយ៉ាងម៉េច? ការដាក់បញ្ចូលគ្នានោះយ៉ាងម៉េច? ការរៀបរាប់នោះ ចំណុចណាខ្លះដែលបានដកចេញដោយសារមូលហេតុសន្តិសុខ។ល។

[១១:០៥:០៥]

ដូច្នេះហើយ ឯកសារទាំងអស់នេះ ប្រសិនបើយកមកដាក់បញ្ចូលនោះ គឺយើងគួរតែកោះហៅអ្នកនិពន្ធ អ្នកសរសេររបាយការណ៍ទាំងអស់ លិខិតឆ្លើយឆ្លងទាំងអស់នោះផងដែរ មកផ្តល់សក្ខីកម្មដើម្បីឲ្យយើងអាចដេញដោលបាន។ វាជាការរំលោភសិទ្ធិរបស់កូនក្តីរបស់ខ្ញុំ ប្រសិនបើដាក់ឯកសារប្រភេទនេះបញ្ចូលមកដោយមិនមានការសួរតទល់ជាមួយនឹងអ្នកនិពន្ធ។ ឯកសារសារព័ត៌មានកាសែតអត្ថបទ មិនថានៅមុនឆ្នាំ១៩៧៥ ឬក៏ចន្លោះឆ្នាំ៧៥ ដល់៧៩ ឬក៏ក្រោយរយៈកាលឆ្នាំ៧៩ យើងសូមលើកឡើងថា មិនអាចទទួលយកបាននោះទេ ប្រសិនបើអ្នកនិពន្ធកាសែតទាំងអស់នោះមានបំណងមកផ្តល់សក្ខីកម្មមកចូលរួមនៅទីនេះទៅលើស្ថានការណ៍កើតឡើងណាមួយ ដែលវាពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលារបស់តុលាការនេះ បានន័យថាក្រោយពេលដួលរលំនៃភ្នំពេញ និងការជម្លៀសទីក្រុងភ្នំពេញនោះ គឺថាមិនជា -- យើងខ្ញុំមិនជំទាស់នោះទេ បើសិនពួកគាត់ចង់មកផ្តល់សក្ខីកម្ម។

[១១:០៦:១០]

អ្នកកាសែតបារាំង -- អ្នកកាសែតកម្ពុជានោះ អាចមកផ្តល់សក្ខីកម្មបាននៅទីនេះ។ ក៏ប៉ុន្តែយើងខ្ញុំជំទាស់អត្ថបទសារព័ត៌មានទាំងអស់ដែលបានស្នើឡើងនេះ ប្រសិនបើការរៀបរាប់នៅក្នុងកាសែតអត្ថបទទាំងអស់នេះ វាមិនត្រឹមត្រូវ។ ជាពិសេសអត្ថបទដែល ទំនងដែលត្រូវយកមកប្រើនោះដោយផ្អែកខ្លាំងទៅលើខ្លឹមសាររបស់វា។ ចំពោះសៀវភៅ និងស្នាដៃស្រាវជ្រាវ នេះជាប្រភេទឯកសារដែលបានស្នើឡើងចុងក្រោយនៅក្នុងឧបសម្ព័ន្ធនេះ។ យើងបានដកឯកសារសៀវភៅមួយចំនួនដែលដំបូងយើងបានស្នើឡើង ហើយអង្គជំនុំជម្រះនៅទីនេះ គឺបានពិចារណាទៅលើឯកសារទាំងអស់នេះ។ ហើយនៅពេលដែលសវនាការចាប់ផ្តើមនោះ គឺថាជំហររបស់ខ្ញុំនោះមានការផ្លាស់ប្តូរបន្តិចបន្តួច។

[១១:០៧:០៥]

ក៏ប៉ុន្តែជំហរជាទូទៅរបស់យើងខ្ញុំនោះគឺថា ប្រសិនបើសៀវភៅណាមួយយកមកដាក់បញ្ចូលអ្នកនិពន្ធនោះត្រូវតែកោះហៅមកផ្តល់សក្ខីកម្មនៅទីនេះផងដែរ។ ដូច្នេះមានន័យថាយ៉ាងម៉េច? យៀវនិនគាត់មិនមកផ្តល់សក្ខីកម្មនៅទីនេះ។ ដូច្នេះសៀវភៅរបស់គាត់មិនគួរដាក់បញ្ចូលនោះទេ សៀវភៅរបស់លោក យៀវនិន។ ហើយចំពោះ អូស្បន ខ្ញុំសូមលើកឡើងដូចតែគ្នា។ គ្មានសៀវភៅឯកសារស្រាវជ្រាវណាមួយយកមកដាក់បញ្ចូលនោះទេ លើកលែងតែអ្នកនិពន្ធនីមួយៗនោះ មកផ្តល់សក្ខីកម្មនៅទីនេះហើយភាគីមានឱកាសក្នុងការសួរពិនិត្យដេញដោលទៅលើអ្នកនិពន្ធ អ្នកសរសេររៀបរាប់។ ជាពិសេស

យើងអាចមានឱកាសសួរទៅលើវិធីសាស្ត្រនៃការសរសេរសៀវភៅ និងប្រភពឯកសារនានា ដែលគាត់យកមកធ្វើជាមូលដ្ឋាន។ បន្ថែមទៅលើចំណុចនេះ អង្គជំនុំជម្រះគួរតែធានាឲ្យបានជាក់លាក់ថា មុនពេលដែលឯកសារណាមួយយកមកដាក់បញ្ចូលនៅក្នុងនេះ ឯកសារទាំងអស់ត្រូវតែមានភាពពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលា និងគោលបំណងកម្រិតរបស់យើង គឺសំណុំរឿង ០០២/០១។

[១១:០៨:១៨]

ដូចដែលខ្ញុំបានកត់សម្គាល់ លោកប្រធាន លោក លោកស្រីចៅក្រម យើងខ្ញុំនឹងដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរលើកឡើងអំពីឯកសារនីមួយៗរៀបរាប់នូវក្នុងឧបសម្ព័ន្ធនេះ។ តាមអ្វីដែលខ្ញុំយល់ គឺថាយើងមានឧសម្ព័ន្ធផ្សេងទៀតផងដែរ ដែលយើងកំពុងតែពិនិត្យពិចារណា ហើយយើងខ្ញុំនឹងលើកឡើងការជំទាស់របស់ខ្ញុំជាលាយលក្ខណ៍អក្សរ លើកលែងតែមានការយល់ខុសណាមួយទៅលើជំហររបស់យើងខ្ញុំ។ ដូច្នេះហើយ លើកលែងតែមានសំណួរណាមួយពីអង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះនោះ គឺថាយើងខ្ញុំសូមបញ្ចប់ត្រឹមនេះ។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទជាបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការជំទាស់ ឬក៏បង្ហាញពីការជំទាស់របស់ខ្លួនទៅលើបណ្ដាឯកសារទាំងឡាយដែលបង្ហាញដោយតំណាងសហព្រះរាជអាជ្ញាចំនួន៤៨។

សូមអញ្ជើញបាទ!

[១១:០៩:៣២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយមិនយូរទេ ទាក់ទងទៅនឹងការជំទាស់ឯកសារនេះ។

ខ្ញុំសូមរំឭកថា តាមការអានសេចក្ដីសម្រេច ចុះថ្ងៃទី០៣ ធ្នូ ឆ្នាំ២០១២ ឃើញ -- បង្ហាញឲ្យឃើញពីយុត្តិសាស្ត្រនៃតុលាការយើងនេះ។ ខ្ញុំសូមគាំទ្រការលើកឡើងរបស់សហភាគីរបស់ខ្ញុំទាក់ទងនឹងវីដេអូ ដូចដែលបាននិយាយឡើងអំពីឯកសារពីក្នុងសវនាការមុន។ ខ្ញុំសូមរកលេខយោងដែលឯកសារវីដេអូរបស់លោក ខៀវ សំផន ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។ ខ្ញុំសូមរំឭកថានៅពេលដែលយើងបង្ហាញសម្រង់ខ្សែវីដេអូនេះ គឺថាមានសេចក្ដី -- មានចម្លើយឆ្លើយទៅនឹង -- យើងមិនដឹងថា

ឆ្លើយទៅនឹងសំណួរណាទេ ហើយយើងមិនដឹងថាពីលក្ខខណ្ឌនៃការថតវីដេអូនេះយ៉ាងម៉េចនោះទេ។ អ៊ីចឹងបានន័យថា យើងមិនដឹងថាគេធ្វើវីដេអូនេះក្នុងលក្ខខណ្ឌណា ហើយការចាប់យកពាក្យសម្ដីនេះយកមកថតទុកនេះក្នុងបំណងអ្វី។ ដូច្នេះ យើងមិនអាចយកនេះជាតម្លៃភស្តុតាងនោះទេ។ ដូច្នេះមិនអាចទទួលយកវីដេអូនេះបានទេ។

[១១:១១:០០]

ចំណុចទី២ គឺទាក់ទងនឹងលិខិតសំបុត្រថាមានលេខកូដមួយ គឺថាសំបុត្រសរសេរលោក ខៀវ សំផន គឺឯកសារ E190/2.5 ហើយនិងឯកសារ E190/2.7 ហើយនិង E190/2.18, E190/2.19។ សំបុត្រទាំងអស់នេះ សហព្រះរាជអាជ្ញា ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីបានជំទាស់ អ៊ីចឹងសូមឲ្យពិចារណាពីបរិបទនៃការសរសេរសំបុត្រទាំងអស់នេះ។ ខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះថា សារណារបស់យើង E9/11.2 ដែលចុះនៅខែកុម្ភៈ ឆ្នាំ២០១២ អ៎! ២០១១ ខ្ញុំ -- សំបុត្រដែលយើងបានផ្ដល់ជូនហើយយើងសូមដាក់ចូលទៅក្នុងសំណុំរឿងនោះ ហើយនិងឲ្យមានការដេញដោលនោះ នេះគឺជា វាស្ថិតនៅក្នុងបញ្ជីរបស់យើងហើយ។ ដូច្នេះ អ៊ីចឹងហើយចំពោះករណីអ្នកស្រី ក្លូត កាតហ្ស៍ ដែលមាននៅឧបសម្ព័ន្ធទី១ ដែលលេខកូដគឺថា លេខសំបុត្រនោះគឺថា ១៩០ -- E190/2.19 នេះមិនមាននៅក្នុងបញ្ជីសាក្សីរបស់យើងកាលពីដែលយើងដាក់នៅឆ្នាំ២០១១ នោះទេ អ៊ីចឹងហើយបានវាអត់មាននៅក្នុងបញ្ជីយើង ព្រោះយើងដាក់ពេលក្រោយហើយ។ ដូច្នេះមូលហេតុដែលយើងផ្ដល់ឯកសារដូចជាសំបុត្រទាំងអស់នេះ ដែលជាសំបុត្រដែលនិយាយអំពីអត្តចរិតរបស់លោក ខៀវ សំផន ហើយនិងពីបទពិសោធន៍របស់អ្នកសាក្សីទាំងអស់នេះ ដែលគាត់ជួប បានជួបលោក ខៀវ សំផន និងបរិបទដែលពួកគាត់បានជួបលោក ខៀវ សំផន នេះ វាសំខាន់ណាស់ យើងត្រូវយល់ពីចំណុចទាំងអស់នេះ។

[១១:១៣:១៧]

យើងសូមឲ្យមនុស្សទាំងអស់នេះមកធ្វើ មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយយើង -- ចំពោះយើងគឺថាយើងចង់ឲ្យគាត់មកផ្ដល់សក្ខីកម្ម ហើយដូចគ្នាដែរ គឺថាអ្នកដែលបាននិយាយអំពីលោក ខៀវ សំផន ពីមុនៗមកនោះ ក៏សូមឲ្យមកផ្ដល់សក្ខីកម្មផងដែរ។ អ៊ីចឹងលិខិតទាំងអស់សំបុត្រទាំងអស់របស់អ្នកទាំងអស់នេះ គឺជាចម្លើយពីមុនមក មុននឹងពេលដែលលោក ខៀវ សំផន មកតុលាការនេះ។ ដូច្នេះអ្វីដែលយើងចង់ដឹង គឺថាតើអង្គជំនុំជម្រះកោះហៅសាក្សីទាំងអស់នេះដែរឬក៏អត់? ដូច្នេះក្នុងការសន្និដ្ឋាននេះ គឺថាមាន វាមានភស្តុតាងដោះបន្ទុក ហើយយើងក៏មិនដឹងដែរ ថាតើការៗក្នុង

ពេលស៊ើបអង្កេតនោះ យើងមិនដឹងថាមានការស៊ើបអង្កេតហ្នឹងយកភស្តុតាងដោះបន្ទុក ឬក៏ដាក់បន្ទុកយ៉ាងណានោះទេ។ អ៊ីចឹងវាអាចប៉ះពាល់ដល់សិទ្ធិរបស់លោក ខៀវ សំផន ដែលយើងមិនៗអាចដាក់ចម្លើយរបស់សាក្សីទាំងអស់នេះនៅក្នុងសំណុំរឿង ដែលគាត់ ដែលអ្នកទាំងអស់នេះអាចនិយាយអំពីឥស្សរភាពរបស់លោក ខៀវ សំផន ហើយនិងបរិបទដែលប្រែប្រួល។ ដូច្នេះយើងសូមឲ្យសាក្សីទាំងអស់នេះមកផ្តល់សក្ខីកម្មចំពោះមុខតុលាការដើម្បីនិយាយអំពីឥស្សរភាព ឬក៏បុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន។ ដូច្នេះសូមឲ្យគ្រោងសវនាការសម្រាប់ស្តាប់គាត់។

បើសិនជាអង្គជំនុំជម្រះមិនទទួលសាក្សីទាំងអស់នេះ ទាំងស្រុងនោះទេ យ៉ាងហោចណាស់ក៏សុំឲ្យបញ្ចូលសំបុត្រទាំងអស់នេះនៅក្នុងសំណុំរឿង ពីព្រោះមានធាតុដោះបន្ទុកច្រើន ដូច្នេះនេះ -- ពីព្រោះថានេះវាៗបញ្ជាក់ពីការគោរពសិទ្ធិរបស់ជនជាប់ចោទ។ យើងសូមរំឭកថានៅក្នុងឯកសារ E9.12 គឺថាយើងសុំ -- គឺថាមាននិយាយអំពីបរិបទប្រវត្តិសាស្ត្រ ហើយនិងបុគ្គលិកលក្ខណៈរបស់លោកតួអង្គ។ ហើយបុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន ដែលសាក្សីទាំងអស់នេះបានសង្កេតឃើញ អ៊ីចឹងហើយនេះវាៗស្ថិតនៅក្នុងបរិបទប្រវត្តិសាស្ត្រតែម្តង។

[១១:១៦:០៥]

អ៊ីចឹងខ្ញុំសូមគូសបញ្ជាក់ថាជាការសំខាន់ណាស់ ដែលយើងត្រូវតែបញ្ចូលសក្ខីកម្មរបស់គាត់ទាំងអស់នេះនៅក្នុងសំណុំរឿង។ ហើយសហព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារនេះមិនពាក់ព័ន្ធនោះខ្ញុំគិតថានេះ ថាយើងត្រូវដឹងថាអំពីបរិបទថា អំពីលក្ខខណ្ឌតើសំបុត្រទាំងអស់នេះធ្វើឡើង ឬក៏យើងប្រមូលយកមកក្នុងលក្ខខណ្ឌណា? អ៊ីចឹងដើម្បីឲ្យច្បាស់លាស់នោះគឺថា គ្មានអ្វីក្រៅពីកោះហៅពួកគាត់ទាំងអស់មកផ្តល់សក្ខីកម្មនោះទេ។ បាទ នេះជាចម្លើយរបស់ខ្ញុំឆ្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយខ្ញុំសូមបញ្ជាក់ថានេះវាមានសារៈសំខាន់ណាស់ព្រោះវាពាក់ព័ន្ធនឹងអត្តចរិតរបស់លោក ខៀវ សំផន ហើយនិងបរិបទប្រវត្តិសាស្ត្រ។ ដូច្នេះវាមានភាពពាក់ព័ន្ធ ហើយព្រោះថាយើងត្រូវគិតថាការសរសេរអំពីអត្តចរិតរបស់លោក ខៀវ សំផន នេះវាស្ថិតនៅក្នុងបរិបទប្រវត្តិសាស្ត្រ។ លោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការឆ្លើយតបទៅនឹងសេចក្តីជំទាស់ទាំងពីរផ្នែក។ សេចក្តីជំទាស់ទៅនឹងសេចក្តីជំទាស់

របស់តំណាងសហព្រះរាជអាជ្ញា និងសេចក្ដីជំទាស់ផ្សេងទៀតដែលមេធាវីការពារក្ដីបានបង្ហាញចំពោះឯកសារមួយចំនួនក្នុងចំណោមឯកសារទាំង៤៨។

[១១:១៧:៣៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯលេ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបទៅនឹងខាងលោក អៀង សារី ព្រោះថាខាងក្រុម នួន ជា មិនបានធ្វើការអត្ថាធិប្បាយអ្វីទេ។ ទាក់ទងទៅនឹងការលើកឡើងរបស់លោកមេធាវី កាណាវាស យើងសូមជំទាស់ជាបឋមទៅនឹងការសរសេរជំទាស់ជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះទាក់ទងនឹងឯកសារទាំង៤៨របស់យើង។ យើងត្រូវពិភាក្សាដេញដោលពេលនេះតែម្ដង មិនបាច់សរសេរលាយលក្ខណ៍ជាអក្សរអីនោះទេ។ សូម -- បញ្ហាគឺថាទាក់ទងទៅនឹងឯកសារផ្សេងមួយចំនួនទៀត គឺថាទាំង៩៤ ដែលយើងនឹងស្នើ ដែលជាឯកសារបន្ថែមទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ ហើយនិងទួលពោធិ៍ជ្រៃ។ បើសិនជាយើងមិនអាចពិភាក្សានៅពេលព្រឹកនេះនោះទេនោះ គឺថាយើង -- អង្គជំនុំជម្រះនឹងសុំឲ្យធ្វើសេចក្ដីសម្រេចមួយថា តើខាងការពារក្ដីអាចសរសេរជំទាស់ជាលាយលក្ខណ៍អក្សរដែលឬក៏អត់? ចំពោះភាគីទាំងអស់ដែលទាក់ទងនឹងឯកសារនេះ។ អ្វីដែលខ្ញុំចង់លើកឡើងនោះគឺថា តាំងពីថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០១២ យើងបានធ្វើអ្វីដែលយើងចាត់ទុកថាជាបញ្ជីដែលជាកម្មវត្ថុនៃការពិភាក្សាដេញដោលយើងនេះ។ ភាគី -- គ្មានភាគីណាមួយខាងការពារក្ដីឆ្លើយតបនោះទេ ហើយពុំមានអ្នកណាចង់ធ្វើការជំទាស់អ្វីនោះទេ ឬក៏ជំទាស់ទាក់ទងទៅនឹងចំនួនឯកសារទាំងអស់នេះនោះទេ ក៏ប៉ុន្តែឥឡូវនេះយើងនិយាយអំពីការជំទាស់ជាលាយលក្ខណ៍អក្សរ។ ហើយខ្ញុំគិតថានេះដូចជាចាកប្រធានទាំងស្រុងតែម្ដង មិនគួរនិយាយយ៉ាងដូច្នេះទេ។

[១១:១៩:២៣]

យើងៗបានស្ដាប់អម្បាញ់មិញនេះ ឃើញថាការជំទាស់នុ៎ងវាអត់មានមូលដ្ឋានច្បាស់លាស់។ មេធាវី កាណាវាស អម្បាញ់មិញលើកឡើងមកគឺបង្កឲ្យមានបញ្ហាមួយទៀត ពេលដែលខ្ញុំស្ដាប់ឮគាត់និយាយនោះគឺខ្ញុំហាក់ដូចជាថាយើងៗនិយាយរឿងពី ១ឆ្នាំមុនអីចឹង។ ដូចពីខែមីនា ឆ្នាំ២០១២ គឺថាតាមខ្ញុំចាំគឺថាមានការប្រជុំ -- មានសេចក្ដីសម្រេចបីរបស់អង្គជំនុំជម្រះដែលក្រុម អៀង សារី នេះមិនគិតទាល់តែសោះ។ នៅក្នុងសេចក្ដីសម្រេចទាំងអស់នោះគឺថាការជំទាស់ ដែលធ្វើឡើងដោយពុំមានមូលដ្ឋានច្បាស់លាស់ ហើយដែលមិនអាចឲ្យយើងឈានទៅមុខបាននោះទេ ព្រោះថាការជំទាស់ទាំងអស់នេះត្រូវ

តែធ្វើជាលម្អិតឲ្យជាក់លាក់ ហើយធ្វើយ៉ាងណាដើម្បីឲ្យឯកសារទាំងអស់នោះ ថាអាចចាត់ទុកថាមិនអាចទទួលយកបាន។

ហើយឃើញការជំទាស់របស់ក្រុម អៀង សារី នេះមិនច្បាស់លាស់នោះទេ មិនជាក់លាក់នោះទេ ដើម្បីឲ្យអង្គជំនុំជម្រះប្តូរសេចក្តីសម្រេចរបស់ខ្លួន ហើយដើម្បីអាចទទួលយកបាននូវឯកសាររបស់សហព្រះរាជអាជ្ញា ដែលបង្ហាញកាលពីឆ្នាំមុន។

[១១:២០:៥២]

បាទ ឥឡូវខ្ញុំសូមនិយាយពីបញ្ហាលម្អិត ពីចំណុចលម្អិតដែលក្រុមមេធាវីលោក អៀង សារី បានលើកឡើង។ ខ្ញុំសូមកត់សម្គាល់ថា នៅក្នុងបញ្ជីទាំង៤៨ នៃឧបសម្ព័ន្ធ១ E223/2/1.1។ គឺថាមិនមានការបញ្ជាក់ជាក់លាក់នោះទេ នៅក្នុងតារាងដែលឯកសារទាំង៤៨ នេះគឺថាមិន -- បាទ អត់ឃើញនិយាយអំពីខ្លឹមសារពាក្យពេចន៍របស់សហចៅក្រមស៊ើបនោះទេ។ មានឯកសាររបស់សហចៅក្រមស៊ើបអង្កេតមួយដែលមាននៅក្នុង*ហ្វូតណូត*របស់ឯកសារ -- ដីកាដំណោះស្រាយដែលទាក់ទងទៅនឹងស្ថានភាពទីតាំងភូមិសាស្ត្រទួលពោធិ៍ជ្រៃ។

ខ្ញុំសូមរំឭកថា ឯកសារដែលជាកម្មវត្ថុនៃ -- ដែលជាសម្រង់នៅក្នុង*ហ្វូតណូត*ដីកាដំណោះស្រាយនេះ មិន -- វាមាន គេហៅថា យើងត្រូវទទួលអាចទុកយកបាន យើងសន្មតថាចាត់ទុកយកបានពីព្រោះនេះជារបស់ចៅក្រមស៊ើបអង្កេត។ ហើយពីព្រោះថាគាត់បានធ្វើការងារនេះយ៉ាងលម្អិត យ៉ាងយកចិត្តទុកដាក់។ ហើយទាក់ទងទៅនឹងការជំទាស់ជាក់លាក់ ចំណុចជំទាស់ជាក់លាក់របស់ខាងមេធាវីលោក អៀង សារី នេះត្រូវឲ្យមានៗមូលដ្ឋានច្បាស់លាស់។

[១១:២២:២៦]

ឯកសារមួយទៀត ខ្ញុំសូមរំឭកថា អ្វីដែលអង្គជំនុំជម្រះបានលើកឡើងនៅក្នុងឯកសារ E3/185 កថាខណ្ឌ២៥, ២១, ២៣ -- ២១ ទៅដល់៣១។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឯកសារ E185/1 ហើយអង្គជំនុំជម្រះបានលើកឡើងយ៉ាងដូច្នេះ ទាក់ទងទៅនឹងប្រភេទឯកសារមួយចំនួន ខ្ញុំសូមដកស្រង់ "ពុំមានៗ លក្ខខណ្ឌតម្រូវណាមួយក្នុងក្របខណ្ឌច្បាប់នៅអ.វ.ត.ក ដែលថាឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែជាឯកសារដែលមានទំនាក់ទំនងជាមួយនឹងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ទន្ទឹងនឹងនោះ ប្រភពឯកសារនានាដូចជា សៀវភៅ ឬឯកសារវិភាគ ឬក៏ភាពយន្តឯកសារ ឬក៏អត្ថបទសារព័ត៌មាននោះ អាចត្រូវបានចាត់ទុកយកនោះក្នុងអង្គជំនុំជម្រះក៏

ពិចារណាអំពីតម្លៃ និងទម្ងន់នៃភស្តុតាងសមស្របទៅតាមប្រភពនៃឯកសារទាំងនេះដែរ ហើយតាមពេលវេលាសមស្រប"។ ដូច្នេះក្នុងកថាខណ្ឌនេះមិនបានតម្រូវអ្នកនិពន្ធមកផ្ដល់សក្ខីកម្មនេះទេ មិនចាំបាច់អ៊ីចឹង ដើម្បីទទួលស្គាល់ឯកសាររបស់គាត់នោះទេ។

[១១:២៤:០៥]

បាទ ខ្ញុំគិតថាៗ ខាងមេធាវីលោក អៀង សារី បាន -- អំមិញនេះគាត់និយាយថា "អ្នកនិពន្ធទាំងអស់ត្រូវតែមកផ្ដល់សក្ខីកម្ម"។ គាត់លើកឡើងពីអ្នកនិពន្ធ អូស្បូន ហើយខ្ញុំសូមរំឭកផងដែរថា គឺខាងមេធាវី អៀង សារី នេះហើយដែលបានស្នើឲ្យដាក់សៀវភៅរបស់លោក អូស្បូន នេះដែល -- លេខកូដគឺថា E190/1.2 (ស៊ីក)។ អ្វីដែលខ្ញុំយល់ នេះគឺថា បើសិន មីលតុន អូស្បូន មិនមកនោះទេ មេធាវី អៀង សារី ជំទាស់មិនទទួលយកសៀវភៅរបស់គាត់នោះទេ។

បាទ ឥឡូវនេះខ្ញុំសូមឆ្លើយតបទៅនឹងការជំទាស់គ្មានមូលដ្ឋានរបស់ក្រុមលោក អៀង សារី ទៀត។ ខ្ញុំសូមចាប់ផ្ដើមនិយាយអំពីចម្លើយសារភាពចេញពីមន្ទីរស-២១។ ខ្ញុំឃើញថា អង្គជំនុំជម្រះមានគោលជំហរច្បាស់លាស់ហើយ ហើយសហព្រះរាជអាជ្ញាក៏មានគោលជំហរច្បាស់លាស់ដែរ គឺថាយើងទាំងអស់គ្នាឯកភាពគ្នាថា ឯកសារដែលទទួលបានក្រោមការធ្វើទារុណកម្មមិនអាចទទួលយកបានទេ។ ក៏ប៉ុន្តែមានរបៀបប្រើប្រាស់មួយចំនួន ដែលអាចទទួលយកបានមាត្រា១៥ ទាក់ទងនឹងការធ្វើទារុណកម្មមានចែងយ៉ាងច្បាស់លាស់ គឺឯកសារ IS5.73 ដែលជាចម្លើយសារភាពរបស់ មូល សំបាត់ ហៅ ហ៊ូ នឹម *(ស៊ីក)* ដែលជាលេខាភូមិភាគពាយ័ព្យ។ ចុះនៅថ្ងៃទី១៤ ខែ៦ ឆ្នាំ៧៨ ហើយអង្គជំនុំជម្រះក៏បានសម្រេចទទួលស្គាល់ឯកសារសារភាពទាំងអស់នេះផងដែរនៅក្នុងឯកសារ E3/1854។ ហើយនៅក្នុងកថាខណ្ឌ២១(៩) នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនេះ ដែលចុះនៅថ្ងៃទី៩ មេសា ឆ្នាំ២០០៩ គឺទាក់ទងនិយាយអំពីឧបសម្ព័ន្ធពី១ ដល់ ៥។

[១១:២៦:៣៨]

ទាក់ទងនឹងចម្លើយនេះគឺថា ការទទួលស្គាល់វាមានលក្ខណៈរឹតត្បិត អ៊ីចឹងយើងយល់ស្របហើយយើងក៏ស្របនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះផងដែរថា វាមិនអាចប្រើបានទាំងអស់នោះទេ។ ក៏ប៉ុន្តែខ្ញុំសូមរំឭកផងដែរថា ការ តាមមាត្រា១៥ នៃកតិកាសញ្ញានោះគឺថា យើងអាចយកចំណុចមួយចំនួនមកប្រើបាន ដោយមិនយកពីខ្លឹមសារនៃដីកាសារភាព ចម្លើយសារភាពនោះទេ។ ហើយម្យ៉ាងទៀតនៅលើចម្លើយសារភាពនៅមន្ទីរស-២១ គឺថាមានចំណារ។ ដូច្នេះយើងអាចប្រើចំណារនេះបាន

យើងមិនអាចយកខ្លឹមសារមកប្រើទេ ពីព្រោះថាអ្នកទោសនោះត្រូវបានគេធ្វើទារុណកម្ម។

ចំណុចមួយទៀតគឺថា ឯកសារ IS5.63 ដែលចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមាននៅក្នុងហ្វូតណូតផងដែរ គឺថា ដូច្នេះយើងអាចសន្មតថា វាមានភាពពាក់ព័ន្ធ ហើយនិងភាពគួរឲ្យទុកចិត្តបាន។ ដូចខ្ញុំបញ្ជាក់ហើយថា ឯកសារនេះគឺថា សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថាមាន អាចទុកចិត្តបាន ហើយមានភាពពាក់ព័ន្ធ ហើយវិធីសាស្ត្រនៃការធ្វើការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ទុកចិត្តបានដែរ។ ដូច្នេះយើងវាមិនមានទំនងទេ ដែលថា យើងសន្មតថាឯកសារទាំងអស់នោះត្រូវបានគេក្លែង ឬក៏កែប្រែនោះ។ ហើយយើងក៏បានស្តាប់ចម្លើយប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងអនុប្រធានផងដែរ។

ចំណុចទី៣ ចម្លើយដែលទទួលបានពីមន្ទីរស-២១ គឺថាចម្លើយរបស់ មូល សំបាត់ ហៅ ហ៊ូ នឹម *(ស៊ុក)* មានបង្ហាញអំពីលក្ខណៈពិសេសនៃចម្លើយសារភាពផ្សេងៗផងដែរ។ ឧទាហរណ៍ដូចជាទំហំ ហើយមានសរសេរជាអក្សរអង្គុលីលេខ ឬក៏មានផ្នែកណាដែលជាចំណារសរសេរជាដៃ។ ដូច្នេះនេះ គឺថាវាមានលក្ខណៈជាក់លាក់ ហើយពេលយើងឃើញមានអក្សរ ហត្ថលេខារបស់ ហ៊ូ នឹម ផងដែរនៅក្នុងឯកសារគាត់នេះ។

[១១:២៩:៣៦]

កាំង ហ្កេកអ៊ាវ ហៅឌុច នោះក៏ទទួលស្គាល់ពីយថាភាពនៃចម្លើយសារភាពនៅមន្ទីរស-២១ ផងដែរ នៅក្នុងសវនាការយើងនេះ។ ដូច្នេះវាបញ្ជាក់អំពីទម្រង់បែបបទដូចគ្នាទៅនឹងចម្លើយសារភាពផ្សេងទៀត។ ហើយទាក់ទងទៅនឹងចម្លើយសារភាពនៅមន្ទីរស-២១ ដដែល គឺថាការចាប់ មូល សំបាត់ ហៅ ហ៊ូ នឹម *(ស៊ុក)* នេះ វាប្រទាក់ក្រឡាគ្នានឹងចម្លើយសារភាពផ្សេងទៀត ដែលបានមកផ្តល់នៅនេះ នៅថ្ងៃទី២៥ ធ្នូ នៅឆ្នាំ២០០៩ -- វិច្ឆិកា (សូមទោស) នៅក្នុងសំណុំរឿង ០០១។ នេះនៅក្នុងប្រតិចារឹកទំព័រ៥៥ ហើយនិងបន្ទាត់ទី២២ ជាភាសាអង់គ្លេស។ ខ្ញុំសូមអានជាភាសាអង់គ្លេស "បន្ទាប់ពី ស៊ី ត្រូវបានគេចាប់ខ្លួន ញឹម ក៏ត្រូវបានគេចាប់ខ្លួនផងដែរ។ ញឹម ត្រូវបានចាប់ខ្លួនប្រហែលជានៅក្នុងខែ៥ ឆ្នាំ១៩៧៨។ ញឹម ត្រូវបានគេចាប់ខ្លួននៅពេលដែល ម៉ុក ត្រូវបានគេតែងតាំងទៅធ្វើជាលេខាភូមិភាគឧត្តរ -- ភូមិភាគនិរតី។" សូមបញ្ចប់ការដកស្រង់។

បាទ ដូច្នេះវាប្រទាក់ក្រឡាគ្នា គឺថា ព្រោះការបង្ហាញឲ្យឃើញថា នៅកាលបរិច្ឆេទនេះ ២៥ ធ្នូ -- កាលបរិច្ឆេទថា នៅខែប្រហែលជាក្នុងខែឧសភា ១៩៧៨ នេះ។ អ៊ីចឹងបញ្ជាក់ថា ត្រឹមត្រូវ។ ខ្ញុំមិន

និយាយវែងឆ្ងាយទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនោះទេ ដោយសារពុំមានការជំទាស់អ្វីនោះទេ ក៏ប៉ុន្តែមានការជំទាស់ទៅនឹងខ្សែអាត់វីដេអូ។

[១១:៣១:៤០]

ហើយឥឡូវទាក់ទងទៅនឹងប្រវត្តិរូបរបស់ ឡុង នរិន្ទ។ ឡុង នរិន្ទ បានមកផ្តល់សក្ខីកម្មនៅថ្ងៃទី២០ -- ថ្ងៃទី៨ ធ្នូ ឆ្នាំ២០១១ យើងបានពិភាក្សាអំពីប្រវត្តិរូបរបស់គាត់នៅទីនេះផងដែរ។ ហើយគាត់ក៏បានបញ្ជាក់ដែរ អ៊ីចឹងខ្ញុំគិតថា ដូចជាមិនមានបញ្ហាអ្វីចោទនោះទេ គឺថាឯកសារជីវប្រវត្តិគាត់ហ្នឹង គឺថា E3/128 ហើយនៅមានជាប្រតិចារឹកផងដែរ នៅក្នុងតុលាការយើងនេះ កាលណោះលោកលីសាក់ បានចោទសំណួរទៅគាត់។

ទាក់ទងទៅនឹងឯកសារដែលលោក ថេត សម្បត្តិ បានធ្វើ ដែលថា ធ្វើចេញពីការសម្ភាសន៍ជាង ១.០០០ម៉ោង ជាមួយលោក នួន ជា នោះ ប្រាំមួយ កាលពី៦ឆ្នាំមុននោះ។ ឯកសារនេះ សហព្រះរាជអាជ្ញាបានបង្ហាញហើយ ហើយសុំឲ្យគាត់មកផ្តល់សក្ខីកម្មផងដែរ។ ទី១ គឺថាមានឯកសារ E186 ដែលគាត់ធ្វើរឿងនេះជាមួយនឹង *អ៊ឹមផ្គេត* (តាមសំឡេងបកប្រែ)។ បាទ ដូច្នេះរឿង -- កាលណាយើងធ្វើរឿងមួយ យើងត្រូវតែដំឡើងរឿងហើយ រឿងសម្ភាសដល់តែ ១.០០០ម៉ោងជាងឯណោះ។ នៅក្នុងនុំងគឺថាមានចម្លើយរបស់លោក នួន ជា ហើយយើងអាចនិយាយថា ការដំឡើងរឿងហ្នឹងវាមិនល្អ វាកាត់តក៏ប៉ុន្តែចម្លើយរបស់គាត់សុទ្ធតែបានចុះ ថតជាខ្សែអាត់ទាំងអស់ ហើយនិងបង្ហាញនៅក្នុងរឿងហ្នឹងហើយ។ ការភាពពាក់ព័ន្ធ ហើយនិងយថាភាពនៃការសម្ភាសរបស់លោក នួន ជា នេះ យើងមិនអាចយកមកធ្វើជាការសង្ស័យបានទេ។

[១១:៣៣:៤៣]

នៅក្នុងសវនាការថ្ងៃទី១៤ ធ្នូ ឆ្នាំ២០១១ គឺឯកសារ E1/222.1 ចាប់ពីម៉ោង១១:៤៥ នួន ជា បានទទួលស្គាល់ថា "គាត់ទទួលស្គាល់ថាធ្លាប់បានសម្ភាសដោយ ថេត សម្បត្តិ ហើយ" ហើយគាត់ក៏បានទទួលស្គាល់ផងដែរថា នៅពេលដែលគាត់សន្ទនាជាមួយ ថេត សម្បត្តិ ថាគាត់និយាយការពិតហើយ គឺថា ម៉ោង ១១:៤៧ ហើយគាត់ថា គាត់ទុកចិត្ត ថេត សម្បត្តិ នេះ ទោះបីជាគាត់មិនដឹងថា ថេត សម្បត្តិ នេះនឹងធ្វើរឿងកុនឯកសារ ហើយនិងផ្សព្វផ្សាយទៅខាងក្រៅក៏ដោយ។ បន្ទាប់មកទៀត នួន ជា បានធ្វើការអត្ថាធិប្បាយទៅលើសៀវភៅមួយទៀត ដែលគាត់បានសរសេរ ហើយខ្ញុំនឹងនិយាយពីចំណុចនេះនៅពេលក្រោយ។ ឯកសារ E186.1R ហើយនិងមានផ្នែកបន្ថែមនេះនៃរឿងនេះ មាន

លក្ខណៈសំខាន់ណាស់ គឺថាមានបង្ហាញអំពីប្រព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងការរកខ្មាំង និងកម្ចាត់ខ្មាំង។ នេះជាគោលនយោបាយខ្មែរក្រហម ដែលជាកម្មវត្ថុនៃការជម្រះសេចក្តីយើងនេះ។

[១១:៣៥:១០]

មានចំណុចផ្សេងទៀតដែលទាក់ទងនឹងរបបខ្មែរក្រហមតែម្តង ឧទាហរណ៍ដូចជាបរិបទប្រវត្តិ-សាស្ត្រពីមុន នៃរបបមុន ហើយនិងការរៀបចំអំណាចនៅក្នុងរបបខ្មែរក្រហមនេះ។ ម្យ៉ាងវិញទៀត ខ្ញុំសូមរំឭកផងដែរថា យើងបានបង្ហាញសម្រង់រឿងខ្សែភាពយន្តនេះហើយ នៅក្នុងតុលាការយើងនេះដោយសហមេធាវីនាំមុខ។ ហើយកាលណោះក្រុមមេធាវីការពារក្តីមិនបានជំទាស់ទេ។

មានឯកសារមួយទៀតរបស់លោក ថេត សម្បត្តិ គឺខ្សែវីដេអូដែលមានលេខ E193 ប្រាំបួន -- គឺE93/7.3R ហើយនិងឯកសារមួយទៀតគឺ E93/7.2R។ ហើយកាលណោះ ខាងបានលើកឡើងថាអត់មានកុនទាំងអស់នេះទាំងស្រុងទេ ហើយតាំងពីដើមដល់ចប់ទេ។ ការ -- គឺថា ថេត សម្បត្តិ សម្ភាសគាត់ជាច្រើនឆ្នាំ ប៉ុន្តែយើងមិនមានខ្សែអាត់ជាកុននេះទាំងអស់នោះទេ។ នៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា គឺថាឯកសារ E93/7 អង្កាល់ណោះ កុននេះមិនទាន់មាននោះទេ គឺថាមាននៅតែក្នុង*យូធូប*នោះទេ។ អ៊ីចឹងគឺថា យើងចង់ឲ្យសម្រង់ខ្សែភាពយន្តនេះបញ្ចូលទៅក្នុងសំណុំរឿង ហើយនិងប្រតិចារឹកនៃសម្រង់ខ្សែភាពយន្តនេះផងដែរ។ កាលនោះ គឺយើងមានប្រតិចារឹកប្រហែលជាចំនួនបីទំព័រធ្វើជាលាយលក្ខណ៍អក្សរគឺថាឯកសារ E93/7.2 នេះវាជាខ្លឹមសារនៃសម្រង់ខ្សែភាពយន្តហ្នឹង។

[១១:៣៧:២៣]

បាទ ឥឡូវខ្ញុំនិយាយអំពីសៀវភៅរបស់លោក ថេត សម្បត្តិ ដែលសរសេរជាមួយមនុស្សម្នាក់ទៀត ដែលថានៅក្រោយវាលពិឃាដ -- ចំណងជើង "នៅក្រោយវាលពិឃាដ *ប៊ីហាញ ឌី ឃាលលីងហ្វៀល*"។ គាត់បានធ្វើសំណើជាក់លាក់មួយ គឺថាដែលទាក់ទងទៅនឹងសៀវភៅរបស់គាត់ ហើយនិងទាក់ទងនឹងខ្សែវីដេអូ ទាក់ទងនឹងលោក ខៀវ សំផន។ អង្គជំនុំជម្រះកាលនោះបានទទួលឲ្យដាក់ចូលក្នុងសំណុំរឿង។ កាលណោះ នៅក្នុងសំណើរបស់យើងនោះ យើងបានបញ្ជាក់ថា សៀវភៅនេះសរសេរចេញពីការសម្ភាសជាច្រើនម៉ោង ហើយនៅក្នុងដើមសៀវភៅនោះក៏មានបង្ហាញពីមូលហេតុផងដែរបង្ហាញថា គឺថាសរសេរសៀវភៅនេះឡើង ដោយសារសម្ភាសជាង១.០០០ម៉ោង។ សៀវភៅ -- ក្នុងសៀវភៅនេះគឺថា ភាគច្រើនមានការដកស្រង់ពាក្យសម្តីរបស់លោក នួន ជា ជាច្រើន។ ហើយដោយបង្ហាញពីមតិយោបល់របស់លោក នួន ជា តាំងពីដើម ពីសម័យចូលព្រៃម៉ាគី រហូតដល់របបកម្ពុជា

ប្រជាធិបតេយ្យ ហើយនិងមានក្នុងសៀវភៅនេះ បង្ហាញពីមុខងាររបស់ជនចាប់ចោទមុនឆ្នាំ៧៥ និងក្រោយឆ្នាំ៧៥ ហើយទាក់ទងនឹងរចនាសម្ព័ន្ធនយោបាយសម័យកម្ពុជាប្រជាធិបតេយ្យ ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំរបស់ប្រជាជន។

ដូច្នេះ សៀវភៅនេះវាមានភាពពាក់ព័ន្ធ ដូច្នេះត្រូវតែទទួលស្គាល់ដោយអង្គជំនុំជម្រះ ព្រោះថាវាគោរពទៅតាមយុត្តិសាស្ត្ររបស់តុលាការដែលបានលើកឡើងថា មិនទាល់ -- គឺថាមិនចាំបាច់ឲ្យអ្នកនិពន្ធមកបានទទួលស្គាល់សៀវភៅនោះទេ។ គ្រាន់តែទន្ទឹមនឹងនេះ យើងសូមឲ្យអង្គជំនុំជម្រះកោះហៅអ្នកនិពន្ធទាំងអស់នេះមកផ្តល់សក្ខីកម្មផងដែរ។

[១១:៣៩:៤៣]

អ្វីដែលយើងអាចឲ្យយើងដោះស្រាយបញ្ហាសៀវភៅនេះបាន យើងត្រូវដឹងថា តើអ្នកណាជាអ្នកនិពន្ធពិតប្រាកដនោះ ពីព្រោះថាកាលសវនាការថ្ងៃទី១៤ ធ្នូ ឆ្នាំ២០១១ គឺប្រតិចារឹក E1/22.1 អង្កាល់ណោះ នៅម៉ោងដប់ពីរ នួន ជា បាននិយាយយ៉ាងដូច្នេះ។

ហើយអ្វីដែលគាត់និយាយនេះអាចបង្ហាញថាពីភាពទុកចិត្តនៃសៀវភៅនេះបាន។ "ខ្ញុំសរសេរសៀវភៅប្រវត្តិរូប ហើយខ្ញុំសូមឲ្យ ថេត សម្បត្តិ បោះពុម្ពផ្សាយសៀវភៅនេះ គឺថាប្រវត្តិរូបបោះពុម្ពនៅកម្ពុជា"។ គាត់និយាយថា "បោះពុម្ពនៅអាមេរិក ព្រោះថាខ្មែរយើងមិនចូលចិត្តអានទេនៅស្រុកខ្មែរនោះ។ ខ្ញុំសរសេរសៀវភៅនេះលើរបបនេះ របបខ្មែរក្រហម ហើយ ថេត សម្បត្តិ បកប្រែសៀវភៅនេះជាភាសាអង់គ្លេស"។ សូមបញ្ចប់ការដកស្រង់។ ហើយបន្ទាប់មកទៀតគាត់និយាយ ហើយក្រោយមក នួន ជា បានត្អូញត្អែរថាបោះពុម្ពសៀវភៅនេះមិនមានការអនុញ្ញាតពីគាត់ ក៏ប៉ុន្តែទោះយ៉ាងណាក្តីចម្លើយរបស់ នួន ជា បង្ហាញពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងសៀវភៅរបស់ ថេត សម្បត្តិ ហើយនិងការសម្ភាស ឬក៏ប្រវត្តិរូបដែលសរសេរដោយ នួន ជា។ អាស្រ័យហេតុដូច្នេះហើយបានថា វាមានប្រយោជន៍ក្នុងការរកការពិតបាន ហើយអ៊ីចឹងត្រូវតែទទួលស្គាល់សៀវភៅនេះ ដោយមិនចាំបាច់ទាល់តែអ្នកនិពន្ធមកផ្តល់សក្ខីកម្មនៅទីនេះនោះទេ។

[១១:៤១:១៨]

ឥឡូវខ្ញុំសូមនិយាយអំពីការជំទាស់របស់លោកមេធាវីតំណាងឲ្យលោក ខៀវ សំផន។ គាត់ដែលជំទាស់ទៅនឹងការសម្ភាសទាំង៥៤។ ហើយដោយគាត់លើកឡើងថាដោយពុំមានបង្ហាញពីលក្ខខណ្ឌនៃការសម្ភាស ឬក៏ការបរិបទនោះទេ ក៏មិន វាមិនខុសទាំងស្រុងនោះទេ គេ -- ប៉ុន្តែយើង -- គាត់និយាយ

អំពីតែតម្លៃភស្តុតាងនោះទេ ហើយក៏ក្រុមមេធាវីលោក ខៀវ សំផន មិនបាននិយាយអំពីការដាក់ចូលក្នុងសំណុំរឿងនោះទេ។

ឯកសារ E152.1.1R ទៅដល់ឯកសារ E152.1.54R ហើយនិងការធ្វើប្រតិចារឹកនៃខ្សែអាត់ទាំងអស់នេះ គឺថាពីឯកសារ E152.1.1 ទៅដល់ឯកសារ E152.1.54.1 នេះគឺជាឯកសារវីដេអូទាំង ៥៤ ដែលសម្ភាសអស់រយៈពេល៨ម៉ោងជាង។ រូបអ្នកដែលយើងមើលឃើញនៅក្នុងលើអេក្រង់មានរូប ខៀវ សំផន នោះទេ។ អ៊ីចឹងការធ្វើឡើងនេះប្រហែលជាធ្វើពីអស់រយៈពេលជាង២ថ្ងៃ ឯកសារវីដេអូទាំង៥៤ នេះ គឺថាយើងដាក់បញ្ចូលទៅក្នុងតារាងតែមួយ គឺថាឯកសារ E20 -- បាទ សហព្រះរាជអាជ្ញាបានដាក់បង្ហាញនូវអំណះអំណាងរបស់ខ្លួនមួយចំនួននៅក្នុងឯកសារ E152 ដោយសារថាសម្រង់ខ្សែវីដេអូទាំងអស់នេះទាក់ទងទៅនឹងភាពពាក់ព័ន្ធ។ សូមទោស គឺថាបរិបទប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ និងតួនាទីទំនួលខុសត្រូវរបស់ជនជាប់ចោទ ហើយនិងរចនាសម្ព័ន្ធរបបហ្នឹង ហើយនិងគោលនយោបាយផ្សេងៗទាក់ទងទៅនឹងការជម្លៀសប្រជាជន។ បើយើងមិនដឹងថាអ្នកណាជាអ្នកកាសែតដែលសួរលោក ខៀវ សំផន ទេ ប៉ុន្តែយើងឮសំឡេងសួរ ជាសំណួរទៅគាត់ គឺថា -- អ៊ីចឹងយើងឮសំឡេងសួរ។ អ៊ីចឹងក៏ប៉ុន្តែមិនមានអត្តសញ្ញាណគាត់ទេ ក៏ប៉ុន្តែយើងដឹងថា យើងដឹងយ៉ាងហោចណាស់ក៏យើងដឹងថាជា ខៀវ សំផន និយាយ។ យើង -- អ៊ីចឹងវាមិនសមស្របទេ ក្នុងការនិយាយថាឯកសារនេះជាឯកសារក្លែងក្លាយនោះ។

[១១:៤៤:១៣]

អ៊ីចឹងខ្ញុំសូមឲ្យតុលាការទទួលស្គាល់ខ្សែអាត់ហ្នឹង ប្រតិចារឹកហ្នឹងឲ្យទទួលយកដាក់ទៅក្នុងសំណុំរឿង។ ឥឡូវនេះទាក់ទងទៅនឹងសំបុត្រដែលសរសេរគាំទ្រលោក ខៀវ សំផន និយាយល្អ ពី ខៀវ សំផន ខាងមេធាវីលោក ខៀវ សំផន បានសុំកោះហៅពួកគាត់មកទីនេះ។ អ៊ីចឹងខ្ញុំគិតថាជាសមស្របដែរ ក៏ប៉ុន្តែទោះយ៉ាងណាត្រូវតែ អង្គជំនុំជម្រះត្រូវតែបញ្ជាក់អំពីលក្ខខណ្ឌដែលកោះហៅពួកអ្នកទាំងអស់នេះមក។ បាទ សូមអរគុណលោកប្រធាន ខ្ញុំឆ្លើយតបទៅនឹងការជំទាស់ទាំងអស់នេះអស់ហើយ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីវិញយ៉ាងម៉េចដែរ? សូមៗឲ្យមេធាវី -- វេទិកាទៅមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាមុនសិន ដើម្បីឲ្យវាស្របគ្នា

ពីព្រោះគាត់អាចបង្ហាញបន្ថែមទៀតលើសេចក្តីជំទាស់ ឬក៏ទៅលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា។

[១១:៤៥:៣៨]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល សាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណី! យើងខ្ញុំនឹងធ្វើការលើកឡើងបន្តិចពាក់ព័ន្ធទៅនឹងករណីជំទាស់របស់លោកមេធាវី កាណាវាស ហើយនិងលោកស្រីមេធាវី អង់តា ហ្គីសសេ ពាក់ព័ន្ធទៅនឹងឯកសារទី១០ និងឯកសារទី១១ ដែលជាវីដេអូ។ ហើយលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងលើកបំពេញបន្ថែម ប្រសិនបើថាបើលោកមាន។ ពាក់ព័ន្ធទៅនឹងឯកសារទាំងពីរ ឯកសារវីដេអូទាំងពីរនេះ អ្វីដែលត្រូវបានលើកឡើងគឺថាជាឯកសារដែលៗធ្វើឡើងដោយមានការថតជាវីដេអូច្រើនម៉ោង ហើយបញ្ហាសំណួរមិនដឹងថា តើមានសំណួរត្រូវបាន -- ត្រូវនឹងចម្លើយ ហើយមិនដឹងថាលក្ខខណ្ឌណាដែលឯកសារទាំងអស់នោះត្រូវបានថតឡើង ឬក៏ត្រូវបានធ្វើឡើង។

[១១:៤៦:៤៣]

តាមការពិនិត្យមើលទៅលើការជំទាស់នេះមិនមានការផ្តល់នូវមូលហេតុសមស្រប មានន័យថាមិនមានមូលដ្ឋានគ្រប់គ្រាន់ទេ។ ហើយមិនបានបង្ហាញថា តើនៅកន្លែងណាមួយនៅក្នុងខ្សែវីដេអូទាំងអស់នោះត្រូវបានធ្វើដោយមានៗអនិយ្យភាពនោះទេ។ ហើយវីដេអូទាំងអស់នេះគឺនិយាយអំពីការថតផ្ទាល់ទៅលើសកម្មភាពរបស់ជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន ដែលគាត់មានសេរីភាពនៅក្នុងការនិយាយដោយសេរីនៅចំពោះមុខអ្នកដែលបានថតគាត់ ហើយនេះបញ្ជាក់អំពីភាពត្រឹមត្រូវនៃសម្តីរបស់អ្នកទាំងនោះដោយអាចធ្វើឲ្យមានតម្លៃជាភស្តុតាង។

[១១:៤៧:៣៨]

ហើយចំណុចទី២ គឺថាដោយសារឯកសារទាំងអស់នេះនិយាយអំពីសកម្មភាពរបស់ជនជាប់ចោទដែលជាសកម្មភាពដែលគាត់បានធ្វើឡើងនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះយើងនេះ មានន័យថាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដូច្នេះព័ត៌មានដែលនៅក្នុងឯកសារនេះ គឺជាព័ត៌មានដែលមានលក្ខណៈពាក់ព័ន្ធទៅនឹងសវនាការរបស់យើង ហើយដែលអាចទទួលយកមកធ្វើជាឯកសារភស្តុតាងសម្រាប់ពិភាក្សា និងពិចារណាជាភស្តុតាងនៅក្នុងសវនាការនេះបាន។

ខ្ញុំមានយោបល់បំភ្លឺបន្ថែមត្រឹមប៉ុណ្ណេះ ហើយជាទូទៅក៏មានការគាំទ្រចំពោះអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអំពីភាពជាក់លាក់ ភាពពាក់ព័ន្ធនៃឯកសារដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីចៅក្រម -- លោកស្រីមេធាវី!

[១១:៤៨:៥១]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមបន្ថែមពីរបីម៉ាត់ទេ ហើយសូមឲ្យកត់ត្រាពីគោលជំហររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងទៅនឹងការជំទាស់របស់ខាងការពារក្ដី។ ខ្ញុំចង់និយាយថា ខ្ញុំមិនយល់ពីអត្ត -- ឥរិយាបថខាងការពារក្ដី ហើយក៏មិនយល់ពីគោលបំណងរបស់ពួកគាត់ផងដែរ។ អង្កាល់ចុងឆ្នាំ២០១១ គឺថាគេបានផ្ដល់លទ្ធភាពឲ្យពួកគាត់ជំទាស់ទៅនឹងឯកសារភស្ដុតាងដែលសាក្សី -- ដែលភាគីស្នើជូន។ ហើយមានសវនាការ៣ដងផងដែរ ដែលគេអញ្ជើញពួកគាត់ឲ្យសុំគាត់ធ្វើការជំទាស់ ហើយនិងផ្ដល់ព័ត៌មានជូនទាំងអស់គ្នា ហើយបន្ទាប់មកទៀតមានការចេញសេចក្ដីសម្រេចពីររបស់តុលាការគឺថាឯកសារ E185 និង E185.1 នៅក្នុងសេចក្ដីសម្រេចនេះហ្នឹង គឺថាឆ្លើយ -- មានការឆ្លើយតបទៅនឹងការជំទាស់របស់ភាគី។ ខ្ញុំសូមលើកឧទាហរណ៍ចំនួនបី ដែលសហព្រះរាជអាជ្ញាបានលើកឡើងហើយ។

ឧទាហរណ៍គឺថា កថាខណ្ឌ២១.៥ នៃឯកសារ E185 នេះដែលឆ្លើយតបទៅនឹងការជំទាស់ជាទូលំទូលាយ ដូចជាសៀវភៅ ឬក៏ខ្សែវីដេអូ ហើយនិងអត្ថបទសារព័ត៌មានជាច្រើននេះ។ ឧទាហរណ៍ទី២ គឺថា១ដែលមានលើកឡើង ថាពុំមានច្បាប់កំណត់ណា តម្រូវឲ្យអ្នកនិពន្ធមកតែដាច់ខាតនោះទេ។ អ៊ីចឹងនៅថ្ងៃនេះ គឺថានៅក្នុងបញ្ជីទាំង៤៨ឯកសាររបស់សហព្រះរាជអាជ្ញានេះ ខ្ញុំឮការជំទាស់ដដែល១ដូចដែលពីដើមមកពីដដែលនុ៎ង ហើយអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចហើយហើយ។ អ៊ីចឹងនៅលើឯកសារទាំង១៨ នេះគឺថាមានឯក -- ៤៨ នេះថាមានឯកសារ១១ ដែលព្រះរាជអា -- ខាងការពារក្ដីនេះជំទាស់ដោយបង្ហាញមូលហេតុដូចមុន១អ៊ីចឹង។

[១១:៥១:០៦]

អ្វីដែលយើងចង់បាននោះគឺថា ចង់ឲ្យអង្គជំនុំជម្រះបដិសេធការជំទាស់ដែលមានលក្ខណៈទូលាយ ដែលអង្គជំនុំជម្រះបានធ្វើសេចក្ដីសម្រេចហើយហើយ។ អ្វីដែលយើងចង់បាននោះគឺថា សូមឲ្យ

គឺថាសូមឲ្យអង្គជំនុំជម្រះកុំទទួលការជំទាស់ជាលាយលក្ខណ៍អក្សរបន្តទៀត។ បើយើងនៅតែបន្តធ្វើសវនាការនិយាយពីការជំទាស់ និងការសន្និដ្ឋាននៃការជំទាស់នោះនោះ មិនចេះចប់មិនចេះហើយនោះជា -- ដោយផ្ទាល់មាត់ ឬក៏ដោយលាយលក្ខណ៍អក្សរនោះ គឺថាយើងនឹងបាត់បង់ពេលវេលាដោយឥតប្រយោជន៍។

នេះជាគោលជំហររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុងក្រោយដោយសារពេលនៅវេលាខ្លីដែរ សូមផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដោយអម្បាញ់មិញនេះលោកស្រីបានងើបឈរឡើងក្នុងន័យបង្ហាញពីការជំទាស់ ឬមួយក៏លោកមេធាវីណាមុនក្នុងចំណោមពីរ។ បាទ សូមអញ្ជើញបាទ!

[១១:៥២:១៨]

**លោក ម៉ែខល កាណាវាស៖**

លោកប្រធាន មុនពេលដែលមេធាវី ខៀវ សំផន ឡើងខ្ញុំសូមនិយាយជាមុនសិន។ នៅក្នុងពេលកន្លងមកយើងបានសរសេរនូវការជំទាស់ជាលាយលក្ខណ៍អក្សរ។ យើងមិនមែន -- យើងមិនចង់ឲ្យមានការងារច្រើនសម្រាប់ខ្លួនយើងនោះទេ ប៉ុន្តែមេធាវីការពារក្ដីបានចំណាយពេលចុងសប្ដាហ៍ដើម្បីពិនិត្យមើលទៅលើឯកសារណាដែលត្រូវជំទាស់។ ដូច្នេះប្រសិនបើអង្គជំនុំជម្រះសាលាដំបូងផ្ដល់នូវគោលការណ៍ណែនាំដ៏ច្បាស់លាស់ ដើម្បីឲ្យភាគីដឹងថាត្រូវធ្វើដូចយ៉ាងម្ដេចនោះ គឺភាគីទាំងនឹងធ្វើ។ ប៉ុន្តែក្នុងពេលកន្លងមកយើងបានធ្វើការជំទាស់ជាលាយលក្ខណ៍អក្សរ ប៉ុន្តែហេតុអ្វីក៏ព្រះរាជអាជ្ញាបានលើកឡើងបែបនេះទៅវិញ ព្រោះថានេះជានីតិវិធី។ ដូច្នេះគួរតែផ្ដល់នូវនីតិវិធីដល់ខ្ញុំ ហើយខ្ញុំនឹងធ្វើតាម។

នេះគឺជានីតិវិធីដែលយើងបានគោរពកាលពីពេលកន្លងមក។ ខាងព្រះរាជអាជ្ញាក៏បានលើកឡើងដោយមិនមានមូលដ្ឋានដែរ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ គឺយើងបានបញ្ជាក់ថា យើងនឹងពិនិត្យមើលទៅលើឯកសារទាំងអស់នេះ ហើយគោលការណ៍របស់យើងនឹងធ្វើតាមទៅលើអ្វីដែលយើងបានធ្វើកន្លងមក។ ដូច្នេះហើយមិនចាំបាច់ឲ្យមានការបង្កើតនូវបរិយាកាសមួយ ដែលថាយើងមិនដឹងថាត្រូវធ្វើយ៉ាងដូចម្ដេចនោះទេ។ យើងសូមជម្រាបដល់អង្គជំនុំជម្រះថា សវនាការដោយផ្ទាល់មាត់ហ្នឹង គឺដើម្បីផ្ដល់ប្រយោជន៍ដល់សារធារណជន ដើម្បីសាធារណជនដឹងថាតើយើងដោះស្រាយជាមួយឯកសារណាមួយ។ យើងផ្ដល់នូវការពន្យល់ដោយសង្ខេប។ ប៉ុន្តែទាក់ទងទងទៅនឹងព័ត៌មានលម្អិត គឺយើងគួរតែផ្ដល់ជា

លាយលក្ខណ៍អក្សរ។ ប្រសិនបើមិនដូច្នេះទេ គឺអង្គជំនុំជម្រះគួរតែផ្តល់នូវការណែនាំឲ្យបានច្បាស់លាស់ ដោយរៀបរាប់ឲ្យបានលម្អិត ហើយយើងនឹងធ្វើតាម ហើយយើងនឹងគោរពតាម។

[១១:៥៤:០៧]

ប្រសិនបើយើងធ្វើខុស យើងសូមអភ័យទោស។ ប៉ុន្តែក្នុងពេលកន្លងមកហ្នឹង ក្នុងពីរសប្តាហ៍កន្លងមកហ្នឹង យើងពិនិត្យមើលទៅលើឯកសារទាំងអស់ ដើម្បីរៀបចំទៅលើចម្លើយ ដើម្បីឆ្លើយតបទៅនឹងឯកសារដែលមាននៅក្នុងឧសម្ព័ន្ធនេះ គឺគ្រប់ឯកសារទាំងអស់នេះ។ ហើយក្នុងពេលជាមួយគ្នាហ្នឹងក៏យើងធ្វើការពិនិត្យ រៀបចំសម្រាប់សាក្សីដែលយើងត្រូវផ្លាស់ប្តូរទៅវិញនោះដែរ។ ហើយយើងប្រហែលជានឹងត្រូវចូលទៅក្នុងអង្គជំនុំជម្រះតុលាការកំពូលទៀត ទាក់ទងទៅលើសេចក្តីសម្រេចរបស់សាលាដំបូង។ សូមអរគុណដល់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី!

[១១:៥៤:៥២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយសង្ខេប ចំណុចទី១ ដែលលើកឡើងដោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលសហភាតាខ្ញុំ លោក កាណាវាស បានឆ្លើយតបអម្បាញ់មិញនេះហើយ ដែលទាក់ទងទៅនឹងលទ្ធភាពនៃការធ្វើដាក់សារណា ហើយនិងការធ្វើអត្ថាធិប្បាយ ដោយខ្ញុំសូមយោងទៅលើអនុស្សរណៈខែ -- គឺថាលេខ E...

**អ្នកបកប្រែ៖**

លោកប្រធានខ្ញុំស្តាប់លេខឯកសារអំមិញអត់ទាន់លោកប្រធាន សូមអភ័យទោស។

**កញ្ញា អង់តា ហ្គីសសេ៖**

ឥឡូវខ្ញុំសូមនិយាយយឺត។ នៅក្នុងអនុស្សរណៈ E258 ចុះថ្ងៃទី១៦ មករា ២០១៣ អង្គជំនុំជម្រះបានបង្ហាញ -- គូសបញ្ជាក់ថា ទោះបីជា កូនក្តីមិនចូលមកក្នុងសាលជំនុំជម្រះនេះក៏ដោយ គឺធ្វើការសន្និដ្ឋានបន្ថែមទាក់ទងទៅនឹងកូនក្តីរបស់យើងខ្ញុំប្រសិនបើស្នើឲ្យធ្វើដូច្នេះ។ សូមបញ្ចប់ការដកស្រង់។ ហើយខ្ញុំបាន គូសបញ្ជាក់ផងដែរ ថាមុនពីដើមពេលសវនាការនេះនេះ យើងបានជម្រាបជូនហើយ ថាយើងពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យមើលឯកសារទាំង៤៨របស់សហព្រះរាជអាជ្ញាដែលជា

ឯកសារនៃជាកម្មវត្ថុនៃការពិភាក្សាយើងនេះ។ ក៏ប៉ុន្តែស្ថានភាពសុខភាពរបស់លោក ខៀវ សំផន មិនអាចឲ្យយើងធ្វើការឲ្យបានស៊ីជម្រៅលើសវនាការនិយាយពីឯកសារនេះនោះទេ ដោយសារមានការប្រែប្រួលពេលវេលា ពីព្រោះថាយើងត្រៀមថានឹង និយាយពីបញ្ហានេះនៅខែកុម្ភៈ។ ហើយខ្ញុំមិនយល់ដែរហេតុអ្វីបានជាសហព្រះរាជអាជ្ញាហ្នឹងចង់បិទទ្វារចាក់គន្លឹះតែម្តង ក្នុងខណៈដែលថាយើងអាចពិភាក្សាគ្នាបាន ហេតុអីក៏មិនឲ្យយើងមានលទ្ធភាពដាក់ឯកសារ ឬក៏ធ្វើសារណាអីនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោង មួយសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៥៧ នាទី ដល់ម៉ោង ១៣:៤០ នាទី)*

[១៣:៤០:០៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីដាក់នូវឯកសារបន្ថែមទាក់ទងទៅនឹងឯកសារផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ អ្វីដែលខ្ញុំចង់ស្នើសម្រាប់រសៀលនេះ ខ្ញុំគិតថាភាគីទាំងអស់បានទទួលការជូនដំណឹងមុនពេលសវនាការនេះហើយថា យើងនឹងនិយាយអំពីឯកសារដែលស្នើដោយសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធ៣។ ហើយខ្ញុំគិតថាភាគីទាំងអស់មានតារាងលេខ E223/2/1.2 ដែលជាតារាងសំខាន់ពាក់ព័ន្ធទៅនឹងឯកសារដែល

និយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយនិងតារាងពីរផ្សេងទៀត ដែលមានឯកសារពីរ ហើយនិងមួយទៀតឯកសារបួន ដែលលេខ E220/2/1.2 ដែលនិយាយអំពីការជម្លៀសដោយបង្ខំដំណាក់កាលទី២។

[១៣:៤២:៣៨]

ហើយនិងឯកសារមួយទៀត E223/2/1.3 បាទសូមម្តងទៀត ខ្ញុំផ្តល់លេខខុសអម្បាញ់មិញនេះ គឺ E223/2/1.3 ពាក់ព័ន្ធនឹងការជម្លៀសដំណាក់កាលទី២ ហើយនិងឯកសារ E223/2/1.4 ដែលនិយាយអំពីទួលពោធិ៍ជ្រៃ។ ដូច្នេះសូមឲ្យភាគីមានឯកសារទាំងនេះនៅក្នុងដៃ ដើម្បីឲ្យចំណេញពេលវេលា ខ្ញុំមិនចាំបាច់អានទៅលើការយោងឯកសារមួយៗនោះទេ ពីព្រោះថាឯកសារមានច្រើន។ ហើយសហព្រះរាជអាជ្ញានឹងពិនិត្យមើលថា តើមានការជំទាស់ ហើយបន្ទាប់មកយើងនឹងឆ្លើយតបទៅនឹងការជំទាស់។ ដូច្នេះ យើងខ្ញុំគិតថាមិនចាំបាច់អានឯកសារទាំង៩៤ នេះទេ។ ឯកសារនេះមាននៅក្នុងឧបសម្ព័ន្ធ ហើយភាគីទាំងអស់ក៏មាននៅក្នុងដៃរួចទៅហើយ។ សូមអរគុណលោកប្រធាន។

[១៣:៤៣:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៥:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដោយសារមានការបង្ហាញបញ្ជាក់យ៉ាងច្បាស់លាស់ហើយពីតំណាងសហព្រះរាជអាជ្ញា អំពីឯកសារទាំងឡាយដែលមានបំណងយកមកដាក់ចំពោះមុខនៅពេលនេះ ហើយឯកសារទាំងអស់នេះមាននៅក្នុងបញ្ជីឧសម្ព័ន្ធដែលបានផ្ញើជូនភាគីរួចទៅហើយ ដូចលេខឯកសារដែលតំណាងសហព្រះរាជអាជ្ញាបានរៀបរាប់ជូនអម្បាញ់មិញនេះ គឺទាំងបី គឺទី១គឺឯកសារ E222 -- E223/2/1.2, E223/2.1.3 ហើយនិង E223/2/1.4 ហើយដោយសារឯកសារនេះមាននៅក្នុងដៃ ហើយភាគីបានជ្រាបហើយ។ ដូច្នេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសនៅក្នុងការធ្វើការជំទាស់ទៅនឹងឯកសារណាមួយជាក់លាក់ ដោយបង្ហាញ គ្រាន់តែបង្ហាញទៅតាមភាពពាក់ព័ន្ធនៃឧសម្ព័ន្ធដែលបានបញ្ជាក់ជូនហ្នឹងតែប៉ុណ្ណោះ ប្រសិនបើមាន។ ហើយចាប់ផ្តើមពីមេធាវីការពារក្តីលោក នួន ជា មុន ប្រសិនបើមានបាទ សូមអញ្ជើញ!

[១៣:៤៦:៥២]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាយើងនិយាយអំពីឧសម្ព័ន្ធតែមួយដូចគ្នាហ្នឹង។ ខ្ញុំសូមបញ្ជាក់ ដោយសារតែចំនួនដែលព្រះរាជអាជ្ញាបានលើកឡើងមិនបានច្បាស់ ថាតើវាមានឯកសារដែលមាន១៤៩ទំព័រ គឺឯកសារដែលមាន៨៦ ឯកសារដែលរៀបរាប់អំពីឧសម្ព័ន្ធ២(ក) និង២(ខ) ហ្នឹង តើយើងនិយាយអំពីឯកសារតែមួយហ្នឹង ឬមួយក៏យ៉ាងម៉េចដែរ? ប្រសិនបើខ្ញុំត្រឹមត្រូវ ប្រហែលជាខ្ញុំនិយាយត្រឹមត្រូវហើយ។ គឺយើងមិនមានការជំទាស់អ្វីនោះទេ ដោយសារតែយើងមិនអាចពិភាក្សាអំពីឯកសារនេះ គឺថាយើងមិនអាចពិនិត្យមើលទៅលើខ្លឹមសារនៃឯកសារនេះជាមួយកូនក្ដីរបស់ខ្ញុំបាន ដោយសារតែហេតុទាំងអស់នេះហើយ ទើបខ្ញុំមិនទទួលបានការណែនាំណាមួយពីកូនក្ដីរបស់ខ្ញុំនៅក្នុងដំណាក់កាលនេះ។ ដូច្នេះក្នុងដំណាក់កាលនេះ គឺយើងមិនអាចបញ្ចេញមតិយោបល់ ឬក៏ធ្វើការបង្ហាញទាក់ទងទៅនឹងឯកសារទាំងអស់នេះបានទេ។

ដូច្នេះយើងសូមទទួលយកការអនុញ្ញាត ដើម្បីផ្ដល់ការដាក់ជាសារណាជាលាយលក្ខណ៍អក្សរវិញ នៅពេលដែលយើងមានលទ្ធភាពពិភាក្សាជាមួយកូនក្ដីរបស់យើង។ សូមអនុញ្ញាត។

[១៣:៤៨:១៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥០:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានទទួលយកថា ខ្លួនបានបញ្ជាក់រួចមកហើយពាក់ព័ន្ធទៅនឹងក្រុមការពារក្ដី នួន ជា និង ខៀវ សំផន ថា ក្រុមទាំងពីរហ្នឹងមានឱកាសនៅពេលក្រោយ ដើម្បីបញ្ចេញមតិយោបល់ទាក់ទងទៅនឹងឯកសារទាំងអស់នេះ។ ហើយអង្គជំនុំជម្រះនឹងប្រាប់នូវពេលវេលាកំណត់ជាក់ស្ដែង និងមធ្យោបាយនៅក្នុងការបញ្ចេញមតិយោបល់ដែលត្រូវបញ្ជូនមកអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីពីរក្រុមផ្សេងទៀត មានយោបល់អីផ្សេងទេលើឯកសារអម្បាញ់មិញនេះ?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម និងអស់លោក លោកស្រីទាំងអស់ទាំងក្នុងនិងក្រៅសវនាការ។

ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី១ គឺមាន៦៥ទំព័រ ដែលនិយាយអំពីមតិរបស់ខ្ញុំ ហើយចំណុចទី២ ក៏ខ្ញុំមាន ចំណែកឯឧសម្ព័ន្ធទី៣ ក៏ខ្ញុំមានបីទំព័រដែរ។ ទាំងអស់នេះ គឺជាសារណារជាលាយលក្ខណ៍អក្សរដែលយើងបានរៀបចំ ហើយយើងគ្រោងនឹងដាក់ចូល។ ដូច្នេះ ធ្វើដូច្នេះដើម្បីកុំឲ្យមានការយល់ច្រឡំថាយើងមិនបានរៀបចំអ្វីឲ្យសោះនោះ។

[១៣:៥២:២២]

ហើយខ្ញុំគិតថា ខ្ញុំនឹងយកឱកាសនេះ មិនមែនអានទាំង៦៥ទំព័រនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែធ្វើការពិភាក្សាទៅលើអ្វីដែលយើងបានពិភាក្សាកាលពីព្រឹកមិញនេះ ទាក់ទងទៅនឹងប្រភេទនៃឯកសារនៅក្នុងឧសម្ព័ន្ធទាំងបីនេះ។ ហើយខ្ញុំនឹងពិភាក្សាមិនត្រឹមទាំងប្រភេទដែលឯកសារដែលយើងបានពិភាក្សាពីព្រឹកនោះទេ ប៉ុន្តែខ្ញុំបន្ថែមនៅប្រភេទឯកសារចំនួនពីរបន្ថែមទៀត ដែលខ្ញុំអាចនឹងនិយាយដោយសង្ខេបជាទូទៅ ហើយព្រះរាជអាជ្ញាអាចជំទាស់ទៅលើអ្វីដែលខ្ញុំបានធ្វើ ឬក៏អ្វីដែលខ្ញុំចង់ធ្វើនេះ។ ប៉ុន្តែបន្ថែមទៅលើអ្វីដែលខ្ញុំបាននិយាយពីមុនមកនេះ ទាក់ទងទៅនឹងប្រភេទនៃឯកសារដែលមិនគួរទទួលយកចូលទៅក្នុងសំណុំរឿងនោះ គឺយើងនិយាយអំពីប្រភេទរូបថតផងដែរ។

[១៣:៥៣:១៥]

នៅពេលរសៀលនេះ គឺយើងនិយាយអំពីប្រភេទនៃរូបថត គឺថាមិនគួរទទួលយករូបថតមកនោះទេ លុះត្រាតែអ្នកថតរូបហ្នឹង គឺគាត់អាចមកផ្តល់សក្ខីកម្មនៅទីនេះ ឬមួយក៏មានការទុកចិត្ត ឬក៏មានអ្នកណាម្នាក់ដែលអាចធានាថារូបថតហ្នឹងគឺធ្វើឡើងដោយរបៀបណា? ថតឡើងដោយរបៀបណា? តើវាមានលក្ខណៈបែបណា? យើងមានបញ្ជីឈ្មោះអ្នកសាក្សីមួយដែលជាអ្នកថតរូបដែលគ្រោងនឹងមកផ្តល់សក្ខីកម្មនៅទីនេះ។ ហើយខ្ញុំគិតថា រូបថតរបស់គាត់មួយចំនួននឹងត្រូវបង្ហាញជូនគាត់នូវពេលដែលគាត់មកផ្តល់នូវទីនេះ។ ហើយនៅពេលនោះ គាត់នឹងអាចផ្តល់ព័ត៌មានទាក់ទងទៅនឹងរូបថតទាំងអស់នេះ។ ឧទាហរណ៍មួយទៀត គឺនិយាយអំពីអ្នកសារព័ត៌មានដែលនឹងមកផ្តល់សក្ខីកម្មនៅទីនេះ នៅពេលដែលគាត់និយាយអំពីអត្ថបទដែលគាត់សរសេរដោយមានបញ្ចូលរូបថតនុ៎ង គឺរូបថតដែលអ្នកផ្សេងជាអ្នកថតនោះទេ។

[១៣:៥៤:១២]

ចំពោះបញ្ហានេះ គឺយើងមិនការជំទាស់ទៅលើបទអត្ថាធិប្បាយទាំងអស់នោះទេ ប្រសិនបើរូបថតហ្នឹង គឺភ្ជាប់ជាមួយអត្ថបទដែលសរសេរដោយអ្នកសារព័ត៌មាននោះ។ ដូច្នេះ ខ្ញុំគិតថា ឯកសារប្រភេទនេះ មិនគួរដាក់បញ្ចូលទៅក្នុងសំណុំរឿងនោះទេ លុះត្រាតែអ្នកថតរូប ឬក៏មានអ្នកឯករាជ្យណាមួយដែលអាចធានា ឬដែលអាចបង្ហាញបញ្ជាក់ថា តើរូបហ្នឹងត្រូវថតក្នុងបរិបទបែបណា? ឬក៏ថតនៅក្នុងនៅលក្ខណៈបែបណានោះ។

ឯកសារមួយប្រភេទទៀត ដែលនៅពេលខ្ញុំនិយាយព្រឹកមិញនេះ ខ្ញុំមិនបានលើកមកនិយាយទោះបីថាវាជាឯកសារនៅក្នុងកំណត់ត្រាត្រាំកក់ក៏ដោយ។ យើងប្រហែលជាចាំបានថា នៅពេលដែលលោក ឆាំង យុ មកផ្តល់សក្ខីកម្មនៅទីនេះ គាត់បានបញ្ជាក់ថា ឯកសារច្បាប់ដើមត្រូវបានបាត់ទៅហើយ។ ហើយ ប៉ែន យៀរនិន បានប្រាប់ខាងសហចៅក្រមស៊ើបអង្កេតថា គាត់បានផ្តល់ -- គាត់បានទទួលនូវឯកសារជាច្បាប់ដើមយកមកថតចម្លង ហើយឯកសារច្បាប់ដើមបានបាត់ ដោយសារថាមិនដឹងជាយកទៅណាទេ។

[១៣:៥៥:៣០]

ខ្ញុំគិតថាលោក ឆាំង យុ មិនមានលទ្ធភាពផ្តល់នូវភស្តុតាង ឬក៏មិនអាចផ្តល់នូវភស្តុតាងទាក់ទងទៅនឹងការរក្សាទុកឯកសារនោះទេ។ ហេតុដូច្នេះប្រសិនបើឯកសារទាំងអស់នោះបាត់ យើងសូមជំទាស់ទៅលើការដាក់ឯកសារទាំងអស់នេះចូលមក លុះត្រាតែមានប្រភពឯករាជ្យ ឬក៏ប្រភពជឿទុកចិត្តមួយដែលអាចបង្ហាញបានអំពីយថាភាពនៃឯកសារទាំងអស់នេះ។ ខ្ញុំសូមបញ្ចូលនូវអ្វីដែលខ្ញុំបានលើកឡើងនៅរសៀល បញ្ចូលបន្ថែមទៅលើអ្វីដែលខ្ញុំលើកឡើងនៅពេលព្រឹកទាក់ទងទៅនឹងឧបសម្ព័ន្ធទាំងអស់នេះទាក់ទងទៅនឹងលិខិតអត្ថបទព័ត៌លិខិតទំនាក់ទំនង ឬក៏ឯកសារផ្សព្វផ្សាយរបស់ប្រហ្វុង ឬប្រហ្គុង ឬក៏របាយការណ៍ស៊ើបអង្កេតរបស់ ក.ស.ច.ស ជាដើមនេះ។

[១៣:៥៦:២៣]

ហេតុដូច្នេះហើយ ខ្ញុំសូមបញ្ចប់ការបង្ហាញរបស់ខ្ញុំ ហើយខ្ញុំសូមបញ្ជាក់ឡើងវិញថា ខ្ញុំបានរៀបចំនូវចម្លើយជាលាយលក្ខណ៍អក្សរដែលខ្ញុំ ដែលថាយើងនឹងដាក់បញ្ចូលទៅក្នុងសារណារបស់យើង ដែលយើងនឹងដាក់បញ្ចូលនៅពេលក្រោយ។ ហើយយើងនឹងធ្វើដូចអ្វីដែលយើងបានធ្វើកន្លងមក។ ហើយនៅពេលដែលយើងធ្វើកន្លងមក គឺខាងសហព្រះរាជអាជ្ញាមិនបានជំទាស់យើង ហើយខាងអង្គជំនុំជម្រះ

សាលាដំបូងក៏មិនបានប្រាប់ថាយើងមិនត្រូវធ្វើបែបនោះៗដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទជាបន្តសូមអញ្ជើញមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមមានមិតដោយខ្លី ជាថ្មីម្តងទៀត យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ នោះ យើងមិនជំទាស់ទេ ទោះបីជាទូទៅយើងគួរតែជំទាស់ក៏ដោយ។ យើងខ្ញុំមានការជំទាស់មួយទៅលើឯកសារដែលដាក់ចំណងជើងដោយសហព្រះរាជអាជ្ញាថា "របាយការណ៍ស្រុកត្រាំកក់"។ ជាពិសេសនោះ គឺឯកសារដែលដាក់ចាប់ពីលេខរៀងទី៤០ ហើយនិងឯកសារលេខ -- និងរៀងបន្តបន្ទាប់នៃបញ្ជីឧបសម្ព័ន្ធ២(ក) របស់សហព្រះរាជអាជ្ញា ដែលឯកសារលេខ E223/2/1.2។

[១៣:៥៨:១៧]

ជាទូទៅនោះ គឺថាយើងចោទបញ្ហាពាក់ព័ន្ធទៅនឹងច្បាប់ដើម ហើយនិងភាពអាចជឿជាក់បាននៃឯកសារ។ ជាពិសេសនោះគឺថា ឯកសារមួយចំនួននោះគឺថាមិនមានអ្នកនិពន្ធច្បាប់លាស់ទេ គឺថាមិនដឹងថាអ្នកណាជាអ្នកសរសេរឯកសារមួយចំនួនបែបនេះនោះ។ ឧទាហរណ៍ដូចជា ឯកសារលេខរៀងទី ៤០, ៤១, ៤៣, ៤៤, ៤៥។ ខ្ញុំព្យាយាមមិនធ្វើឲ្យសាំញ៉ាំនោះទេ ក៏ប៉ុន្តែក្នុងឯកសារទាំងអស់ហ្នឹង គឺថាអត់មានអ្នកមិនដឹងថា តើអ្នកណាជាអ្នកសរសេរនោះទេ។ ដូច្នេះយើងមិនគួរដាក់ចូលទៅជាភស្តុតាងក្នុងសំណុំរឿងនោះទេ។

ហើយចំណុចតូចមួយដែលលើកឡើងកាលពីព្រឹកមិញដោយសហភាតារបស់ខ្ញុំ ពាក់ព័ន្ធទៅនឹងរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស គឺថាមានការយោងទៅលើឯកសារជាលាយលក្ខណ៍អក្សរនោះ យើងគិតថាវាមានបញ្ហាពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាន គឺថាវាស្របគ្នាទៅនឹងអ្វីដែលយើងមានកាលពីខែមេសា ពាក់ព័ន្ធទៅនឹងឯកសារសរសេរជាលាយលក្ខណ៍អក្សរនោះ។ ដើម្បីឲ្យបានច្បាស់ជាងហ្នឹងទៅទៀតនោះគឺថា លិខិតដែលមានដូចជានៅក្នុងឧទាហរណ៍ដូចនៅក្នុងលេខរៀង ៣៩ ដែលមានលេខ D277/9 ជាដើមនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

តើលោកតំណាងសហព្រះរាជអាជ្ញាមានអ្វីតបទៅនឹងសេចក្តីជំទាស់របស់ភាគីមេធាវីការពារក្តីដែរឬទេ?

[១៤:០០:១៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

សូមអរគុណលោកប្រធាន។ កាលពីព្រឹកនេះ យើងស្តាប់ឮការជំទាស់មួយចំនួនរបស់មេធាវីការពារក្តីលោក អៀង សារី ហើយដូច្នេះ ខ្ញុំមិនចង់រំឭកឡើងវិញនៅវសៀលនេះទៀតទេ ដើម្បីកុំឲ្យខាតពេលវេលា។ ខ្ញុំផ្តោតតែទៅលើប្រភេទនៃឯកសារដែលកំណត់ដោយមេធាវីការពារក្តីពីរក្រុម ដែលពាក់ព័ន្ធទៅនឹងប្រភេទផ្សេងទៀតនៃឯកសារ គឺការទំនាក់ទំនងអន្តរជាតិ ហើយនិងអត្ថបទសារព័ត៌មានអន្តរ-ជាតិ។ ដូច្នេះ ការសម្រេចរបស់អង្គជំនុំជម្រះពីមុនៗមកនោះ គឺថាមិនចាំបាច់តម្រូវឲ្យមានអ្នកនិពន្ធនៃអត្ថបទ ឬក៏លិខិតឆ្លើយឆ្លងជាអន្តរជាតិនោះទេ ហើយមិនចាំបាច់ទាល់តែពួកទាំងអស់នោះ មកធ្វើសក្ខីកម្មទើបអាចបញ្ជាក់អំពីយថាភាពបាននោះទេ។ នៅក្នុងឧបសម្ព័ន្ធផ្សេងៗនេះ មានឯកសារពីរដែលពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី១ ដែលក្នុងនោះមាន TCW-565 គឺឯកសាររូបថតដែលមានលេខ D366/7.1.416។

[១៤:០១:៥៥]

ហើយនិងមានរូបថតមួយផ្សេងទៀត ដែលចេញមកពីសាក្សី TCW-470 ដែលមានលេខយោង D313/1.2.238។ រូបថតទាំងនោះត្រូវបានថតនៅពេលវាយយកទីក្រុងភ្នំពេញនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ដូច្នេះឯកសារនេះជាឯកសារនៅសម័យកាលនោះ វាមានភាពពាក់ព័ន្ធ ហើយនៅក្នុងរូបថតទី១នោះ គឺបង្ហាញអំពីហ្វូងមនុស្សដែលទទួលយុទ្ធជនខ្មែរក្រហម ហើយក្នុងនោះយើងឃើញមានយុវជនខ្មែរក្រហម។ ហើយរូបថតទី២នោះ ក៏ពីបង្ហាញពីខ្មែរក្រហមនៅស្ពាតអូរឡាំពិក នៅថ្ងៃជម្លៀសប្រជាជនដែលមានរថក្រោះខ្មែរក្រហមជាដើម។ ដូច្នេះ រូបថតទាំងអស់នោះ គឺអនុញ្ញាតឲ្យអង្គជំនុំជម្រះនិងភាគី មើលឃើញអំពីហេតុការណ៍ដែលកើតឡើងមុនពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

បាទ ពិតប្រាកដណាស់ សាក្សី TCW-565 និងអាចត្រូវបានបង្ហាញរូបថតនេះឲ្យមើល នៅ

ពេលដែលគាត់មកផ្តល់សក្ខីកម្ម។ ដូច្នេះ ខ្ញុំគិតថា វាមិនចាំបាច់ទាល់តែថាសាក្សីនោះមកផ្តល់សក្ខីកម្ម ទើបអាចទទួលយករូបថតនេះបានទេ។ រូបថតពីរដែលមាននៅក្នុងឧបសម្ព័ន្ធ២(គ) គឺឯកសារ E223/2/1.4 ដែលពាក់ព័ន្ធទៅនឹងមន្ទីរសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ដែលនៅក្នុងតំបន់៧ នៃខេត្តពោធិ៍សាត់។ រូបថតនេះ មានលេខ D313/1.2.104 និងរូបថតមួយទៀត គឺ D313/1.2.106។ រូបថតទាំងពីរនេះ ត្រូវបានថតដោយមជ្ឈមណ្ឌលកម្ពុជាឯកសារកម្ពុជានៅឆ្នាំ១៩៩៧ នៅពេលដែលមជ្ឈមណ្ឌលនោះបានទៅទីតាំងនោះ នៅនឹងកន្លែង។ ហើយឯកសារហ្នឹង គឺមាននៅក្នុងឧបសម្ព័ន្ធ២(គ) ហើយឯកសារមួយទៀតនោះ គឺឯកសារ IS18.78។

[១៤:០៤:៥៥]

ឯកសារនេះ បញ្ជាក់អំពីឈ្មោះរបស់ម្នាក់ដែលមាននៅក្នុងបញ្ជីសាក្សី ដែលថាដាក់ឈ្មោះថា TCW-699។ បុគ្គលនេះ គឺថាមាននៅក្នុងរូបថត មានរូប -- យើងឃើញរូបគាត់នៅក្នុងរូបថតនោះ។ ហើយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក៏បានសម្ភាសគាត់ផងដែរ នៅក្នុងឯកសារ D125/49។ នេះគ្រាន់តែជាព័ត៌មានជម្រាបជូនអង្គជំនុំជម្រះ។ ខ្ញុំគិតថាយើងមិនអាចជំទាស់តវ៉ាទៅលើយថាភាពនៃរូបថតទាំងអស់នោះទេ ឯកសារនេះត្រូវបានបញ្ជូនមកដោយ ឌី.ស៊ី.ខេម ហើយយើងក៏បានស្តាប់ចម្លើយរបស់ប្រធាន និងអនុប្រធាននៃមជ្ឈមណ្ឌលនេះរួចមកហើយ។ ដូច្នេះយើងមិនអាចជំទាស់តវ៉ានឹងបញ្ហាយថាភាពបានទេ។

[១៤:០៥:៥១]

ពាក់ព័ន្ធទៅនឹងកំណត់ហេតុស្រុកត្រាំកក់ អ្វីដែលយើងមិនត្រូវនៅស្ងៀមស្ងាត់នោះគឺថា កាលពីឆ្នាំមុន គឺខែមីនា ឆ្នាំ២០១២ យើងបានពិភាក្សាទៅលើឯកសារមួយចំនួនច្រើនទៀត ដែលចេញមកពីកំណត់ហេតុស្រុកត្រាំកក់នេះ។ ហើយទាំងអស់ កាលណោះមាន៥៧ឯកសារ។ ហើយយើងក៏បានផ្តល់ទឡ្ហីករណ៍យ៉ាងវែងអន្លាយពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនឹងភាពអាចទទួលយកបាន និងភាពអាចជឿជាក់បាននៃឯកសារទាំងអស់នោះ។ ដូច្នេះ កាលនោះអង្គជំនុំជម្រះបានទទួលយកឯកសារទាំង៥៧នោះ ប្រសិនបើខ្ញុំមិនច្រឡំទេ គឺនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ ដែលមានលេខ E185/1។ ខ្ញុំមិននិយាយអំពីអ្វីដែលយើងបានជជែកគ្នាតាំងពីឆ្នាំមុនមកហើយនោះទេ ក៏ប៉ុន្តែខ្ញុំអាចលើកឡើងនូវឯកសារមួយចំនួន ពីព្រោះថាឯកសារ៤៩ដែលមាននៅក្នុងផ្នែកនៃកំណត់ហេតុនោះ។ វាមិនចាំបាច់ឲ្យយើងបញ្ជាក់ឲ្យបានច្បាស់នោះ អ្វីបន្ថែមទៀតនោះទេ ពីព្រោះអង្គជំនុំជម្រះបាន

សម្រេចរួចមកហើយ ហើយយើងបានជ្រើសរើសយកឯកសារ៤៩ ដែល -- ដើម្បីយកមកបង្ហាញដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញដោយបង្ខំចេញពីទីក្រុងភ្នំពេញ។

[១៤:០៧:២៤]

ឯកសារ៤៩ ដែលត្រូវបានជ្រើសរើសយកមកនោះ គឺថាមានភាពពាក់ព័ន្ធទៅលើច្រើនចំណុច។ ជាដំបូងពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងដែលប្រើដោយអាជ្ញាធរមូលដ្ឋាននៅស្រុក១០៥។ ទី២ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់តំបន់១០៥ (សូមទោស)របស់ស្រុក១០៥ និងជាចុងក្រោយពាក់ព័ន្ធទៅនឹងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការអប់រំកសាងសមាសភាពមិនល្អ ទាំងក្នុង និងក្រៅបក្ស។ ហើយនិងនយោបាយចាត់វិធានការជាក់លាក់ប្រឆាំងទៅនឹងក្រុមជាក់លាក់មួយចំនួននៃអតីតមន្ត្រីរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរ គឺមានន័យថាជាមន្ត្រីរដ្ឋកាលយោធា និងក្រុមគ្រួសាររបស់ពួកគេ។ ហើយនិងមានមនុស្សមួយចំនួនដែលស្ថិតនៅក្នុងប្រភេទជាប្រជាជនថ្មី ដែលមាន-- ធ្វើឲ្យមានទំនាក់ទំនងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់ជនបទ។ ហើយនិងមានការជម្លៀសចេញទៅខាងនិរតីផងដែរ។

ក្នុងចំណោមឯកសារ៤៩នោះ គឺជារបាយការណ៍ដែលធ្វើឡើងដោយឃុំផ្សេងៗ ដើម្បីផ្ញើជូនទៅស្រុក១០៥ ហើយក៏ជារបាយការណ៍នៃមន្ទីរសន្តិសុខក្រាំងតាចាន់ផ្ញើជូនទៅស្រុក១០៥ ហើយក៏មានសេចក្តីណែនាំដែលផ្ញើដោយថ្នាក់ស្រុក ឬក៏ថ្នាក់តំបន់ទៅកាន់ថ្នាក់ក្រោមៗ ដូចជាឃុំ ឬក៏មន្ទីរសន្តិសុខផ្សេងៗជាដើម។ ជាទូទៅរបាយការណ៍ទាំងអស់នោះមានបញ្ជីឈ្មោះមនុស្សដែលធ្វើឡើងដោយឃុំនានា ហើយដែលមានបញ្ជាក់ច្រើនលើកច្រើនសាថាបុគ្គល ឬក៏បុគ្គលណាមួយផ្សេងនោះថាមានឋានៈជាមន្ត្រីរដ្ឋការ ជាយោធា ឬក៏ជាប្រជាជនថ្មី។

[១៤:០៩:៤៥]

ឯកសារមួយប្រភេទផ្សេងទៀតក្នុងចំណោមឯកសារទាំង៤៩នោះ គឺជារបាយការណ៍ និងប្រវត្តិរូប ឬក៏ចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ ឯកសារនេះនិយាយអំពីអ្នកទោសដែលត្រូវបានចាត់ទុកថាជាប្រជាជនថ្មី ឬក៏ជាអតីតយោធា ឬមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ហើយនិងមាននិយាយអំពីអ្នកទោសដែលត្រឡប់មកពីបារាំង។ ឧទាហរណ៍ដូចជាឯកសារ IS18.32 ចុះថ្ងៃទី២៨ ខែ៤ ឆ្នាំ៧៧។ ឯកសារនេះបង្ហាញពីការចាប់អារម្មណ៍ទូទៅទៅលើស្រុក ពាក់ព័ន្ធទៅនឹងសន្តិសុខ ហើយនិងពាក់ព័ន្ធទៅនឹងប្រជាជនថ្មីដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយនិងមាន

នាយទាហាន នាយទាហានរងនៃយោធាដែលត្រូវបានជម្លៀសហើយទៅនៅតំបន់១០៥។ ខ្ញុំមិនសង្កត់ធ្ងន់ទៅលើបញ្ហាដែលថាឯកសារទាំង៤៩នោះ បញ្ជាក់អំពីការទំនាក់ទំនងជាលាយលក្ខណ៍អក្សររវាងថ្នាក់មូលដ្ឋាន និងថ្នាក់លើនោះទេ ពីព្រោះថាយើងមានឯកសារជាច្រើនរួចមកហើយដែលចេញមកពីកន្លែងតែមួយបែបនេះដែលបង្ហាញអំពីទំនាក់ទំនងផ្សេងៗរវាងថ្នាក់លើ និងថ្នាក់ក្រោម ឬក៏ថ្នាក់ផ្សេងៗគ្នា។

[១៤:១១:២២]

ហើយឯកសាររបៀបនេះ គឺថាមានលក្ខណៈដូចៗគ្នា ដែលវាមានផលប្រយោជន៍ច្រើនសម្រាប់ការជំនុំជម្រះក្តីរបស់យើងនេះ។ នេះបង្ហាញអំពីប្រសិទ្ធភាពនៃការទំនាក់ទំនងគ្នា ហើយនិងបង្ហាញអំពីអំណាចរបស់ថ្នាក់លើនិងថ្នាក់ក្រោម ជាពិសេសពាក់ព័ន្ធទៅនឹងការតាមដានប្រជាជនថ្មី ឬក៏អ្នកដែលធ្វើការឱ្យរបបសាធារណរដ្ឋខ្មែរ។

ខ្ញុំសូមបង្ហាញនូវភាពអាចទទួលយកបាននូវឯកសារទាំង៤៩ នេះ លោក កាណាវាស បានរំឮកហើយថាឯកសារនោះត្រូវបានយកឡើងក្នុងកាលៈទេសៈបែបណា? ហើយចង់បានឯកសារច្បាប់ដើមពីឯកសារទាំងអស់នោះយ៉ាងម៉េចនោះ។ ពិតណាស់លោក យុ ឆាំង បានបញ្ជាក់ការពីសវនាការថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ គឺនៅក្នុង -- យើងក៏មានប្រតិចារឹកបញ្ជាក់ច្បាស់ហើយ។ ខ្ញុំមិនត្រឡប់មកនិយាយដដែលៗទេ ក៏ប៉ុន្តែគាត់បញ្ជាក់ហើយថា គឺថាគាត់ទទួលបានច្បាប់ដើមពីលោក ស៊ូ ភិរិន្ទ មែន ក៏ប៉ុន្តែក្រោយមកយើងមិនអាចរកច្បាប់ដើមបានទេ ហើយយើងមានឯកសារថតចម្លងដែលយើងអាចរកបាន គឺថាអាចមាននៅសារមន្ទីរទួលស្លែង ឯកសារមួយចំនួននោះ។

យើងដឹងហើយថាសាក្សី TCW-38 គាត់មិនមកផ្តល់សក្ខីកម្មទេ ក៏ប៉ុន្តែចម្លើយរបស់គាត់នោះអាចជឿជាក់បានគឺថា ឯកសារមួយចំនួន គឺអាចប្រើប្រាស់បាន។ ហើយពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននោះ ខ្ញុំសូមនិយាយដូចតទៅនេះ៖

[១៤:១៣:២៥]

ឯកសារទាំង៤៩ ដែលចេញមកពីស្រុកត្រាំកក់នោះ គឺថាមានភាពស៊ីសង្វាក់គ្នារវាងឯកសារនីមួយៗ ហើយនិងជាមួយនឹងឯកសារ៥៧ផ្សេងទៀតដែលបានទទួលយករួចមកហើយ ដោយអង្គជំនុំជម្រះ។ ដូច្នេះយើងគួរតែទទួលយកទាំងអស់ យើងមិនអាចបំបែកថាឯកសារប៉ុណ្ណោះអាចទទួល ហើយឯកសារផ្សេងទៀតមិនអាចទទួលទេ ពីព្រោះថាឯកសារទាំងអស់នោះមានភាពស៊ីសង្វាក់គ្នា។ ពាក់ព័ន្ធ

ទៅនឹងទម្រង់នោះ គឺថារបាយការណ៍ច្រើនតែសរសេរដោយអក្សរដៃ ហើយមិនមានរចនាសម្ព័ន្ធច្បាស់លាស់អ្វីទេនៅក្នុងរបាយការណ៍ទាំងអស់នោះ។ អាជ្ញាធរមូលដ្ឋានគឺថាប្រើប្រាស់មធ្យោបាយរឹតត្បិតតាមអ្វីដែលខ្លួនមាន។ ហើយដូចដែលយើងឃើញនៅក្នុងឯកសារ៥៧ផ្សេងទៀតហើយ គឺថាឯកសារមួយចំនួននោះសរសេរទៅលើសៀវភៅរៀនសូត្រ ហើយយើងឃើញមានតារាងមេគុណមេអីជាដើម។ ហើយឯកសារនុ៎ងគឺថាមានលក្ខណៈដូចទៅនឹងឯកសារនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះហើយ។ ព្រោះថាយើងឃើញមានពាក្យ “អង្គការ” មានពាក្យ “ខ្មាំង” “កម្ទេច” “ការបោសសម្អាត” “ការប្រុងប្រយ័ត្នបដិវត្តន៍” ឬក៏របាយការណ៍ដែលមានផ្ញើថាជូន “បងជាទីស្នេហា” “បងជាទីនឹករឭក”។ ដូច្នេះយើងឃើញហើយថា ក្នុងឯកសារទាំងនោះមាននិយាយអំពី “ប្រជាជន១៧មេសា” ឬក៏ “ប្រជាជនថ្មី” “ពួកអា” យើងហៅ “អា” ឬក៏ “អាខ្មាំង” ឬក៏មានពាក្យ “អាជនក្បត់” ហើយនិងមានពាក្យថា “អប់រំកសាង” ជាដើម។

[១៤:១៥:០៥]

ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបានខាងក្រៅនោះ គឺថា សាក្សីជាច្រើនត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត ហើយបានបញ្ជាក់អំពីយថាភាពនៃកំណត់ហេតុ ហើយវាមានភាពស៊ីសង្វាក់គ្នាជាមួយនឹង ឧទាហរណ៍ដូចជាឈ្មោះនៃអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរឃុំផ្សេងនៃស្រុក១០៥។ ដូច្នេះឈ្មោះទាំងអស់នោះ គឺថាមានដូចគ្នាទៅនឹងរបាយការណ៍ដែលផ្ញើចេញពីស្រុក១០៥។ ឧទាហរណ៍សាក្សី TCW-680 នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលមានលេខ D232/93, សាក្សី TCW-505 ដែលមានកំណត់ហេតុស្តាប់ចម្លើយ D232/16 និង D232/73។ សាក្សីនេះជាអតីតលេខាមួយនៃស្រុក១០៥ ហើយគាត់បានផ្តល់ព័ត៌មានលម្អិតជាច្រើនពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃតំបន់១០៥ នៃស្រុក១០៥ និងស្រុក១៣ ហើយគាត់ក៏បានផ្តល់យថាភាពទៅលើឯកសារ IS18.33 ដែលឯកសារនេះគឺស្ថិតនៅក្នុងឯកសាររបាយការណ៍ស្រុកត្រាំកក់។ ហើយមានសាក្សីមួយទៀតគឺ TCW-518 ដែលមានកំណត់ហេតុ D232/78 ហើយជាចុងក្រោយគឺសាក្សី TCW-301 គឺនៅក្នុងកំណត់ហេតុ D232/46។

[១៤:១៦:៥៧]

ដើម្បីបញ្ចប់ពាក់ព័ន្ធទៅនឹងរបាយការណ៍៤៩ ដែលចេញមកពីស្រុកត្រាំកក់នោះ គឺថាយើងគិតថាវាមានភាពពាក់ព័ន្ធ ពីព្រោះថាវាបញ្ជាក់អំពីរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន ហើយនិងប្រព័ន្ធទំនាក់ទំនងដែលបានឆ្លើយឆ្លងគ្នានៅក្នុងថ្នាក់តំបន់ ហើយវាក៏ពាក់ព័ន្ធទៅនឹងមនុស្សមួយចំនួន ដែលជាយោធារបប

លន់ នល់ ឬក៏ជាប្រជាជនថ្មី។ ដូច្នេះយើងគិតថា ឯកសារទាំងអស់នោះមានព័ត៌មានច្បាស់លាស់ដែលអាចឲ្យយើងកំណត់បានថា តើអ្នកណាជាខ្លាំងនៅក្នុងរបបនោះ។

ការជំទាស់ដែលលើកឡើងដោយមេធាវី ខៀវ សំផន ថាឯកសារមួយចំនួនមិនមានហត្ថលេខាមិនមានឈ្មោះអ្នកសរសេរជាដើមនោះ គឺថាវាមានមិនមែនជាមូលហេតុត្រឹមត្រូវ ក្នុងការអនុញ្ញាតឲ្យអង្គជំនុំជម្រះប្រកាសថាមិនទទួលយកនោះទេ។ ដូច្នេះខ្ញុំគិតថា ខ្ញុំសូមបញ្ចប់ទៅលើការផ្តល់អត្ថាធិប្បាយទៅលើឯកសារប្រសិនបើមិនមានការជំទាស់នៅក្នុងដំណាក់កាលនេះទេ។ សូមអរគុណលោកប្រធាន។

[១៤:១៨:១៤]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយចុះខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានអ្វីចង់បន្ថែមដែរឬទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន យើងខ្ញុំអត់មានអ្វីបន្ថែមទេ។ សូមអរគុណ។

[១៤:១៨:៣៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២១:៤២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ។ ហើយអង្គជំនុំជម្រះក៏មានបញ្ហាមួយចំនួនត្រូវជជែកពិភាក្សាដែរ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២២ នាទី ដល់ម៉ោង ១៥:០៤ នាទី)*

[១៥:០៤:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីដាក់បង្ហាញនូវបណ្តាឯកសារជាគន្លឹះ ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃកថាខណ្ឌទី៤ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះ ដែលចេញកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ ឯកសារ E223/3 អង្គជំនុំជម្រះសូមជម្រាបជូនភាគីឲ្យបានជ្រាបថា អង្គជំនុំជម្រះមុននេះបន្តិចបានទទួលនូវសំណើសុំរបស់មេធាវីការពារក្តី អៀង សារី បានស្នើសុំដាក់ពិភាក្សាលើឯកសារចំនួន៥៦ នៅចំពោះមុខអង្គជំនុំជម្រះនិងភាគីនៅក្នុងកិច្ចដំណើរការសវនាការនេះ។

អង្គជំនុំជម្រះមិនទាន់ដឹងច្បាស់ទេ ថាតើភាគីនានាបានទទួលនូវបញ្ជីឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី អៀង សារី ហើយឬនៅ? ហើយឯកសារទាំង៥៦ ដែលមេធាវីការពារក្តី អៀង សារី បានស្នើសុំនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការពិភាក្សានៅថ្ងៃស្អែកនៅវេលារសៀលដោយអង្គជំនុំជម្រះទុកពេលវេលាសមស្របសម្រាប់ភាគីនានាពាក់ព័ន្ធនៃរឿងក្តី មានឱកាសក្នុងការពិនិត្យមើលឯកសារទាំង៥៦ ដែលបានស្នើសុំនេះ។ ហើយអង្គជំនុំជម្រះក៏នូវផ្តល់ឱកាសឲ្យភាគីនានាធ្វើអត្ថាធិប្បាយ ឬក៏ជំទាស់ទៅនឹងឯកសារទាំង៥៦ ដែលបានស្នើសុំឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី ផងដែរ។

បាទ ជាបន្តនេះ អង្គជំនុំជម្រះសុំផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីដាក់បង្ហាញនូវឯកសារជាគន្លឹះដែលអង្គជំនុំជម្រះកំណត់នៅក្នុងកថាខណ្ឌទី៤ នៃឯកសារ E223/3 ដោយយកអង្គហេតុ ឯកសារពាក់ព័ន្ធនឹងអង្គហេតុ រចនាសម្ព័ន្ធយោធាជាមុន។

សូមអញ្ជើញបាទ!

[១៥:០៦:៥០]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូង សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម និងភាគីដែលមានវត្តមាននៅទីនេះទាំងអស់។ ពេលនេះខ្ញុំនឹងបង្ហាញឯកសារមួយចំនួនពាក់ព័ន្ធទៅនឹងការបង្កើត ហើយនិងរចនាសម្ព័ន្ធរបស់កងទ័ពបដិវត្តន៍កម្ពុជា និងការត្រួតពិនិត្យកងទ័ពបដិវត្តន៍កម្ពុជាដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយឯកសារទាំងនេះក៏សូមអនុញ្ញាតពីលោក

ប្រធាន ដើម្បីដាក់បញ្ចាំងនៅលើអេក្រង់កុំព្យូទ័រផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។ ឯកសារសំខាន់ដំបូង ដែលទាក់ទងនឹងតួនាទី និងរចនាសម្ព័ន្ធរបស់កងទ័ពបដិវត្តន៍កម្ពុជា បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាឯកសារទង់បដិវត្តលេខ៨ ចុះខែសីហា ឆ្នាំ១៩៧៥ ដែលមាននៅក្នុងឯកសារលេខ E3/5។

ការចេញផ្សាយទង់បដិវត្តនេះ គឺជាការបោះពុម្ពផ្សាយនូវបទបង្ហាញ ឬក៏សុន្ទរកថាដែលបានធ្វើនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ហើយដែលមាននៅក្នុង ERN ជាភាសាខ្មែរ គឺ00063324, ជាភាសាអង់គ្លេស គឺ00401488, ជាភាសាបារាំងគឺ 00538963 ដែលបានលើកឡើងថា "កាលពីថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥ ក្នុងឱកាសពិធីចាត់តាំងកងទ័ពបដិវត្តន៍របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សមមិត្តប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស បានធ្វើសន្និសីទនយោបាយមួយដ៏សំខាន់ជូនតំណាងគ្រប់អង្គភាពនៃកងទ័ពបដិវត្តន៍ប្រមាណ៣.០០០នាក់ របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ សន្និសីទដ៏សំខាន់នេះមានខ្លឹមសារទាំងស្រុងដូចតទៅ៖

១) អត្ថន័យនៃមហាជ័យជម្នះជាប្រវត្តិរបស់ប្រជាជាតិ ប្រជាជន កងទ័ព និងបក្សយើង។ ២) ប្រវត្តិសង្ខេប នៃកងទ័ពបដិវត្តន៍យើង ៣) មូលហេតុនៃមហាជ័យជម្នះរបស់កងទ័ពបដិវត្តន៍យើង។ និង៤) ភារកិច្ចថ្មីនៃកងទ័ពបដិវត្តន៍យើង។

[១៥:១០:១៦]

នៅត្រង់ផ្នែកទីII នៃសុន្ទរកថានេះ ដែលទាក់ទងទៅនឹងប្រវត្តិនៃការកសាងកងទ័ពបដិវត្តន៍កម្ពុជា ដែលមាននៅត្រង់លេខ ERN ជាភាសាខ្មែរគឺ 00063328, ជាភាសាអង់គ្លេសគឺ 00401491, ជាភាសាបារាំងគឺ 00538966 ដែលបានលើកឡើងថា កងទ័ពបដិវត្តន៍កម្ពុជាកកើតឡើងមកពីមាគ៌ានយោបាយជាយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានចែងក្នុងខ១ថា "ខ្មាំងវាប្រើហិង្សា វាប្រើអំពើឃោរឃៅជានយោបាយ និងជាយោធា ជាអាវុធ ដើម្បីជិះជាន់ កាប់សម្លាប់ បំផ្លិចបំផ្លាញប្រជាជន។ ដូច្នេះ បក្សត្រូវដឹកនាំប្រជាជនប្រើហិង្សា ប្រើអំពើសងឈាមវិញ ជានយោបាយក្តី ជាយោធាក្តី គឺបក្សត្រូវប្រើហិង្សាបដិវត្តន៍ ត្រូវប្រមូលប្រជាជន ប្រើហិង្សាបដិវត្តន៍ប្រឆាំងពួកប្រតិកិរិយា

ពួកវណ្ណៈជិះជាន់ ប្រឆាំងពួកអាណានិគម ចក្រពត្តិនិយម"។

[១៥:១១:៥៨]

នៅត្រង់ផ្នែកទីIII នៃសុន្ទរកថានេះដែរ គឺនៅត្រង់ ERN ជាភាសាខ្មែរ 00063338, និងជាភាសាអង់គ្លេសគឺ 00401498, ជាភាសាបារាំងគឺ 00538973 ដល់ 74 ដែលបានលើកអំពីមូលហេតុនៃជ័យជម្នះរបស់កងទ័ពបដិវត្តន៍ ក្នុងការរំដោះទីក្រុងភ្នំពេញ និងប្រទេសទាំងមូល។ មូលហេតុទី១ គឺការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងសុន្ទរកថានេះថ្លែងថា "បក្សបំពាក់មាគ៌ានយោបាយដល់កងទ័ព កងទ័ពជ្រួតជ្រាប។ បក្សបំពាក់គោលជំហរសតិអារម្មណ៍ដល់កងទ័ព កងទ័ពជ្រួតជ្រាប។ មាគ៌ាចាត់តាំង ដែលបក្សបំពាក់ដល់កងទ័ព កងទ័ពជ្រួតជ្រាប ទាំងកងស្រួច ទាំងកងតំបន់ ទាំងកងឈ្លប។ កងទ័ពបដិវត្តន៍ទាំងបីប្រភេទ ទទួលការបំពាក់បំប៉នពីបក្សគ្រប់ពេលវេលា"។ ជាមួយគ្នានេះដែរ នៅផ្នែកចុងក្រោយ គឺផ្នែកទីIV នៃសុន្ទរកថា ដែលទាក់ទងទៅនឹងភារកិច្ចពីរយ៉ាងរបស់កងទ័ពបដិវត្តន៍ ដែលបក្សបានប្រគល់ឲ្យគឺ៖ ទី១) ការពារប្រទេស និង ទី២) កសាងប្រទេស។

[១៥:១៣:៤៨]

ភារកិច្ចទី១ ទាក់ទងទៅនឹងការការពារប្រទេសរបស់កងទ័ពបដិវត្តន៍កម្ពុជា បើយើងពិនិត្យនៅត្រង់ ERN ជាភាសាខ្មែរគឺ 00063340 ដល់42, ជាភាសាអង់គ្លេសគឺ 00401501, ជាភាសាបារាំងគឺ 00538975 ដល់76 ភារកិច្ចរបស់កងទ័ពបដិវត្តន៍ត្រូវបានណែនាំដូចជា សូមដកស្រង់ "ភារកិច្ចចម្បងរបស់កងទ័ពគឺការពារប្រទេស។ យ៉ាងម៉េចបានជាត្រូវការពារប្រទេស បើប្រទេសយើងរំដោះទាំងស្រុងហើយ?" បន្តមកទៀត "សភាពការណ៍សង្គ្រាមនៅតែចោទមានដដែល ពីព្រោះនៅលើពិភពលោកចក្រពត្តិនិយម អាណានិគមនិយមថ្មីចាស់ នៅតែមានដដែល។ វាធ្វើសកម្មភាពគ្រប់បែបយ៉ាង រាល់ពេលរាល់វេលា បំផ្លិចបំផ្លាញប្រជាជន បំផ្លិចបំផ្លាញប្រទេសទន់ខ្សោយ បំផ្លិចបំផ្លាញបដិវត្តន៍"។

[១៥:១៥:១៥]

បន្តមកកថាខណ្ឌមួយទៀត បានលើកឡើងថា "នេះជាខ្មាំងនៅខាងក្រៅ ក៏ប៉ុន្តែខ្មាំងនៅខាងក្រៅក៏វាទាក់ទងនឹងខ្មាំងនៅខាងក្នុង។ សក្តិភូមិ នាយទុន ក្នុងឋានៈជាវណ្ណៈជិះជាន់ ត្រូវវាយរំលំហើយ ក៏ប៉ុន្តែការវាយរំលំនេះ តើវាសាបសូន្យទាំងស្រុង លែងវិលមកវិញ ឬយ៉ាងម៉េច? មិនដូចនេះទេ" បាទបញ្ចប់ការកស្រង់។

ហើយនៅកថាខណ្ឌបន្តទៀត បានលើកឡើងទាក់ទងទៅនឹងការផ្តល់ការណែនាំដល់កងទ័ព

បដិវត្តន៍ដូចតទៅ៖ “ហេតុនេះហើយបានជាកងទ័ពយើងត្រូវបំពេញភារកិច្ចការពារប្រទេសដោយប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច។ ការពារប្រទេសទាំងមូល ការពារដែនដី ទាំងដែនដីខាងក្នុង ទាំងដែនដីតាមព្រំដែនការពារដែនសមុទ្រ ការពារដែនអាកាស។ ទាំងនេះ សុទ្ធតែជាភារកិច្ចរបស់កងទ័ព”។

[១៥:១៦:៣២]

ហើយបន្តបមកទៀត បានលើកឡើងថា “គឺជាការការពារភ្នំពេញ និងកម្ទេចពួកចារកម្ម កម្ទេចពួកវិទ្ធ្វេទកម្ម ដែលវាចង់បំផ្លិចបំផ្លាញបដិវត្តន៍យើង គឺយើងបន្តកម្ទេចសំណល់ខ្មាំងដែលចេញនោះ ហើយពង្រឹងជ័យជម្នះរបស់យើង”។

ឯកសារមួយទៀត គឺទាក់ទងទៅនឹងការត្រួតពិនិត្យ និងសិទ្ធិអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើកងទ័ព ដែលមាននៅក្នុងឯកសារលេខ E3/214 ដែលមានចំណងជើងថា “លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា”។ ជាពិសេសនៅត្រង់មាត្រា២៧ នៃលក្ខន្តិកៈនេះបានចែងថា “កងទ័ពបដិវត្តន៍កម្ពុជាទាំងបីប្រភេទ ស្រួច តំបន់ ឈ្លប ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ដាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា”។ ហើយមាត្រា២៨ នៃលក្ខន្តិកៈនេះក៏បានបង្កើតឲ្យមានជាអង្គការបក្សជាថ្នាក់ៗ នៅក្នុងរចនាសម្ព័ន្ធរបស់កងទ័ពបដិវត្តន៍កម្ពុជាផងដែរ។

ឯកសារផ្សេងទៀតទាក់ទងទៅនឹងកិច្ចប្រតិបត្តិការជាហូរហែនៃសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំបក្សទៅលើកងទ័ព ត្រូវបានបង្ហាញនៅក្នុងកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលក្នុងនោះ ក៏មានការចូលរួមរបស់ជនជាប់ចោទទាំងបីរូបនៅទីនេះផងដែរ។

ជាបន្តនេះ ខ្ញុំនឹងបង្ហាញឯកសារមួយចំនួនទាក់ទងទៅនឹងបញ្ហាកងទ័ព ដែលបានរាយការណ៍ទៅថ្នាក់ដាក់នាំបក្ស ហើយបញ្ហាទាំងនេះត្រូវបានលើកយកមកពិភាក្សា និងសម្រេចដោយថ្នាក់ដឹកនាំបក្សនៅក្នុងកិច្ចប្រជុំទាំងនេះផងដែរ។

[១៥:១៨:៤៩]

ឯកសារដំបូង គឺឯកសារដែលមានលេខ E3/182 ដែលជាកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលបានធ្វើនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥។ នៅក្នុងកិច្ចប្រជុំនេះបានកត់ត្រាជាពិសេសនៅត្រង់ទំព័រទី៦ និងទំព័រទី៧ ថា “គណៈអចិន្ត្រៃយ៍បានពិភាក្សា និងបានសម្រេចបញ្ហាមួយចំនួនទាក់ទងនឹងកងទ័ពដែលរួមមានទាំងការរៀបចំសេនាធិការ ចាត់ចែងកងទ័ពថ្មី ជើងទឹក អាកាស បើកវគ្គកម្មាភិបាលនៅសល់ និងក្ដាប់ប្រវត្តិរូបរបស់កងទ័ព។

ហើយឯកសារបន្តបន្ទាប់មកទៀត គឺមានលេខ E3/1150 ដែលជាឯកសារបានផ្ញើនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលជាលិខិតរបស់អង្គការ ផ្ញើទៅសមមិត្ត យ៉ា ដែលជាលេខាភូមិភាគឦសាន។ នៅក្នុងលិខិតនេះគឺថា អង្គការបានទទួលទូរលេខរបស់សមមិត្ត យ៉ា ដែលបានផ្ញើកាលពីថ្ងៃទី០៩ និងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥។ អង្គការបានឆ្លើយតបទៅវិញ ហើយបានផ្តល់ការណែនាំជាក់លាក់មួយចំនួនទាក់ទងទៅនឹងការរៀបចំ និងចល័តកម្លាំងនៅក្នុងតំបន់នោះ ដើម្បីរៀបចំឲ្យរួចរាល់ក្នុងការប្រយុទ្ធទៅលើខ្មាំង។ ហើយយើងអាចឃើញជាឧទាហរណ៍ នៅក្នុងកថាខណ្ឌទីII ត្រង់ចំណុចទី២ និងចំណុចទី៣ នៃឯកសារនេះ ហើយនិងត្រង់ចំណុចទី៦ ដែលជាសេចក្តីសរុប។ ហើយយើងកត់សម្គាល់ផងដែរថា នៅចុងបញ្ចប់នៃឯកសារនេះ គឺមានការបញ្ជាក់ថា "អង្គការក៏បានទទួលទូរលេខអំពីប្រជាជនថ្មីព្រឹកនេះ ចាំមានមតិជាក្រោយ"។

[១៥:២១:៣០]

ជាបន្ត គឺឯកសារលេខ E3/229 គឺជាកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ យប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលមានរបៀបវារៈបញ្ហាការពារប្រទេស។ កំណត់ហេតុនេះ បានកត់ត្រាអំពីសមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន៖ សមមិត្តលេខា ប៉ុល ពត, សមមិត្តអនុលេខា នួន ជា, អៀង សារី ហៅ វ៉ាន់, វន វេត, សុន សេន ហៅ ខៀវ, កុយ ធួន ហៅ ធុច, ខៀវ សំផន ហៅ ហែម, និង សឿ វ៉ាស៊ី ហៅ ឌឿន។ ក្នុងកិច្ចប្រជុំនេះ សុន សេន បានរបាយការណ៍ជូនថ្នាក់ដឹកនាំផ្សេងៗទៀត អំពីសភាពការណ៍នៅព្រំដែនខាងកើត បញ្ហាជំនួយចិនទាក់ទងខាងអាកាស និងខាងជើងទឹក។ បញ្ហាដឹកគ្រាប់រំសេវ និងស្នើអង្គការឲ្យបង្កើតមន្ទីរពេទ្យមួយសម្រាប់យោធា។ នៅក្នុងកំណត់ហេតុនេះ ក៏បានកត់ត្រាអំពីវិធានការនានា ដែលសម្រេចដោយគណៈអចិន្ត្រៃយ៍នៅក្នុងកិច្ចប្រជុំនេះ ដែលរួមមានដូចជាឃ្លាដែរថា "ត្រូវប្រុងប្រៀបប្រយុទ្ធ វាមកជ្រុល ដាក់វាភ្លាម។ ត្រូវសហការឲ្យជាប់ជាមួយមូលដ្ឋានជាដើម"។ គណៈអចិន្ត្រៃយ៍ក៏បានស្នើឲ្យពិនិត្យកន្លែងថ្មីសម្រាប់ព្រលានយន្តហោះនៅកំពង់ឆ្នាំង ហើយនិងយល់ព្រមឲ្យរៀបចំមន្ទីរពេទ្យយោធាតាមការស្នើរបស់សេនាធិការផងដែរ។

[១៥:២៣:៤២]

នៅក្នុងនេះ ខ្ញុំសូមលើកឧទាហរណ៍មួយទាក់ទងទៅនឹងរបៀបរបបធ្វើការជាមួយនឹងមូលដ្ឋាន ដែលមានដូចជា ភូមិភាគ ហើយនិងកងពលផ្សេងៗ ដែលត្រូវបានសម្របសម្រួលជាមួយមជ្ឈិម ដែលមាននៅក្នុងឯកសារលេខ E3/866។ ឯកសារនេះ គឺជាទូរលេខផ្ញើមកពីលេខាភូមិភាគឦសាន ហើយក៏

បានចម្លងជូនបង ប៉ុល, នួន, វ៉ាន់, ឌឿន និងរក្សាទុកឯកសារ។ នៅខាងក្រោមបង្អស់នៃទូរលេខដែលផ្ញើមកពីលេខាភូមិភាគឈ្មោះ យ៉ា នេះ មានសរសេរបន្ថែមថា "បើអង្គការយល់ព្រម យើងខ្ញុំស្នើខាង៨៩ ជួយណែនាំខាង៩២០ ឲ្យបង្អង់សកម្មភាពប្រយុទ្ធសិន"។ បាទ ឯកសារមួយទៀត គឺជាឯកសារដែលមានលេខ E3/217 ដែលជាកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ដែលបានធ្វើនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ទាក់ទងទៅនឹងសភាពការណ៍នៅព្រំប្រទល់ខាងកើត។

ដែលក្នុងនោះក៏មានការចូលរួមដោយលោក នួន ជា, អៀង សារី ហៅ វ៉ាន់, និង ខៀវ សំផន ហៅ ហែម ផងដែរ។ នៅក្នុងកិច្ចប្រជុំនេះ សុន សេន ហៅ ខៀវ បានរាយការណ៍អំពីសភាពការណ៍នៅព្រំប្រទល់ខាងកើត ជាពិសេសនៅមណ្ឌលគិរី និងអំពីការប្រាស្រ័យទាក់ទងជាមួយវៀតណាម។ នៅក្នុងកំណត់ហេតុនេះក៏បានកត់ត្រាអំពីកិច្ចពិភាក្សាទាក់ទងនឹងការប្រយុទ្ធគ្នារវាងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ និងកម្លាំងរបស់វៀតណាមផងដែរ ដែលបានកើតឡើងនៅក្នុងខេត្តរតនគិរី និងខេត្តតាកែវ ព្រមទាំងបានលើកឡើងអំពីវិធានការយោធា និងនយោបាយ ដែលស្នើឡើងដោយគណៈអចិន្ត្រៃយ៍។

[១៥:២៦:២០]

ឯកសារបន្តទៀត គឺឯកសារលេខ E3/235 ដែលជាសរុបសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ក្នុងអង្គប្រជុំថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ១៩៧៦។ នៅត្រង់ផ្នែកទី៣ធំ នៃឯកសារនេះដែលមាននៅក្នុងទំព័រទី៤ និងទំព័រទី៥ បានកត់ត្រាអំពីបញ្ហាការពារប្រទេស ដែលបានសម្រេចដោយគណៈអចិន្ត្រៃយ៍នៅក្នុងកិច្ចប្រជុំទាំងបីថ្ងៃនេះ។

សេចក្ដីសម្រេចទាំងនេះ គឺរួមមានដូចជា ការរៀបចំដំណើរការព្រលានយន្តហោះយោធានៅកំពង់ឆ្នាំង និងការចាត់តាំងកម្មាភិបាលឲ្យទៅសេនាធិការ។ កំណត់ហេតុប្រជុំនេះក៏បានលើកឡើងនៅត្រង់ចំណុចទី៤ នៃផ្នែកទីIIIនេះថា គណៈអចិន្ត្រៃយ៍នឹងប្រជុំស្នើសុំកម្លាំងឲ្យទៅកងទ័ពបដិវត្តន៍បន្ថែមទៀត។

ជាបន្តទៀតគឺឯកសារលេខ E3/221 គឺជាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ដែលបានធ្វើនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦។ ក្នុងកិច្ចប្រជុំនោះក៏មានការចូលរួមរបស់លោក នួន ជា, អៀង សារី ហៅ វ៉ាន់, និង ខៀវ សំផន ហៅ ហែម ផងដែរ។ ប្រធានបទប្រជុំនៅពេលនោះ គឺលើកឡើងអំពីដំណើរការចរចាជាមួយវៀតណាម។ ដែលមានរាយការណ៍ដោយសមមិត្ត យ៉ា និងមានការលើកមតិពិភាក្សាដោយអ្នកចូលរួមទាំងអស់ផងដែរ។ នៅក្នុងនោះលោក នួន ជា ក៏បានលើកជាមតិទាក់ទងទៅនឹង

ឧប្បត្តិហេតុដែលកងម៉ារីន និងយន្តហោះរបស់វៀតណាមបានបាញ់ទៅលើកប៉ាល់ដែលប្រទេសចិនយកមកឲ្យកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងកំណត់ហេតុនេះ លោក អៀង សារី ក៏បានលើកជាមតិនៅក្នុងអង្គប្រជុំនោះផងដែរ ដែលលើកថា “យូរៗទៅវៀតណាមអាចនឹងទទួលយកខ្សែប្រេវីយ៉េនេះ”។

[១៥:២៩:១៣]

ជាបន្តខ្ញុំនឹងបញ្ចាញឯកសារគណៈអចិន្ត្រៃយ៍ចុងក្រោយដែលទាក់ទងទៅនឹងសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់គណៈអចិន្ត្រៃយ៍ទៅលើកងទ័ព។ ឯកសារនោះគឺមានលេខ E3/224 ដែលជាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៦។ សមាសភាពនៃកិច្ចប្រជុំនេះរួមមាន ប៉ុល ពត, នួន ជា, វន វ៉េត, សុន សេន ហៅ ខៀវ, និង ខៀវ សំផន ហៅ ហែម ផងដែរ។ កិច្ចប្រជុំនេះបានពិភាក្សាអំពីកិច្ចការ និងភារកិច្ចជាក់លាស់ដែលត្រូវប្រគល់ឲ្យកងទ័ពត្រូវធ្វើ ជាពិសេសទាក់ទងទៅនឹងការបង្កបង្កើនផល។

នៅក្នុងផ្នែកទីI នៃកំណត់ហេតុនេះ ក៏បានកត់សម្គាល់ឃើញមានភារកិច្ចសំខាន់របស់កងទ័ពបដិវត្តន៍ដែលត្រូវការពារ គឺមានបួនសមរភូមិ ដែលក្នុងនោះកិច្ចការពារដែនសមុទ្រ និងការពារដែនគោកត្រូវបានកំណត់នៅក្នុងសមរភូមិពីដំបូង។ បន្ទាប់មកទៀត កំណត់ហេតុនេះបានកត់ត្រាបន្តថា សមរភូមិទី៣ គឺជាសមរភូមិអន្តរាគមន៍ ដែលមានអ្នកនៅចាំអន្តរាគមន៍ចាំមួយផ្នែកនៅភ្នំពេញ។ ហើយសមរភូមិទី៤ គឺការការពារសន្តិសុខនៅជុំវិញម៉ាស៊ីនដឹកនាំរបស់បក្ស និងអង្គការរដ្ឋ។ បន្ទាប់មកទៀត កិច្ចប្រជុំបានពិភាក្សា និងបានសម្រេចអំពីការបែងចែកភារកិច្ចជាក់លាក់ទាក់ទងទៅនឹងការបង្កបង្កើនផលដល់ខាងពាយ័ព្យភ្នំពេញ កន្លែងសមមិត្ត អឿន ដែលជាលេខាតំបន់៣១០ បែងចែកភារកិច្ចដល់ខាងនិរតី និងខាងត្បូងភ្នំពេញ កន្លែងសមមិត្ត ម៉េត ដែលជាលេខាតំបន់៥០២ និងសមមិត្តពីន លេខាតំបន់៧០៣។

[១៥:៣១:៣៤]

ហើយបន្តមកទៀត បែងចែកភារកិច្ចដល់ខាងជើងឯក កន្លែងសមមិត្តពីន តំបន់៧០៣ទៀត ហើយក៏បានណែនាំឲ្យខាងសមមិត្តពីន ត្រូវដឹកប្រឡាយតភ្ជាប់ទៅទន្លេបាសាក់ផងដែរ។

ជាបន្តទៀត ខ្ញុំនឹងបង្ហាញឯកសារដែលបញ្ជាក់ពីមុខងារ ឬក៏តួនាទីរបស់ថ្នាក់ដឹកនាំបក្សនៅក្នុងវិស័យកងទ័ព។ ឯកសារលេខ D56-10.008 គឺជាសេចក្តីរាយការណ៍របស់នីរសារវៀតណាមដែលបានរាយការណ៍អំពីការប្រកាសជាសាធារណៈ ដោយរណសិរ្សបង្រួបបង្រួមជាតិកម្ពុជាហៅថា “ហ្វ្រុង” និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាហៅថា “ក្រុង” ស្តីពីការបង្ហាញនូវសមាសភាពអគ្គបញ្ជាការកង

កម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ នៅក្នុងសេចក្ដីប្រកាសនោះបានលើកយោងក្នុងឱកាសរំឭកខួបនៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ហើយដែលបានប្រកាសជាសាធារណៈថា "ខៀវ សំផន ត្រូវបានតែងតាំងជាប្រធាន និងជានាយអគ្គសេនាធិការនៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ហើយបន្តទៀតគឺ សាឡុត ស ត្រូវតែងតាំងជាប្រធានដឹកនាំផ្នែកយោធានៃកងទ័ព, ហើយ នួន ជា ត្រូវតែងតាំងជាប្រធានដឹកនាំផ្នែកនយោបាយនៃកងទ័ព ហើយក្នុងនោះក៏មាន សុន សេន ត្រូវបានតែងតាំងជានាយសេនាធិការផងដែរ"។

[១៥:៣៣:៤២]

ឯកសារបន្តទៀត គឺឯកសារដែលមានលេខ E3/290 គឺជារបាយការណ៍សារព័ត៌មានរបស់បណ្ដាញសារព័ត៌មានអន្តរជាតិ អេហ្វ.ប៊ី.អាយ.អេហ្វ ដែលបានធ្វើនៅខែតុលា ឆ្នាំ១៩៧៧ ត្រង់ទំព័រ *អេច* ៣៨ ដែលរួមមានការចាក់ផ្សាយរបស់វិទ្យុព្យុងយ៉ាង ដែលបានលើកឡើងអំពីជីវប្រវត្តិ ប៉ុល ពត ដែលបានលើកឡើងថា "ចាប់ពីឆ្នាំ១៩៧០ ដល់១៩៧៥ ក្នុងឋានៈជាប្រធានគណៈកម្មាធិការយោធានៃគណៈមជ្ឈិមបក្ស គាត់បានធ្វើកិច្ចចរចាក្នុងវិស័យយោធា -- គាត់បានធ្វើការកិច្ចការក្នុងវិស័យយោធាបន្ថែមពីលើការងាររបស់បក្ស និងការងារដឹកនាំប្រឆាំងសហរដ្ឋអាមេរិក ដោយទទួលបានជោគជ័យក្នុងដណ្ដើមប្រទេសជាតិមកវិញ។

[១៥:៣៤:៥៩]

នៅក្នុងខែមករា ឆ្នាំ១៩៧៦ គាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងវិញឲ្យកាន់តំណែងជាលេខានៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈកម្មាធិការកងទ័ពនៅក្នុងសន្និបាតបក្សលើកទី៤។ ឯកសារជាបន្តទៀតគឺជាឯកសារដែលមានលេខ E3/1714 ដែលជាបទសម្ភាសន៍ជាមួយ ជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជាថៃដែលបានធ្វើនៅក្នុងខែកុម្ភៈដល់ខែមីនា ឆ្នាំ១៩៨០ ជាពិសេស គឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00324763, ជាភាសាអង់គ្លេសគឺ 00170748 និងជាភាសាបារាំងគឺ 00649010 ទៅ 11 ដែលមាននៅបទសម្ភាសន៍ជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍ក្រុងកំពង់សោម។ នៅក្នុងបទសម្ភាសន៍នេះ មានការរៀបរាប់លម្អិតអំពីការវាយដណ្ដើមកាន់កាប់ទីក្រុងភ្នំពេញដោយកងកម្លាំងខ្មែរក្រហមនៅក្នុងអំឡុងឆ្នាំ១៩៧៤ ដល់ ឆ្នាំ១៩៧៥។ ខ្ញុំសូមដកស្រង់សម្ដីសង្ខេបដូចតទៅ៖ "ការវាយប្រហារទាំងនេះស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈយោធាមជ្ឈិម ប៉ុល ពត និង នួន ជា។ សុន សេន ទទួលបន្ទុកបង្កើតសមរភូមិ"។ ជាមួយគ្នានេះដែរ សមាសភាពជាក់លាក់នៃគណៈ

កម្មាធិការខាងកងទ័ព និងសន្តិសុខរបស់បក្សដែលស្ថិតនៅក្រោមគណៈមជ្ឈិមឬក៏គណៈអចិន្ត្រៃយ៍ ត្រូវបានលោក អៀង សារី បានឆ្លើយបំភ្លឺនៅក្នុងបទសម្ភាសន៍មុនៗរបស់គាត់មួយចំនួនជាពិសេសគឺ នៅក្នុងឯកសារដែលមានលេខ E3/94 ដែលជាបទសម្ភាសន៍ជាមួយលោក អៀង សារី ធ្វើនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៨១ ជាពិសេសនៅត្រង់ ERN ជាភាសាខ្មែរគឺ 00578895, ជាភាសាអង់គ្លេស គឺ 00342501 ដល់ 02, ជាភាសាបារាំងគឺ 00602000។ លោក អៀង សារី បានឆ្លើយទៅនឹងសំណួររបស់អ្នកធ្វើសម្ភាសដូចតទៅ “ សំណួរ៖ តើនរណាគ្រប់គ្រងខាងសន្តិសុខ?” លោក អៀង សារី បានឆ្លើយថា “មេដឹកនាំកំពូលបី ឬបួននាក់ បានពិភាក្សាអំពីបញ្ហានេះ បន្ទាប់មកធ្វើរបាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍។” សំណួរបន្ទាប់ទៀតសួរថា “តើអ្នកដឹកនាំបីបួននាក់នោះជានរណា?” ហើយលោក អៀង សារី ក៏បានឆ្លើយថា “ប៉ុល ពត, នួន ជា, សោ ភឹម និងសុន សេន។ សុន សេន ទទួលបន្ទុកខាងសន្តិសុខ។ ពួកគេពឹងផ្អែកលើអ្នកនៅក្នុងតំបន់សម្រាប់រាយការណ៍អំពីសន្តិសុខ”។

[១៥:៣៩:១៧]

នៅក្នុងឯកសារលេខ E3/93 ឯកសារនេះក៏ជាបទសម្ភាសន៍ជាមួយនឹងលោក អៀង សារី ដែលធ្វើនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៦ ជាពិសេសគឺត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00224443, ជាភាសាអង់គ្លេស គឺ00078610, ជាភាសាបារាំងគឺ 00347376។ លោក អៀង សារី បានឆ្លើយថា “ខ្ញុំមិនមែនជាដៃស្តាំរបស់ ប៉ុល ពត ទេ ការពិតដៃស្តាំរបស់ ប៉ុល ពត គឺ នួន ជា ហើយមានគណៈកម្មាធិការមួយដែលបានពិនិត្យរាល់បញ្ហាទាំងឡាយអំពីសន្តិសុខ ដែលកម្មាធិការនោះមានសមាសភាពបួននាក់គឺ ប៉ុល ពត, នួន ជា, សុន សេន និងទីប្រឹក្សា យុន យ៉ាត”។

ឯកសារចុងក្រោយរបស់ខ្ញុំដែលត្រូវបង្ហាញនៅពេលនេះ គឺឯកសារលេខ E3/86 ដែលជាសេចក្តីថ្លែងការណ៍ដែលបានចេញផ្សាយដោយចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យរបស់លោក អៀង សារី កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៩៦ ដែលមានចំណងជើងថា “ការពិតអំពីរបបផ្តាច់ការរបស់ ប៉ុល ពត ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨” ដែលនៅត្រង់ ERN ជាភាសាខ្មែរគឺ 00224430, ជាភាសាអង់គ្លេស 00081215, ជាភាសាបារាំងគឺ 00614094។ នៅត្រង់ចំណុចនេះបានសរសេរថា “រដ្ឋាភិបាលគ្រាន់តែជារបាំងបិទបាំងលទ្ធិផ្តាច់ការរបស់ ប៉ុល ពត ផ្ទាល់ ហើយដែលមានមូលដ្ឋានយ៉ាងមាំក្នុងគណៈកម្មាធិការសន្តិសុខសម្ងាត់ ដែលមាន នួន ជា ប្រធាន។ សុន សេន ហៅ ខៀវ និងទីប្រឹក្សារបស់ សុន សេន ដែលជាប្រពន្ធរបស់គាត់ឈ្មោះ យុន យ៉ាត ហៅ អាត។ ដូច្នេះចាប់ពីឆ្នាំ១៩៧៥ ទៅឆ្នាំ១៩៧៨ ជើងកាង

ទាំងបួនមាន ប៉ុល ពត, នួន ជា, សុន សេន, យុន យ៉ាត ជាអ្នកសម្រេចរាល់ការសម្លាប់ និងការសម្លាប់រង្គាល"។

បាទ ខ្ញុំដាក់បង្ហាញឯកសាររបស់ខ្ញុំចប់ត្រឹមនេះ ហើយសហការីរបស់ខ្ញុំនឹងបង្ហាញបន្តទៀតបាទ សូមអរគុណ។

[១៥:៤២:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅក្នុងបទបង្ហាញរបស់ខ្ញុំ ឯកសារដែលខ្ញុំចាប់ផ្ដើមថ្ងៃនេះ ហើយ និងបន្តរហូតដល់ថ្ងៃស្អែកគឺ ខ្ញុំផ្ដោតជាសំខាន់ទៅលើឯកសារដែលនៅសល់ពីសេនាធិការ ក៏ដូចជាអគ្គបញ្ជាការរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងនោះរួមបញ្ចូលទាំងកំណត់ត្រាការប្រជុំរវាង សុន សេន ជាមួយនឹងលេខាកងពល ព្រមទាំងរបាយការណ៍ពីកងពលរួមបញ្ចូលទាំងចំណារដែលបង្ហាញថារបាយ-ការណ៍នេះត្រូវបានបញ្ជូនដោយ សុន សេន ទៅដល់មេដឹកនាំបក្សដទៃទៀត ព្រមទាំងការណែនាំ ឬក៏ការបង្គាប់បញ្ជាដែល សុន សេន បានបញ្ជាទៅដល់ប្រធានកងពលនានាផងដែរ។

[១៥:៤៤:០៨]

ឯកសារដែលខ្ញុំនឹងបង្ហាញនោះ នឹងនិយាយអំពីការរាយការណ៍លម្អិត និងប្រចាំរបស់ប្រធានកងពលទៅឲ្យមេដឹកនាំជាន់ខ្ពស់នៃទីក្រុងភ្នំពេញ ព្រមទាំងប្រព័ន្ធទំនាក់ទំនងរបស់យោធាជាមួយនឹងខាងគោលនយោបាយខាងបក្ស។ ហើយខ្ញុំនឹងធ្វើការបង្ហាញឯកសារតាមលំដាប់អក្ខរក្រម តាមលំដាប់នៃពេលវេលាដើម្បីឲ្យអង្គជំនុំជម្រះអាចពិនិត្យមើល ថាតើរចនាសម្ព័ន្ធនៃការរាយការណ៍ព្រមទាំងច្រវាក់នៃការដឹកនាំខាងលើ វាមានលក្ខណៈបែបណា? ហើយនៅក្នុងពេលជាមួយគ្នាហ្នឹង យើងនឹងពិនិត្យមើលទៅលើគោលនយោបាយ ព្រមទាំងបញ្ហាដែលទាក់ទងនៅក្នុងការទំនាក់ទំនងគ្នានេះផងដែរ។

[១៥:៤៤:៥៩]

ជាដំបូង គឺខ្ញុំនិយាយអំពីឯកសារបន្ទាប់ពីការរំដោះទីក្រុងភ្នំពេញបាន១ខែគឺបន្ទាប់ពីការរំដោះថ្ងៃ១៧ មេសា ៧៥។ ឯកសារនេះ គឺមានលេខ E3/832 គឺឯកសារ E3/832 ហើយចុះនៅថ្ងៃទី០៤ ខែ០៦ ឆ្នាំ១៩៧៥ ដែលបញ្ជូនឡើងដោយសមមិត្ត ភីម ជាប្រធានកងពល៧០២ ដែលនៅក្នុងតំបន់៧០៣

នៅក្នុងតំបន់ពិសេស។ ឯកសារនេះ គឺរាយការណ៍អំពីជនក្បត់១៧នាក់ ដែលជាទាហានរបស់ លន់ នល់ ហើយបានបញ្ជាក់នៅខាងចុង។ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។ នៅខាងក្រោម គឺបានបញ្ជាក់ដូចតទៅនេះ "ទាំង១៧នាក់នេះ បក្សពិនិត្យ និងសម្រេចកម្ទេច។ ស្នើសមមិត្តអនុវត្តតាមគោលការណ៍របស់បក្ស" សូមបញ្ចប់ការដកស្រង់។

[១៥:៤៦:២៥]

ការពណ៌នាអំពីទាហាន១៧នាក់ ដែលត្រូវកម្ទេចទាំងអស់នេះ ភាគីច្រើនគឺជាទាហានសុទ្ធក្នុងឋានៈវរសេនីយ៍ ហើយបានបញ្ជាក់ថា សមាជិកគ្រួសាររបស់ជនទាំង១៧នាក់នេះ ក៏ជាជនក្បត់ផងដែរ។ លេខ៧ នៅក្នុងក្រុមនេះ គឺឈ្មោះ ស៊ីសុវត្ថិរិទ្ធផារ៉ាវង្ស ដែលដែលត្រូវបានគេរាប់បញ្ចូលថាជាពួកសក្តិភូមិដែលបានក្បត់" សូមបញ្ចប់ការដកស្រង់។ ហើយលេខ១២ គឺ "ប្រាក់ វណ្ណារិន អានេះសរសេរប្រវត្តិរូបត្លុះតិះដៀលយើងខ្លាំងណាស់ ភាពដាច់ខាតប្រឆាំងនឹងបដិវត្តន៍"។

ហើយឯកសារបន្តទៀតដែលខ្ញុំនឹងបង្ហាញ គឺនិយាយអំពីដើមឆមាសទី១ នៃឆ្នាំ១៩៧៦ គឺឯកសារ E3/1016។ ខ្ញុំសូមនិយាយឡើងវិញគឺ E3/1016។ គឺរបាយការណ៍ថ្ងៃ០៥ មករា ៧៦ កងពល១៦៤ របស់ មុត ផ្ញើជូនបង៨៩។ គឺជារបាយការណ៍និយាយអំពីការវាយប្រហារកោះថាល។ ហើយនៅចុងបញ្ចប់នៃរបាយការណ៍នេះគឺបាននិយាយថា "ផ្ញើជូនបង៨៩ សេចក្តីរាយការណ៍ប្រចាំខែតាមរទេះភ្លើង"។

[១៥:៤៨:៣៩]

ហើយរបាយការណ៍នេះ និយាយអំពីការអនុវត្តគោលនយោបាយដែលដាក់ចេញដោយបក្ស ក៏ដូចជាឲ្យខាងកងពល ហើយនិងខាងភូមិភាគជាអ្នកអនុវត្ត។ ហើយបានបញ្ជាក់ថា "ខ្ញុំនៅកោះរុង និងរុងក្រៅ ដើម្បីតាមដាន និងណែនាំអនុវត្តសេចក្តីសម្រេចចិត្តនេះរបស់បក្សឲ្យមានប្រសិទ្ធភាព"។ គាត់ក៏បានរាយការណ៍ផងដែរ ខ្ញុំសូមដកស្រង់ "សមមិត្ត ឆាន ទៅជួប បងញឹក ហើយដើម្បីធ្វើការពិភាក្សា ហើយនិងដើម្បីអនុវត្តសម្រេចចិត្តរបស់បក្ស ហើយគឺជាប្រធានកងពល៤៦ នៃខេត្តកោះកុង។ ហើយសែ គឺជារហស្សនាមរបស់ កង ចាប គឺប្រធានកងពលសាមសិប -- អ៊ំ! ប្រធានកងពល៣៥។

ឯកសារបន្ទាប់ទៀតគឺ E3/887 គឺចុះថ្ងៃទី២៣ មករា ឆ្នាំ៧៦ ផ្ញើជូនអ៊ំ៨៩ ពី ០៥" ដែលសាក្សីបានបញ្ជាក់ថា "០៥ ហ្នឹង គឺ ស សារុន ជាលេខាកងពល១០១"។ ហើយទូរលេខានេះ បានរៀបរាប់អំពីការវាយប្រយុទ្ធជាមួយកងកម្លាំងវៀតណាម។ ហើយខាងយើងមិនទាន់វាយវិញទេ ដោយសារយើងរង់ចាំបញ្ជាពីអង្គការ។ ហើយនិយាយជាបញ្ជាក់សំខាន់នៅកថាខណ្ឌ៥ហ្នឹង គឺសូមអនុញ្ញាតបង្ហាញនៅ

លើអេក្រង់។

[១៥:៥០:៤០]

កថាខណ្ឌ៥បាននិយាយដូចតទៅនេះ៖ “ខ្ញុំរៀបចំកម្លាំង និងដកពិសោធន៍ និងរង់ចាំការសម្រេចរបស់បក្ស។ ដូចបានរាយការណ៍ខាងលើ ស្ទើរាយកន្លែងណាក៏ដោយ ឲ្យតែវានៅលើទឹកដីកម្ពុជា។ ខ្ញុំវាយទាំងអស់ តែមិនទាន់មានមតិសម្រេចពីអង្គការ។ ខ្ញុំធ្វើនយោបាយចាស់ទុំ ខំទ្រាំសិន មិនទាន់ផ្ទុះមួយគ្រាប់ទេ ចាំមតិអង្គការសិន”។ ហើយនៅចុងបញ្ចប់នៃទូរលេខ គឺមានបន្ថែមតទៅទៀត “នៅម៉ោង១១ ថ្ងៃទី២៣ ខែមករា ១៩៧៦នេះ ពួកយួន វាបញ្ជូនកម្លាំងវាមកវាយយើងទៀត។ យើងមិនទាន់ប្រយុទ្ធទេ” ហើយជាចុងក្រោយ គឺថា “សុំយោបល់អំប្រញាប់”។

ឯកសារបន្ទាប់ទៀត ដែលខ្ញុំចង់បង្ហាញមានលេខ E3/1175 គឺឯកសារថ្ងៃ២៦ ខែកុម្ភៈ ឆ្នាំ៧៦ ជារបាយការណ៍ប្រចាំថ្ងៃទាក់ទងទៅនឹងខ្មាំង សេ.អ៊ី.អា។ របាយការណ៍នេះ បានពិភាក្សាអំពីមនុស្សពីរនាក់ ដែលត្រូវបានឃុំខ្លួនដើម្បីសួរចម្លើយ ហើយនៅក្នុងពេលសួរចម្លើយនោះ ត្រូវបានគេបញ្ជាក់ថា “ជាបង ខន បានចូលរួមជាមួយពួកគេ”។

[១៥:៥២:៣៥]

យើងសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះ។ ឯកសារនេះ គឺមាននៅកំណត់ត្រាសរសេរដៃចំនួនពីរ ដែលទី១ គឺនៅខាងលើផ្នែកខាងឆ្វេង ដែលសរសេរដោយ ខៀវ “ជូនអង្គការជាព័ត៌មាន” ហើយអក្សរសរសេរដៃនៅខាងក្រោម គឺជាសំណួមពរ “សូមអង្គការសួរគ្រប់ផ្នែកមើល មានខាងណាចាប់បានឈ្មោះ ខន នេះ ឬទេ?”

ហើយឯកសារបន្ទាប់ គឺ E3/923 ហើយគឺឯកសារថ្ងៃ០៣ មីនា ឆ្នាំ៧៦ ផ្ញើជូនពី ឈិន ដែលជាប្រធានកងពលទៅបង៨៩ ហើយមានចម្លងជូនបង៨៧ និង បងវ៉ាន់ គឺជារហស្សនាមរបស់ អៀង សារី។ នៅក្នុងកថាខណ្ឌទី២ នៃរបាយការណ៍នេះ ដែលនិយាយអំពីផ្នែកផ្ទៃក្នុង គឺនិយាយអំពីការចាប់ខ្លួន និងការសួរចម្លើយ ហើយបានបញ្ជាក់ថា “ខ្ញុំបានចាប់ខ្លួនចំនួនប្រាំនាក់ បញ្ហាសមាសភាពមិនល្អ។ បញ្ហាទី១ សកម្មភាពបំផុតរត់ទៅផ្ទះ។ សកម្មភាពទី២ យកគ្រាប់បែក ប្រុងកម្ទេចឡាន។ ហើយបានអនុវត្តនូវសកម្មភាពដូចតទៅនេះ៖ “ខ្ញុំកំពុងតែសួរចម្លើយជាច្រើនទៀត ខ្ញុំជូនសំណុំរឿងខាងក្រោយ”។

[១៥:៥៤:៥៥]

ឯកសារបន្ទាប់ គឺ E/1176 គឺរបាយការណ៍ថ្ងៃ១៦ មីនា ៧៦ គឺកងពលលេខ៣១០ ប្រធាន

កងពលឈ្មោះ ពឿន ហើយមានសរសេរអក្សរផ្ទាល់ដៃនៅខាង "ជូនអង្គការជ្រាបជាព័ត៌មាន"។ ឯកសារនេះចាប់ផ្តើមដោយរាយការណ៍នូវព័ត៌មានលម្អិត អំពីខ្មាំងផ្ទៃក្នុង រហូតដល់ចុងបញ្ចប់នៃកថាខណ្ឌទី២ ដែលនិយាយអំពីកងពល និងកងវរសេនាតូច ដែលបានតម្រូវឲ្យមានការសិក្សា ដែលៗលួចសម្ភារៈនានា។

នៅក្នុងកថាខណ្ឌទី៤ នៅចុងនៃឯកសារនេះ ខ្ញុំគិតថាទំព័រជាភាសាខ្មែរគឺ 00021470 ហើយនៅខាងចុងគឺមានលេខឯកសារនេះ។ បញ្ហាបន្តទៅទៀតនេះ គឺរៀបរាប់ដោយប្រធានកងពលឈ្មោះ ពឿន។ ខ្ញុំសូមដកស្រង់ "បញ្ហាកើតឡើងនៅរោងចក្រជីបតុងនៅទួលគោក គឺថាកងកម្លាំងយើងបានតាមដាននៅពេលយប់ ហើយបានឃើញស្ត្រីម្នាក់នៅចាក់អង្រែ យកបទបដិវត្តន៍កែវាំជារបៀបជាសង្គមចាស់បែបអឺរ៉ុប ពួកវាពីដើម។ ទន្ទឹមនេះ ឃើញនារីបុរសប្រឡែងគ្នា ក្រោយប្រឡែងគ្នា ស្រាប់តែនាំគ្នាមួយគូៗចូលបន្ទប់ ហើយពន្លត់ភ្លើង"។ ហើយបានរៀបរាប់បន្តទៅទៀតថា "តាមពិនិត្យមួយរយៈហាក់ដូចជាសភាពបង្កើតការពុករលួយអាវ៉ាសែឡើងវិញ។ ឥឡូវនេះគឺឲ្យបងប្អូនលបចាំមើលឲ្យច្បាស់ ហើយឲ្យយកខ្សែអាត់លួចថតយកឯកសារច្បាស់ជូនអង្គការ"។

[១៥:៥៧:២៦]

ហើយហេតុការណ៍ដែលបានកើតឡើងនៅរោងចក្រជីបតុងនេះ គឺថាមាននូវការណែនាំសរសេរដៃ ដែលនៅចុងនៃរបាយការណ៍នេះ ដែលបានបញ្ជាក់ថា "សូមរាយការណ៍ជូនបង សមមិត្តវន (ដែលសំដៅលើ វន វ៉េត) ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ ដើម្បីធ្វើការឆ្លើយតប"។

ឯកសារបន្ទាប់ លោកប្រធាន គឺឯកសារ E3/1162 ហើយឯកសារនេះចុះថ្ងៃ២៦ ឧសភា ឆ្នាំ៧៦ មកពីប្រធានកងពលឈ្មោះ អឿន។ ឯកសារនេះ គឺនិយាយនៅកថាខណ្ឌទី៧ ដែលនិយាយអំពីការលាក់ប្រវត្តិរូប អំពីការត្រួតពិនិត្យប្រវត្តិរូបរបស់កម្មាភិបាល របស់សមាជិក។

កថាខណ្ឌទី៧ បានបញ្ជាក់ដូចតទៅ ខ្ញុំសូមដកស្រង់ "នៅក្នុងវរៈពិសេស៣១២ កងពិសេសមានសមមិត្តបីរូបលាក់ប្រវត្តិរូប។ ក) ឈ្មោះ ហៀក គាត់ដាក់និន្នាការនយោបាយគ្មានអ្វីទេ។ ដល់តាមដានដល់ផ្ទះ ឃើញឪពុកធ្វើទាហានកងឆ្មក់នៅកំពង់ធំ"។ ហើយបុគ្គលពីរនាក់ទៀត នៅក្នុងកថាខណ្ឌនេះក៏ត្រូវបានគេរាយការណ៍ថាមានសាច់ញាតិដែលជាទាហាននៅក្នុងរបបពីមុន។

លោកប្រធាន ខ្ញុំអាចបន្តទៅមុខទៀត ប្រសិនបើលោកប្រធានអនុញ្ញាត ដោយសារ -- ប៉ុន្តែប្រសិនបើលោកប្រធានគិតថាអាចបញ្ចប់ គឺថាខ្ញុំសូមអនុញ្ញាតបន្តនៅថ្ងៃស្អែកព្រឹក។ សូមអរគុណ។

[១៥:៥៩:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*